# សៀវភៅសង្ខេបស្តីអំពី៖ វេទិកាគោលនយោបាយថ្នាក់ខេត្ត របស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៦




Australian Aid

PONLOK CHOMNES

The Asia Foundation

# មាតិកា


សេចក្តីថ្លែងអំណរគុណ i

អំពីកម្មវិធីពន្លកចំណេះ ii

អំពីអង្គការមូលនិធិអាស៊ី ii

ក្រុមការងារ iii

អំណះអំណាង iii

សេចក្តីផ្តើម ១

សុន្ទរកថាស្វាគមន៍ ៣

សុន្ទរកថាបើកកម្មវិធី ៧

សុន្ទរកថាគន្លឹះ ១១

កិច្ចពិភាក្សាពេញអង្គ៖ ១៨
"ដំណោះស្រាយនៅមូលដ្ឋានដែលមានប្រសិទ្ធភាព៖ តើសហគមន៍ប្រែក្លាយទិន្នន័យ និងការចូលរួមទៅជាសកម្មភាពដោយរបៀបណា?"

កិច្ចពិភាក្សាពេញអង្គ៖ ២៦
"ការពិភាក្សាប្រកបដោយបរិយាបន្ននៅក្នុងការអនុវត្តជាក់ស្តែង"

ការពិភាក្សាស្របពេលគ្នា ១ក៖ ៣៦
"ការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមរយៈកម្មវិធីផ្ទេរសាច់ប្រាក់នៅកម្ពុជា"

ការពិភាក្សាស្របពេលគ្នា ១ខ៖
"ការបែងចែកថវិកាឃុំសម្រាប់ការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់លើសហគមន៍ងាយរងគ្រោះ" ៤៦

ការពិភាក្សាស្របពេលគ្នា ២ក៖ "ប្រព័ន្ធនវានុវត្តន៍ថ្នាក់តំបន់តាមរយៈកិច្ចសហការរវាងសាកលវិទ្យាល័យអាជ្ញាធរខេត្ត មន្ទីរជំនាញពាក់ព័ន្ធ និងវិស័យឧស្សាហកម្មនៅភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា" ៥៤

ការពិភាក្សាស្របពេលគ្នា ២ខ៖ "ការពង្រឹងកិច្ចគាំពារសង្គម សម្រាប់ពលករចំណាកស្រុកកម្ពុជា នៅក្នុងប្រទេស" ៦០

សុន្ទរកថាបិទកម្មវិធី ៦៧

សេចក្តីសន្និដ្ឋាន ៧០

ឧបសម្ព័ន្ធ ១៖ វាគ្មិន និងអ្នកសម្របសម្រួល ៧២

ឧបសម្ព័ន្ធ ២៖ របៀបវារៈ ៨៨

ឧបសម្ព័ន្ធ ៣៖ ការផ្សាយព័ត៌មានក្នុងប្រព័ន្ធផ្សព្វផ្សាយ ៩២

# សេចក្តីថ្លែងអំណរគុណ

អង្គការមូលនិធិអាស៊ី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកពាក់ព័ន្ធ រួមមាន អង្គការ ស្ថាប័ន និងម្ចាស់ជំនួយ ដែលបានរួមចំណែកធ្វើឱ្យវេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ អាចដំណើរការទៅបាន។

អង្គការមូលនិធិអាស៊ី សូមថ្លែងអំណរគុណចំពោះដៃគូ និងក្រុមជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ដែលបានផ្តល់ធាតុចូល និងកិច្ចសហការក្នុងការរៀបចំការពិភាក្សាជាមួយវាគ្មិន។ យើងខ្ញុំក៏សូមអរគុណដល់វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួលសម្រាប់ការចែករំលែកចំណេះដឹងដ៏មានតម្លៃក្នុងអំឡុងការពិភាក្សា និងសូមអរគុណចំពោះរដ្ឋាភិបាលអូស្ត្រាលី ដែលបានផ្តល់ការគាំទ្រថវិកា។

# អំពីកម្មវិធីពន្លកចំណេះ

ផ្អែកលើសមិទ្ធផលនៃកម្មវិធីពន្លកចំណេះ ដំណាក់កាលទី១ (២០១៩-២០២៣) ដែលផ្តោតលើការពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវនៅកម្ពុជា ដើម្បីធានាគុណភាពនៃការស្រាវជ្រាវ អង្គការមូលនិធិអាស៊ីបាន និងកំពុងអនុវត្តកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា (២០២៣-២០២៧)។ ក្រោមការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី កម្មវិធីនេះមានគោលដៅរួមចំណែកធ្វើឱ្យការសម្រេចចិត្តលើគោលនយោបាយសាធារណៈ ដែលផ្អែកលើទិន្នន័យ និងទទួលបានព័ត៌មានពីការពិភាក្សាប្រកបដោយបរិយាបន្នត្រូវបានយកទៅអនុវត្ត និងក្លាយជាបទដ្ឋាននៅកម្ពុជា។

# អំពីអង្គការមូលនិធិអាស៊ី

អង្គការមូលនិធិអាស៊ី គឺជាអង្គការអន្តរជាតិមិនស្វែងរកប្រាក់ចំណេញ ដែលខិតខំដោះស្រាយបញ្ហាសង្គម និងសេដ្ឋកិច្ចដ៏លំបាកបំផុតនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ ផ្អែកលើបទពិសោធជាង ៧០ ឆ្នាំ និងចំណេះដឹងមូលដ្ឋានស៊ីជម្រៅ អង្គការមូលនិធិអាស៊ីធ្វើការជាមួយដៃគូនៅតាមបណ្តាប្រទេសជាង២០ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងពង្រីកឱកាសសម្រាប់ប្រជាជននៅទីនោះ។

# ក្រុមការងារ

*ក្រុមការងារអង្គការមូលនិធិអាស៊ី*

Dolgion ALDAR

ជ័យ ម៉ារ៉ាមី

ហួត សាលីនិត

Meloney C. LINDBERG

ម៉ែន ពិចិត្រ

ម៉ន លីហ្សា

ងិន ពិសិដ្ឋ

ផន សុខភួង

ប្រាក់ វត្ថធិរា

រ៉េន ស្រីពេជ

ស៊ឹម សុវចនា

យ៉ា អានីតា

***ដៃគូនវានុវត្តន៍របស់កម្មវិធីពន្លកចំណេះ***

មជ្ឈមណ្ឌលសំរាប់ការវិភាគបញ្ហាអភិវឌ្ឍន៍
វិទ្យាស្ថានជាតិសង្គមកិច្ច
សាកលវិទ្យាល័យជាតិបាត់ដំបង
អង្គការភូមិខ្ញុំ

***ក្រុមជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម***

អង្គការជនពិការកម្ពុជា
អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
អង្គការនារីដើម្បីសន្តិភាព

***ហិរញ្ញប្បទាន***

កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖
ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា
ទទួលបានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី
និងអនុវត្តដោយអង្គការមូលនិធិអាស៊ី

# អំណះអំណាង

វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៦ ក្រោមប្រធានបទ "ការផ្សារភ្ជាប់សហគមន៍ ទិន្នន័យ និងគោលនយោបាយ៖ ការពង្រឹងការសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ ដើម្បីអនាគតកម្ពុជា" ទទួលបានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា របស់អង្គការមូលនិធិអាស៊ី។ ទស្សនៈដែលបានលើកឡើងនៅក្នុងសៀវភៅនេះ គឺជាទស្សនៈរបស់អ្នកវាគ្មិន និងអ្នកចូលរួមពិភាក្សាតែប៉ុណ្ណោះ និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលី ឬអង្គការមូលនិធិអាស៊ីឡើយ។

រក្សាសិទ្ធិដោយអង្គការមូលនិធិអាស៊ី ឆ្នាំ២០២៦


5
CHANEL



# សេចក្តីផ្តើម

នៅទូទាំងប្រទេសកម្ពុជា សហគមន៍មូលដ្ឋាន អ្នកស្រាវជ្រាវ និងអ្នកអនុវត្តការងារអភិវឌ្ឍន៍បាន និងកំពុងបង្កើតចំណេះដឹងកាន់តែច្រើនឡើង ដែលឆ្លុះបញ្ចាំងពីតថភាពជាក់ស្តែងនៃការរស់នៅ ការរំពឹងទុកនិងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ។ ចាប់ពីគម្រោងអភិវឌ្ឍន៍ដែលដឹកនាំដោយសហគមន៍រហូតដល់ការស្រាវជ្រាវបែបលក្ខណៈការចូលរួមស្តីពីជីវភាពរស់នៅ បរិស្ថាន និងបរិយាបន្នសង្គម ដែលទស្សនៈទាំងនេះទទួលបានពីមូលដ្ឋានផ្ទាល់ គឺជាមូលដ្ឋានទិន្នន័យដ៏មានតម្លៃសម្រាប់ការតាក់តែងគោលនយោបាយ ដែលមានភាពពាក់ព័ន្ធ និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ទោះបីជាមានការខិតខំប្រឹងប្រែងស្រាវជ្រាវកាន់តែច្រើន និងគំនិតផ្តួចផ្តើមដែលគាំទ្រដោយម្ចាស់ជំនួយនៅក្នុងវិស័យស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏ជារឿយៗ ដំណើរការពិភាក្សាគោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត នៅតែប្រមូលផ្តុំនៅថ្នាក់ជាតិ។ ទស្សនៈនៅថ្នាក់ខេត្ត និងសហគមន៍ច្រើនតែមិនសូវបានដាក់បញ្ចូលទៅក្នុងការពិភាក្សាគោលនយោបាយ ជាពិសេសទស្សនៈពីក្រុមដែលងាយរងគ្រោះ ដូចជាស្ត្រី យុវជន ជនជាតិដើមភាគតិច និងជនមានពិការភាព ។ ភាពចន្លោះប្រហោងបែបនេះធ្វើឱ្យគោលនយោបាយមិនអាចដោះស្រាយបញ្ហាបានគ្រប់ជ្រុងជ្រោយ ដោយផ្អែកតាមបរិបទសង្គម សេដ្ឋកិច្ច និងបរិស្ថានជាក់លាក់នៃបណ្តាខេត្តនានានៅកម្ពុជា។

កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា (២០២៣-២០២៧) ដែលទទួលបានការគាំទ្រថវិកាពីរដ្ឋាភិបាលអូស្ត្រាលី និងអនុវត្តដោយអង្គការមូលនិធិអាស៊ីបាន និងកំពុងធ្វើការជាមួយតួអង្គផ្សេងៗទាំងកម្រិតថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ នៅចន្លោះឆ្នាំ២០២៤ និង២០២៥ ដៃគូកម្មវិធីបានរៀបចំការពិគ្រោះយោបល់ ២៦១៤ លើក ជាមួយប្រជាពលរដ្ឋ មេគ្រួសារ ម្ចាស់អាជីវកម្ម និងសាលារៀន មកពី ១៦ខេត្តនៅទូទាំងប្រទេសកម្ពុជា ដើម្បីផ្តល់ព័ត៌មានសម្រាប់ការស្រាវជ្រាវរបស់ពួកគេស្តីពីការអភិវឌ្ឍជនបទ ការប្រែប្រួលអាកាសធាតុ ការធ្វើចំណាកស្រុក ការកែលម្អអាជីវកម្ម កិច្ចគាំពារសង្គម និងការអប់រំ។

ក្នុងខែកញ្ញា ឆ្នាំ២០២៥ កម្មវិធីពន្លកចំណេះ និងដៃគូ បានរៀបចំវេទិកាគោលនយោបាយថ្នាក់ជាតិ ក្រោមមូលបទ "ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន នៅក្នុងបរិបទប្រែប្រួល៖ ការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ"។ វេទិកានេះបានប្រមូលផ្តុំអ្នកចូលរួមជាង ២០០ នាក់ មកពីរាជរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ សង្គមស៊ីវិល និងសហគមន៍ ដើម្បីពិភាក្សាអំពីអនាគតនៃវិស័យស្រាវជ្រាវនៅកម្ពុជា និងស្វែងយល់ពីបញ្ហាអាទិភាពនានាដូចជា ការធ្វើចំណាកស្រុកដោយសារបញ្ហាអាកាសធាតុ កិច្ចគាំពារសង្គម និងការអភិវឌ្ឍជនបទនៅថ្នាក់ជាតិ។ សារដ៏សំខាន់មួយពីវេទិកានាពេលនោះ គឺភាពចាំបាច់នៃការធានាឱ្យបានថា ការប្តេជ្ញាចិត្តថ្នាក់ជាតិចំពោះការប្រើប្រាស់ទិន្នន័យ និងការលើកកម្ពស់ការពិភាក្សាប្រកបដោយបរិយាបន្ន ត្រូវបានរំលេចក្នុងការអនុវត្តជាក់ស្តែងនៅថ្នាក់ក្រោមជាតិ។

វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ មានគោលបំណងគាំទ្រដល់ការផ្លាស់ប្តូរបែបនេះ។ វេទិកាគោលនយោបាយថ្នាក់ខេត្ត នាំយកទិន្នន័យនៅមូលដ្ឋាន និងបទពិសោធន៍របស់សហគមន៍ទៅកាន់ការពិភាក្សាគោលនយោបាយ និងបង្កើតជាវេទិកាមួយ ដែលអង្គការសង្គមស៊ីវិល សាកលវិទ្យាល័យក្នុងស្រុក អ្នកស្រាវជ្រាវតាមសហគមន៍ និងអ្នកអនុវត្តការងារផ្ទាល់ អាចចែករំលែកនូវអ្វីដែលពួកគេកំពុងសង្កេតឃើញផ្ទាល់នៅមូលដ្ឋាន។ វេទិកានេះក៏អនុញ្ញាតឱ្យអ្នករៀបចំគោលនយោបាយថ្នាក់ខេត្ត និងថ្នាក់ជាតិ ពិភាក្សាគ្នាអំពីការរកឃើញទាំងនោះផងដែរ។ វេទិកានេះមានគោលដៅសាមញ្ញ គឺធានាថា ចំណេះដឹងកម្រិតមូលដ្ឋានត្រូវបានបន្លឺសម្លេង និងអាចជួយតម្រឹមតម្រង់ការសម្រេចចិត្តឱ្យកាន់តែល្អប្រសើរ និងប្រកបដោយបរិយាបន្នសម្រាប់បណ្តាខេត្តនានានៅកម្ពុជា។




លោកស្រី Meloney C. Lindberg

តំណាងអង្គការមូលនិធិអាស៊ី
ប្រចាំប្រទេសកម្ពុជា

# សុន្ទរកថាស្វាគមន៍

“

តាងនាមឱ្យអង្គការមូលនិធិអាស៊ី និងកម្មវិធីពន្លកចំណេះ នាងខ្ញុំមានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ក្នុងការស្វាគមន៍លោកអ្នកមកកាន់វេទិកាគោលនយោបាយថ្នាក់ខេត្ត ឆ្នាំ២០២៦ នៅខេត្តសៀមរាប ដែលជាមជ្ឈមណ្ឌលទេសចរណ៍ដ៏សំខាន់របស់ប្រទេសកម្ពុជា និងជាទីដ្ឋាននៃប្រាសាទអង្គរវត្តដ៏ល្បីល្បាញនៅលើពិភពលោក។

ជាបឋម នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី និងភាពជាដៃគូរបស់រាជរដ្ឋាភិបាលកម្ពុជា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
ការដឹកនាំ និងកិច្ចសហការរបស់លោកអ្នក មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការងារនេះ។

នាងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់ដៃគូកម្មវិធីពន្លកចំណេះ ដែលបានសហការរៀបចំវេទិកានាថ្ងៃនេះ និងជួយសម្របសម្រួលនាំយកអ្នកចូលរួមពីបណ្ដាខេត្តនានា មកចូលរួមក្នុងការពិភាក្សានេះ។ របៀបវារៈថ្ងៃនេះ ឆ្លុះបញ្ចាំងពីកិច្ចសហការ និងការប្ដេជ្ញាចិត្តចំពោះការពិភាក្សាដែលដឹកនាំដោយសហគមន៍មូលដ្ឋានផ្ទាល់។

នៅពេលដែលកម្មវិធីពន្លកចំណេះ ចាប់ផ្ដើមនៅឆ្នាំ២០១៩ វេទិកាគោលនយោបាយត្រូវបានបង្កើតឡើងដើម្បីផ្ដល់ឱកាសឱ្យរាជរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងសង្គមស៊ីវិល មកជួបជុំគ្នាពិភាក្សាអំពីទិន្នន័យ និងគោលនយោបាយ។ យូរៗទៅ វេទិកាទាំងនេះបានជួយពង្រឹងទំនុកចិត្ត និងកិច្ចសហការនៅទូទាំងវិស័យស្រាវជ្រាវនៅកម្ពុជា។

វេទិកាគោលនយោបាយថ្នាក់ខេត្តនាថ្ងៃនេះ គឺជាជំហានបន្ទាប់មួយ ដែលនាំយកស្មារតីនៃការពិភាក្សាដូចគ្នានេះ នៅកម្រិតថ្នាក់ក្រោមជាតិ។ វាជាការឆ្លើយតបទៅនឹងសារមួយដែលយើងបានឮយ៉ាងច្បាស់កាលពីវេទិកាគោលនយោបាយថ្នាក់ជាតិនៅឆ្នាំមុន៖ ការរៀបចំគោលនយោបាយប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យ មិនត្រឹមតែត្រូវអនុវត្តនៅថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវអនុវត្តនៅថ្នាក់ខេត្ត ស្រុក និងឃុំផងដែរ ព្រោះទីនោះជាកន្លែងដែលគោលនយោបាយត្រូវបានអនុវត្ត និងជាកន្លែងដែលផលជះនៃគោលនយោបាយស្ដែងឱ្យឃើញច្បាស់បំផុត។

”

នៅដំណាក់កាលទី១ កម្មវិធីពន្លកចំណេះបានកសាងមូលដ្ឋានគ្រឹះយ៉ាងសំខាន់សម្រាប់បរិយាបន្ន ដូចជាការបង្កើតបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ ដែលជាបណ្តាញអ្នកស្រាវជ្រាវជាស្ត្រីដំបូងគេនៅកម្ពុជា ដែលកំពុងបន្តដោះស្រាយវិសមភាពយេនឌ័រនៅក្នុងការស្រាវជ្រាវ និងបន្លឺសំឡេងរបស់ស្ត្រីនៅក្នុងការតាក់តែងគោលនយោបាយ។

នៅដំណាក់កាលទី២ (២០២៣-២០២៧) កម្មវិធីពន្លកចំណេះបាន និងកំពុងពង្រីកកិច្ចការនេះបន្ថែមទៀត។ យើងកំពុងសហការជាមួយស្ថាប័នស្រាវជ្រាវ សាកលវិទ្យាល័យ និងអង្គការសង្គមស៊ីវិលនៅកម្ពុជាជាង ២០ ស្ថាប័ន ក្នុងការដោះស្រាយបញ្ហាសំខាន់ៗចំពោះអនាគតរបស់កម្ពុជា ចាប់ពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍជនបទរហូតដល់កិច្ចគាំពារសង្គម អភិបាលកិច្ចប្រកបដោយបរិយាបន្ន ទិន្នន័យបើកទូលាយ ព្រមទាំងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។

ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ ដៃគូរបស់យើងបានធ្វើការជាមួយប្រជាពលរដ្ឋជាង ២៦០០ នាក់ នៅខេត្តចំនួន ១៦។ អ្វីដែលពួកគេបានចែករំលែកគឺច្បាស់លាស់ថា៖ ទិន្នន័យនៅមូលដ្ឋានគឺមានពិតមែន ដំណោះស្រាយនៅមូលដ្ឋានគឺក៏មានពិតមែន ប៉ុន្តែអ្វីដែលចាំបាច់គឺ ការផ្សារភ្ជាប់កាន់តែរឹងមាំទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ វេទិកានេះគឺជាជំហានមួយឆ្ពោះទៅរកការពង្រឹងនូវតំណភ្ជាប់ទាំងនោះ។

មូលបទនៃវេទិកាថ្ងៃនេះ "ការផ្សារភ្ជាប់សហគមន៍ ទិន្នន័យ និងគោលនយោបាយ" គឺមានភាពសមស្របទៅនឹងកាលៈទេសៈបច្ចុប្បន្ន។ អាជ្ញាធរខេត្ត និងសហគមន៍ កំពុងប្រឈមមុខនឹងភាពមិនប្រាកដប្រជាកាន់តែខ្លាំង ចាប់ពីផលប៉ះពាល់ដោយអាកាសធាតុ និងសម្ពាធសេដ្ឋកិច្ច រហូតដល់ការធ្វើចំណាកស្រុក និងការប្រែប្រួលប្រជាសាស្ត្រ។ ក្នុងបរិបទនេះ សមត្ថភាពប្រើប្រាស់ចំណេះដឹងក្នុងមូលដ្ឋាន និងជំរុញឱ្យសហគមន៍ចូលរួមប្រកបដោយអត្ថន័យក្នុងការធ្វើសេចក្តីសម្រេចចិត្ត គឺរឹតតែសំខាន់។

ហេតុនេះហើយទើបនៅក្នុងវេទិកានេះទាំងមូល យើងនឹងស្វែងយល់ពីសំណួរមួយ ដែលសាមញ្ញ ប៉ុន្តែសំខាន់៖ "តើធ្វើដូចម្តេចទើបអាចឱ្យដំណើរការតាក់តែងគោលនយោបាយថ្នាក់ក្រោមជាតិនៅកម្ពុជា កាន់តែប្រកបដោយបរិយាបន្ន ផ្អែកលើទិន្នន័យ និងឆ្លើយតបទៅនឹងតថភាពនៅកម្រិតមូលដ្ឋាន?"

### ដូច្នេះ វេទិកានេះមានគោលបំណងសាមញ្ញគឺ៖

- បង្កើតឱកាសសម្រាប់ការភ្ជាប់ទំនាក់ទំនងរវាងអាជ្ញាធរខេត្ត ស្ថាប័នថ្នាក់ជាតិ អ្នកស្រាវជ្រាវ សង្គមស៊ីវិល និងសហគមន៍។
- ចែករំលែកករណីនៅថ្នាក់ខេត្ត ដែលបង្ហាញពីរបៀបដែលទិន្នន័យ និងបទពិសោធន៍នៅមូលដ្ឋាន អាចផ្តល់ព័ត៌មានដល់ការសម្រេចចិត្តលើគោលនយោបាយ។
- និងលើកកម្ពស់ការពិភាក្សាប្រកបដោយបរិយាបន្ន ដោយធានាថា ទស្សនៈរបស់ស្ត្រី យុវជន ជនមានពិការភាព ជនជាតិដើមភាគតិច និងក្រុមមិនសូវមានភាពតំណាងដទៃទៀត ត្រូវបានដាក់បញ្ចូលទៅក្នុងការពិភាក្សា និងដំណោះស្រាយគោលនយោបាយ។

របៀបវារៈនេះត្រូវបានរៀបចំឡើងជុំវិញគោលបំណងទាំងនេះ។ ជាជាងការពិភាក្សាជាទូទៅអំពីវិស័យនានា លោកអ្នកនឹងបានស្តាប់នូវករណីជាក់ស្តែងតាមបណ្តាខេត្តនានា ជាមួយនឹងឱកាសសម្រាប់ការផ្លាស់ប្តូរយោបល់ឱ្យកាន់តែស៊ីជម្រៅនៅក្នុងវគ្គពិភាក្សាស្របពេលគ្នា។

នាងខ្ញុំក៏សូមគូសបញ្ជាក់ផងដែរអំពីវគ្គពិភាក្សាប្រកបដោយបរិយាបន្ន។ ក្នុងវគ្គនេះនឹងមានការចែករំលែកអំពីវិធីសាស្ត្រសម្របសម្រួលជាក់ស្តែង រួមទាំងឧបករណ៍ដែលអ្នកចូលរួមអាចយកទៅកែសម្រួល និងប្រើប្រាស់នៅក្នុងការពិគ្រោះយោបល់ថ្នាក់ខេត្ត និងដំណើរការធ្វើផែនការរបស់ពួកគេ ជាពិសេសគោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន។

វេទិកានាថ្ងៃនេះ មិនមែនមានត្រឹមតែការពិភាក្សាប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការផ្សារភ្ជាប់មនុស្សដែលកម្រមានឱកាសអង្គុយជាមួយគ្នា និងការផ្សារភ្ជាប់ទិន្នន័យជាមួយនឹងការសម្រេចចិត្ត ដែលជះឥទ្ធិពលលើជីវិតរស់នៅរបស់ប្រជាពលរដ្ឋផងដែរ។

នាងខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកទាំងអស់គ្នាចែករំលែកដោយបើកចំហ ស្តាប់ដោយយកចិត្តទុកដាក់ និងចូលរួមដោយស្មារតីចង់ចេះចង់ដឹង និងការគោរព។ គុណតម្លៃនៃវេទិកានេះ មិនត្រឹមតែស្ថិតលើអ្វីដែលបាននិយាយនៅលើឆាកប៉ុណ្ណោះទេ ប៉ុន្តែក៏ស្ថិតលើការសន្ទនាគ្នាពេញមួយថ្ងៃនេះផងដែរ។

ជាចុងក្រោយ នាងខ្ញុំសូមថ្លែងអំណរគុណដល់រដ្ឋបាលខេត្តសៀមរាប ដែលបានទទួលធ្វើជាម្ចាស់ផ្ទះ ដៃគូកម្មវិធីពន្លកចំណេះ ដែលបានជួយរៀបចំវេទិកានេះ និងអ្នកទាំងអស់គ្នា ដែលបានចំណាយពេលចូលរួម ជាពិសេសវាគ្មិនកិត្តិយស និងតំណាងសហគមន៍ ដែលបានធ្វើដំណើរមកពីបណ្តាខេត្តនានា ដើម្បីចែករំលែកបទពិសោធន៍របស់ខ្លួន។

នាងខ្ញុំមានទំនុកចិត្តថា ការពិភាក្សានាថ្ងៃនេះនឹងមានលក្ខណៈជាក់ស្តែង និងពាក់ព័ន្ធ ហើយចំណេះដឹង ដែលទទួលបានពីវេទិកានេះនឹងបន្តចូលរួមចំណែកដល់ដំណើរការរៀបចំគោលនយោបាយ ទោះវេទិកានេះត្រូវបានបញ្ចប់ទៅវិញក៏ដោយ។

**សូមអរគុណច្រើន និងសូមជូនពរឱ្យលោកអ្នកទទួលបានថ្ងៃដែលប្រកបដោយលទ្ធផលផ្លែផ្កា និងប្រកបដោយអត្ថន័យ។**






***លោកស្រី Kirsty Harris***

*ប្រធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍*
*នៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា*

# សុន្ទរកថាបើកកម្មវិធី

“

នាងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមជាមួយលោកអ្នកនៅថ្ងៃនេះ ក្នុងវេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៦។

នាងខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា  អាជ្ញាធរខេត្ត  ស្ថាប័នស្រាវជ្រាវ ដៃគូសង្គមស៊ីវិល និងតំណាងសហគមន៍ ដែលបានមកជួបជុំគ្នានៅថ្ងៃនេះ។ ជាបឋម នាងខ្ញុំសូមថ្លែងអំណរគុណដល់អង្គការមូលនិធិអាស៊ី និងកម្មវិធីពន្លកចំណេះ ព្រមទាំងដៃគូទាំងអស់ ដែលបានរៀបចំវេទិកាដ៏មានសារៈសំខាន់នេះ។

ដូចដែលបានលើកឡើងក្នុងសុន្ទរកថារបស់លោកស្រី Meloney Lindberg កាលពីខែកញ្ញាឆ្នាំមុន ពួកយើងជាច្រើននាក់បានមកជួបជុំគ្នាក្នុងវេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះ នៅរាជធានីភ្នំពេញ ហើយវេទិកានោះបានរំលេចសារដ៏មានអានុភាពមួយ ៖ *ការរៀបចំគោលនយោបាយប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យ ត្រូវតែបន្តពង្រីកឱ្យលើសពីការពិភាក្សាកម្រិតថ្នាក់ជាតិ និងត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញក្នុងការអនុវត្តជាក់ស្តែងនៅកម្រិតថ្នាក់ក្រោមជាតិ។* វេទិកានៅថ្ងៃនេះ គឺជាការឆ្លើយតបដោយផ្ទាល់ទៅនឹងការអំពាវនាវនោះ។

បណ្តាខេត្តនៅទូទាំងប្រទេសកម្ពុជា កំពុងប្រឈមមុខនឹងបញ្ហាដ៏ស្មុគស្មាញ និងប្រែប្រួលឥតឈប់ឈរ  មានជាអាទិ៍ ហានិភ័យទាក់ទងនឹងអាកាសធាតុ  សម្ពាធសេដ្ឋកិច្ច  ការប្រែប្រួលប្រជាសាស្ត្រ ការធ្វើចំណាកស្រុក និងកំណើនតម្រូវការសេវាសាធារណៈដែលឆ្លើយតបទាន់ពេលវេលា។

នៅពេលដែលទិន្នន័យថ្នាក់ខេត្ត និងបទពិសោធន៍សហគមន៍ មិនត្រូវបានបញ្ចូលទៅក្នុងការសន្ទនាគោលនយោបាយ  យើងអាចនឹងបង្កើតដំណោះស្រាយដែលមិនឆ្លុះបញ្ចាំងពេញលេញអំពីតថភាពនៅមូលដ្ឋាន។

ដូច្នេះ វេទិកានេះទទួលស្គាល់ថា តួអង្គថ្នាក់ខេត្តមិនត្រឹមតែជាអ្នកអនុវត្តគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ជាអ្នកមានចំណេះដឹង អ្នកផ្តល់ជាមតិយោបល់ និងអ្នកធ្វើសេចក្តីសម្រេចចិត្តផងដែរ។

”

តាមទស្សនៈរបស់ប្រទេសអូស្ត្រាលី គោលការណ៍នេះគឺជាចំណុចកណ្ដាលនៃភាពជាដៃគូអភិវឌ្ឍន៍យូរអង្វែងរបស់យើងជាមួយប្រទេសកម្ពុជា។ អូស្ត្រាលីបានគាំទ្រដល់ដំណើរអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាអស់ជាច្រើនទសវត្សរ៍មកហើយ តាមរយៈការធ្វើការងារលើវិស័យនានា ដូចជា អប់រំ សុខាភិបាល កសិកម្ម អភិបាលកិច្ច កិច្ចគាំពារសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ច។ តាមរយៈភាពជាដៃគូនេះ យើងសង្កេតឃើញថា គោលនយោបាយដ៏រឹងមាំមិនកើតចេញពីទិន្នន័យតែមួយមុខ ឬពីការពិគ្រោះយោបល់តែមួយមុខនោះទេ ប៉ុន្តែវាកើតចេញពីការច្របាច់បញ្ចូលគ្នានៃទិន្នន័យ ការពិភាក្សា និងចំណេះដឹងពីមូលដ្ឋាន។

ហេតុនេះហើយទើបចាប់តាំងពីឆ្នាំ២០១៩ មក ប្រទេសអូស្ត្រាលីបានផ្ដល់ការគាំទ្រដល់កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា។ ក្នុងដំណាក់កាលទី១ កម្មវិធីពន្លកចំណេះ បានពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវនៅកម្ពុជារួមមាន ស្ថាប័នស្រាវជ្រាវ (think tanks) អង្គការស្រាវជ្រាវ និងក្រុមគោលនយោបាយ ដើម្បីធ្វើការស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់ និងចែករំលែកការរកឃើញក្នុងវិធីដែលអាចជះឥទ្ធិពលដល់គោលនយោបាយ។ ការងារនេះបានកសាងមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការស្រាវជ្រាវប្រកបដោយបរិយាបន្ន ការកសាងបណ្ដាញ និងភាពគួរឱ្យជឿទុកចិត្ត។

នាពេលនេះ ស្ថិតក្នុងដំណាក់កាលទី២ កម្មវិធីពន្លកចំណេះកំពុងបន្តស្ថាបនាពីលើមូលដ្ឋានគ្រឹះនោះ តាមរយៈការផ្លាស់ប្ដូរចំណុចផ្ដោតសំខាន់ ពោលគឺមិនមែនផ្ដោតតែលើការបង្កើតការស្រាវជ្រាវដ៏ល្អប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្ដោតសំខាន់លើការបញ្ជ្រាបទិន្នន័យ និងការពិភាក្សាប្រកបដោយបរិយាបន្នទៅក្នុងរបៀបនៃការបង្កើត និងការអនុវត្តគោលនយោបាយផងដែរ។ ការផ្លាស់ប្ដូរនេះទទួលស្គាល់ថា ទិន្នន័យត្រូវតែអាចប្រើប្រាស់បាន ទាន់ពេលវេលា និងមានទំនាក់ទំនងនឹងដំណើរការធ្វើសេចក្ដីសម្រេចចិត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

វេទិកានៅថ្ងៃនេះ ឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីការផ្លាស់ប្ដូរ។ ជាជាងការរៀបចំការពិភាក្សាជុំវិញវិស័យគោលនយោបាយនីមួយៗ វេទិកានេះផ្ដោតសំខាន់លើរបៀបដែលការបង្កើតគោលនយោបាយដែលប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យ ត្រូវបានអនុវត្តនៅតាមបណ្ដាខេត្តនានា និងអ្វីដែលជួយសម្រួល ឬរារាំងដល់ការអនុវត្តនោះ។ ទោះបីជាប្រឈមមុខនឹងបញ្ហាខុសៗគ្នា ប៉ុន្តែបណ្ដាខេត្តនានាច្រើនតែជួបប្រទះបញ្ហាស្រដៀងគ្នាក្នុងការប្រើប្រាស់ទិន្នន័យ ការសម្របសម្រួលរវាងស្ថាប័ន ការជំរុញឱ្យសហគមន៍ចូលរួមប្រកបដោយអត្ថន័យ និងការយកចំណេះដឹងដែលទទួលបានទៅអនុវត្តជាក់ស្ដែង។

ចំណុចស្នូលនៃការងារនេះ គឺបរិយាបន្ន។ គោលនយោបាយនឹងកាន់តែគ្រប់ជ្រុងជ្រោយ នៅពេលដែលវាឆ្លុះបញ្ចាំងពីរបៀបដែលក្រុមផ្សេងៗជួបប្រទះបញ្ហាប្រឈម និងឱកាសក្នុងការអនុវត្តជាក់ស្ដែង។ ការធានាថាស្ត្រី យុវជន ជនមានពិការភាព ជនជាតិដើមភាគតិច និងសហគមន៍ងាយរងគ្រោះដទៃទៀត អាចចូលរួមចំណែកប្រកបដោយអត្ថន័យ ជួយបង្កើនភាពពាក់ព័ន្ធ ប្រសិទ្ធភាព និងនិរន្តរភាពនៃការសម្រេចចិត្តលើគោលនយោបាយ។

បទពិសោធន៍របស់ប្រទេសអូស្ត្រាលីផ្ទាល់ ក៏បានពង្រឹងមេរៀននេះផងដែរ។ យើងនៅតែបន្តរៀនសូត្រពីរបៀបដែលវិធីសាស្ត្របែបបរិយាបន្ន ពង្រឹងលទ្ធផលគោលនយោបាយទោះនៅក្នុងការស្រាវជ្រាវ ការផ្តល់សេវា ឬអភិបាលកិច្ចក៏ដោយ។ ដោយហេតុនេះហើយទើបកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ប្រទេសអូស្ត្រាលី ផ្អែកតាមការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះសមភាពយេនឌ័រ និងបរិយាបន្នពិការភាពរួមទាំងតាមរយៈយុទ្ធសាស្ត្រអន្តរជាតិដើម្បីសមភាពយេនឌ័រ និងយុទ្ធសាស្ត្រអន្តរជាតិដើម្បីសមធម៌ និងសិទ្ធិជនពិការរបស់យើង។ យុទ្ធសាស្ត្រទាំងនេះសង្កត់ធ្ងន់លើការផ្លាស់ប្តូរជាប្រព័ន្ធ និងការលុបបំបាត់របាំងរាំងការចូលរួម មិនមែនគ្រាន់តែបរិយាបន្នគ្រាន់ជានិមិត្តរូបនោះទេ។

វេទិកានេះត្រូវបានរៀបចំឡើងចំពេលវេលាដ៏សំខាន់មួយ។ បណ្តាខេត្តនានានៅទូទាំងប្រទេសកម្ពុជា កំពុងជួបប្រទះនឹងបញ្ហាប្រឈមនានាដែលកាន់តែស្មុគស្មាញនិងប្រទាក់ក្រឡាទៅវិញទៅមក រួមមាន៖ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុការផ្លាស់ប្តូរសេដ្ឋកិច្ច ការផ្លាស់ប្តូរប្រជាសាស្ត្រ ការវិវត្តផ្នែកបច្ចេកវិទ្យានិងការរំពឹងទុកកាន់តែខ្ពស់ចំពោះសេវាសាធារណៈក្នុងស្រុកដែលមានការឆ្លើយតបលឿនរហ័ស។

កិច្ចពិភាក្សាពេញអង្គស្តីពី "ដំណោះស្រាយនៅមូលដ្ឋានដែលមានប្រសិទ្ធភាព" នៅព្រឹកនេះ គឺជាឧទាហរណ៍ដ៏ល្អមួយនៃរបៀប ដែលគោលការណ៍ទាំងនេះអាចត្រូវបានអនុវត្តជាក់ស្តែង។ ការលើកឡើងនូវបទពិសោធន៍ជាក់ស្តែងពីបណ្តាខេត្តនានា ធ្វើឱ្យការពិភាក្សានេះគ្របដណ្តប់លើសពីទ្រឹស្តី និងឈានដល់ការបង្ហាញពីរបៀបដែលតួអង្គក្នុងមូលដ្ឋាន ប្រើប្រាស់ទិន្នន័យ ការចូលរួម និងការពិភាក្សា ដើម្បីដោះស្រាយបញ្ហាប្រឈមពិតប្រាកដ។

បទពិសោធន៍ទាំងនេះ មានតម្លៃជាពិសេសសម្រាប់អ្នកតាក់តែងគោលនយោបាយ ព្រោះវាគូសបញ្ជាក់ពីផ្នែកដែលប្រព័ន្ធនានាគាំទ្រដល់សកម្មភាពនៅមូលដ្ឋាន និងផ្នែកដែលអាចត្រូវមានការកែសម្រួល ដើម្បីឱ្យកាន់តែងាយស្រួលដាក់បញ្ចូលទិន្នន័យ និងការចូលរួម ទៅក្នុងការអនុវត្តជាក់ស្តែង។





***លោក អ៊ឹង គឹមលាង***

*អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប*

# សុន្ទរកថាគន្លឹះ

“

វាជាកិត្តិយសដ៏ធំធេងសម្រាប់ខេត្តសៀមរាប ដែលបានធ្វើជាម្ចាស់ផ្ទះរៀបចំវេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៦ ហើយខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួម និងថ្លែងសុន្ទរកថាគន្លឹះនៅក្នុងវេទិកានេះជាមួយអ្នកទាំងអស់គ្នា។

ជាបឋម ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះអ្នកចូលរួមទាំងអស់ ដែលបានធ្វើដំណើរមកពីបណ្តាខេត្តផ្សេងៗ និងរាជធានីភ្នំពេញ ដើម្បីចូលរួមក្នុងវេទិកានាថ្ងៃនេះ។ យើងមានសេចក្តីសោមនស្សរីករាយ ដែលបានទទួលស្វាគមន៍អ្នកទាំងអស់គ្នានៅក្នុងខេត្តសៀមរាប។

ខេត្តសៀមរាបមានកេរ្តិ៍ឈ្មោះល្បីល្បាញខាងសម្បត្តិបេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ ប៉ុន្តែក៏ជាទីដែលសហគមន៍កំពុងបន្សាំខ្លួនទៅនឹងការផ្លាស់ប្តូរផងដែរ។ សព្វថ្ងៃនេះ ខេត្តសៀមរាបកំពុងខិតខំធ្វើយ៉ាងណាស្តារវិស័យទេសចរណ៍ឡើងវិញ ធ្វើពិពិធកម្មជីវភាពរស់នៅ កាត់បន្ថយសម្ពាធលើធនធានធម្មជាតិ និងធានាឱ្យបានថា សហគមន៍មូលដ្ឋានពិតជាទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រាកដមែន។

តាមប្រវត្តិសាស្ត្រ ខេត្តសៀមរាបមិនត្រឹមតែជាមជ្ឈមណ្ឌលនយោបាយនៃចក្រភពខ្មែរប៉ុណ្ណោះទេ ប៉ុន្តែក៏ជាទីប្រមូលផ្តុំនៃការសិក្សារៀនសូត្រ  ដែលផ្សារភ្ជាប់ចំណេះដឹង  និងកិច្ចការរដ្ឋបាលទៅនឹងជីវិតសាធារណៈផងដែរ។ ដូច្នេះ ការជួបជុំគ្នានៅថ្ងៃនេះដើម្បីជជែកពិភាក្សាអំពីរបៀបដែលទិន្នន័យ  និងការសន្ទនា អាចផ្តល់ផលជះដល់ការតាក់តែងគោលនយោបាយគឺជាកិច្ចការដ៏មានអត្ថន័យ។

ទន្ទឹមនឹងនេះ ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងស្មោះស្ម័គ្រចំពោះរដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ី ព្រមទាំងកម្មវិធីពន្លកចំណេះ ដែលនៅតែបន្តចាប់ដៃគូសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នស្រាវជ្រាវ និងសហគមន៍នៅទូទាំងប្រទេសកម្ពុជា។ ខ្ញុំសូមវាយតម្លៃខ្ពស់ និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់កម្មវិធីនេះ ក្នុងការពង្រឹងការផ្សារភ្ជាប់គ្នារវាងចំណេះដឹងក្នុងមូលដ្ឋាន ការពិភាក្សាប្រកបដោយបរិយាបន្ន និងការសម្រេចចិត្តលើគោលនយោបាយ។

”

## ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីគោរព

យើងទាំងអស់គ្នាកំពុងស្ថិតក្នុងដំណាក់កាលនៃការផ្លាស់ប្តូរដ៏ស៊ីជម្រៅ និងភាពមិនប្រាកដប្រជា។ ឧទាហរណ៍ ការប្រែប្រួលសេដ្ឋកិច្ច និងឌីជីថលូបនីយកម្ម កំពុងជះឥទ្ធិពលលើទីផ្សារការងារ និងទំនាក់ទំនងសង្គម។ ការធ្វើចំណាកស្រុក ទោះក្នុងប្រទេស ឬឆ្លងដែន នៅតែបន្តបង្កផលប៉ះពាល់ដល់គ្រួសារ និងសហគមន៍។ ស្របពេលជាមួយគ្នានេះ ការវិវត្តនៅលើពិភពលោក និងក្នុងតំបន់ មានឥទ្ធិពលកាន់តែខ្លាំងមកលើតថភាពនៅកម្រិតមូលដ្ឋាន ហើយភាគច្រើនគឺមិនអាចស្មានដឹងបានឡើយ។

ក្នុងបរិបទនេះ ការតាក់តែងគោលនយោបាយប្រកបដោយប្រសិទ្ធភាព អាស្រ័យលើទិន្នន័យដែលមានភាពពាក់ព័ន្ធ ទាន់ពេលវេលា ចេញពីមូលដ្ឋានដោយផ្ទាល់ និងផ្អែកតាមបទពិសោធន៍របស់អ្នកដែលរងផលប៉ះពាល់ដោយផ្ទាល់។ទាល់តែមានទិន្នន័យបែបនេះទើបដំណោះស្រាយគោលនយោបាយ អាចដោះស្រាយ និងកែលម្អបញ្ហាប្រឈមក្នុងមូលដ្ឋានបានយ៉ាងមានប្រសិទ្ធភាព។

សម្រាប់ខេត្តដូចជាសៀមរាប ទិន្នន័យក្នុងមូលដ្ឋានពិតជាសំខាន់ខ្លាំងណាស់។ ក្របខ័ណ្ឌគោលនយោបាយជាជាតុផ្សំដ៏ចាំបាច់សម្រាប់តម្រង់ទិសការអភិវឌ្ឍជាតិ ប៉ុន្តែជារឿយៗ ស្ថានភាពកម្រិតមូលដ្ឋាន មានលក្ខណៈខុសគ្នាពីខេត្តមួយទៅខេត្តមួយ។ បើគ្មានទិន្នន័យពីមូលដ្ឋានទេ គោលនយោបាយអាចនឹងមើលរំលងលក្ខណៈខុសគ្នាទាំងនេះ និងមិនអាចឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងតថភាពនៅកម្រិតមូលដ្ឋាន។

ឧទាហរណ៍ ចំណេះដឹងក្នុងមូលដ្ឋានអាចបង្ហាញអំពីបទពិសោធន៍របស់គ្រួសារនីមួយៗក្នុងការទទួលបានកម្មវិធីគាំពារសង្គម មិនមែនត្រឹមតែរបៀបរៀបចំកម្មវិធីនោះទេ។ វាបង្ហាញពីរបាំងរាំងស្ត្រី យុវជន ជនមានពិការភាព ជនជាតិដើមភាគតិច និងក្រុមដែលត្រូវបានផាត់ចេញផ្សេងទៀត ដែលជារបាំងដែលគេមិនអាចមើលឃើញតាមរយៈទិន្នន័យរួម។

ខ្ញុំសូមចែករំលែកឧទាហរណ៍ជាក់ស្តែងមួយថា តើហេតុអ្វីបានជាចំណេះដឹង និងទិន្នន័យក្នុងមូលដ្ឋានមានសារៈសំខាន់មិនត្រឹមតែសម្រាប់រដ្ឋាភិបាលថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏មានសារៈសំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ក្នុងអំឡុងពេលនៃការផ្ទុះឡើងជំងឺរាតត្បាតកូវីដ-១៩ រដ្ឋបាលថ្នាក់ជាតិបានសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដាក់ចេញវិធានការឆ្លើយតប ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យឃុំ ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងប្រព័ន្ធផ្សេងទៀតរួមជាមួយនឹងទិន្នន័យដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីស្វែងយល់អំពីស្ថានភាពក្នុងមូលដ្ឋាន ស្ថានភាពហិរញ្ញវត្ថុ អន្តោប្រវេសន៍ និងកត្តាផ្សេងទៀត ដែលជាប្រយោជន៍ដល់រដ្ឋាភិបាលក្នុងការធ្វើអន្តរាគមន៍បានទាន់ពេលវេលា។ លើសពីនេះ ទិន្នន័យក្នុងមូលដ្ឋានមានសារៈសំខាន់ណាស់សម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារដែលទើបតែធ្លាក់ក្នុងស្ថានភាពក្រីក្រដោយសារជំងឺកូវីដ-១៩ ដែលមានសិទ្ធិទទួលបានការឧបត្ថម្ភសាច់ប្រាក់ពីរដ្ឋាភិបាល។ មួយវិញទៀត ទិន្នន័យទាំងនេះបានដើរតួយ៉ាងសំខាន់ក្នុងការជួយដល់រដ្ឋាភិបាលធ្វើយុទ្ធនាការចាក់វ៉ាក់សាំងនៅកម្រិតមូលដ្ឋាន ដែលបានរួមចំណែកដល់ការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងការបើកដំណើរការប្រទេសឡើងវិញ ដើម្បីឱ្យមានការស្តារសេដ្ឋកិច្ចជាថ្មី។

ហេតុនេះហើយ ទិន្នន័យនៅកម្រិតមូលដ្ឋានមិនត្រឹមតែមានភាពពាក់ព័ន្ធសម្រាប់ការធ្វើសេចក្ដីសម្រេចចិត្តថ្នាក់ខេត្តប៉ុណ្ណោះទេប៉ុន្តែក៏ជាធាតុចូលដ៏សំខាន់សម្រាប់ការតាក់តែងគោលនយោបាយថ្នាក់ជាតិផងដែរ។

នាពេលបច្ចុប្បន្ន ខេត្តសៀមរាបកំពុងផ្ដោតលើគោលដៅ និងយុទ្ធសាស្ត្រសំខាន់ៗមួយចំនួន ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការផ្ដល់សេវាកម្មសាធារណៈដែលធ្វើការឆ្លើយតបនឹងតម្រូវការក្នុងស្រុក និងដោះស្រាយបញ្ហាប្រឈមនានា ឱ្យមានប្រសិទ្ធភាព និងប្រកបដោយបរិយាបន្ន។ យើងទន្ទឹងរង់ចាំការចែករំលែកបន្ថែមទៀតអំពីគោលដៅគោលនយោបាយទាំងនេះ ដូចជារបៀបដែលយើងកំពុងប្រើប្រាស់ទិន្នន័យ សំឡេងពីប្រជាពលរដ្ឋរបស់យើងក្នុងការរៀបចំ និងអនុវត្តគោលដៅទាំងនេះទៅក្នុងមូលដ្ឋានដោយផ្ទាល់។

ខ្ញុំក៏ចង់លើកឡើងផងដែរថា កម្ពុជាសម្រេចបានវឌ្ឍនភាពយ៉ាងសំខាន់នៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ បច្ចុប្បន្ន អាជ្ញាធរខេត្ត ស្រុក និងឃុំបាន និងកំពុងដើរតួនាទីកាន់តែសកម្មក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ការផ្ដល់សេវា និងអភិបាលកិច្ចមូលដ្ឋាន។ នៅចំពោះមុខការទទួលខុសត្រូវកាន់តែច្រើនបែបនេះ យើងរឹតតែត្រូវការទិន្នន័យដែលឆ្លុះបញ្ចាំងពីតថភាពក្នុងមូលដ្ឋាន។ នៅថ្នាក់ខេត្ត ទិន្នន័យជួយគាំទ្រដល់ការសម្រេចចិត្តឱ្យកាន់តែប្រសើរឡើង តាមវិធីដូចខាងក្រោម៖

ទីមួយ ទិន្នន័យជួយកំណត់អាទិភាព។ ទិន្នន័យក្នុងមូលដ្ឋាន និងការយល់ដឹងស៊ីជម្រៅពីសហគមន៍ អាចឱ្យអាជ្ញាធរប្រមូលផ្ដុំធនធានសម្រាប់ផ្ដល់ដល់កន្លែង ដែលខ្វះខាតបំផុត។



ទីពីរ ទិន្នន័យជួយកែលម្អការអនុវត្តគោលនយោបាយ។ ការយល់ដឹងអំពីរបៀបដែលគោលនយោបាយត្រូវបានទទួលយក និងអនុវត្តនៅកម្រិតមូលដ្ឋាន ជួយឱ្យរកឃើញចន្លោះប្រហោង ផលវិបាកមិនល្អ និងឱកាសសម្រាប់ការកែលម្អ។

ទីបី ទិន្នន័យជួយពង្រឹងគណនេយ្យភាព និងទំនុកចិត្ត។ នៅពេលដែលសហគមន៍មើលឃើញថា បទពិសោធន៍ និងទស្សនៈរបស់ពួកគេ បានផ្តល់ផលដល់ការសម្រេចចិត្ត ពួកគេនឹងមានទំនុកចិត្តកាន់តែខ្លាំងលើស្ថាប័នសាធារណៈ។

ឧទាហរណ៍ យើងប្រើប្រាស់ប្រព័ន្ធទិន្នន័យឃុំ ដើម្បីកំណត់រកតំបន់សម្រាប់អនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ខេត្ត ស្រុក និងឃុំ ហើយទន្ទឹមនឹងនោះ ក៏បានចែករំលែកជាមួយរដ្ឋបាលថ្នាក់ជាតិ។ យើងមើលឃើញពីសារៈសំខាន់នៃប្រព័ន្ធទិន្នន័យឃុំ និងសង្ឃឹមថា កម្មវិធីអភិវឌ្ឍន៍ ដូចជា កម្មវិធីពន្លកចំណេះ អាចជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ខេត្តក្នុងការពង្រឹងភាពគួរឱ្យជឿទុកចិត្តនៃទិន្នន័យ និងរួមបញ្ចូលព័ត៌មានសំខាន់ៗបន្ថែមទៀត ដូចជា ការប្រែប្រួលអាកាសធាតុ ផលជះលើសហគមន៍ និងទិន្នន័យលម្អិតបន្ថែមទៀតស្តីពីស្ថានភាពរបស់ក្រុមដែលត្រូវបានផាត់ចេញ។

ទោះជាយ៉ាងណាក៏ដោយ គុណតម្លៃនៃទិន្នន័យក្នុងមូលដ្ឋានផ្តល់ប្រយោជន៍លើសពីថ្នាក់ខេត្តទៅទៀត។ នៅពេលត្រូវបានចងក្រងជាឯកសារ វិភាគ និងផ្សព្វផ្សាយជាប្រព័ន្ធ បទពិសោធន៍ថ្នាក់ខេត្តក៏អាចផ្តល់ព័ត៌មានដល់យុទ្ធសាស្ត្រជាតិ គោលនយោបាយតាមវិស័យ និងដំណើរការកំណែទម្រង់ផងដែរ។

ដូច្នេះ គោលនយោបាយថ្នាក់ជាតិនឹងមានភាពគ្រប់ជ្រុងជ្រោយបំផុត នៅពេលដែលវាច្បាមយកគតិភាព និងបទពិសោធន៍ពីថ្នាក់ខេត្ត ស្រុក និងឃុំ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យ ដូចដែលបានឆ្លុះបញ្ចាំងក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ និងក្របខ័ណ្ឌគោលនយោបាយជាតិផ្សេងទៀត មានជាអាទិ៍ កិច្ចគាំពារសង្គម ប្រព័ន្ធទិន្នន័យឃុំ ការអភិវឌ្ឍជនបទ។ ទោះជាយ៉ាងនេះក្តី ប្រសិទ្ធភាពនៃក្របខ័ណ្ឌទាំងនេះ អាស្រ័យលើថាតើវាឆ្លុះបញ្ចាំងពីស្ថានភាពក្នុងមូលដ្ឋានបានល្អកម្រិតណា និងថាតើវាឆ្លើយតបប្រកបដោយភាពបត់បែនទៅនឹងបញ្ហាប្រឈមដែលកំពុងលេចឡើងយ៉ាងដូចម្តេច។

ខ្ញុំគិតថា នេះជាចំណុចដែលវេទិកានានា ដូចជា វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះដើរតួនាទីយ៉ាងសំខាន់ ដោយបំពេញបន្ថែមលើវេទិកាដែលមានស្រាប់ផ្សេងទៀត ដែលមិនត្រឹមតែតភ្ជាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្សារភ្ជាប់ជាមួយអង្គការសង្គមស៊ីវិល គ្រឹះស្ថានសិក្សា និងសហគមន៍ផងដែរ។




ខ្ញុំដឹងថា កម្មវិធីពន្លកចំណេះក៏បានធ្វើការជាមួយដៃគូមួយចំនួនផងដែរ ដើម្បីលើកកម្ពស់ការផ្តល់អាហារូបករណ៍ ការស្រាវជ្រាវ និងការពិភាក្សាប្រកបដោយបរិយាបន្ននៅក្នុងខេត្តសៀមរាប រួមទាំងបណ្ណាល័យរបស់មជ្ឈមណ្ឌលខេមរសិក្សា ដែលផ្តល់ប្រយោជន៍យ៉ាងច្រើនដល់ខេត្តសៀមរាបក្នុងការជួយជំរុញសកម្មភាពស្រាវជ្រាវ រីឯការងាររបស់សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ (CCYMCR) និងការងាររបស់ក្រុមសិល្បៈល្ខោនឆ្លុះ បានគូសបញ្ជាក់ពីសារៈសំខាន់នៃការធ្វើឱ្យការស្រាវជ្រាវ និងទិន្នន័យកាន់តែងាយស្រួលទទួលបាន និងខិតជិតសហគមន៍។ កិច្ចការទាំងមូលនៃការបង្វែរទិន្នន័យទៅជាគោលនយោបាយ តម្រូវឱ្យមានមនុស្ស និងស្ថាប័នជាច្រើនដែលមានជំនាញ និងចក្ខុវិស័យផ្សេងៗគ្នាមកជួបជុំគ្នា និងបង្កើតជាកម្លាំងផ្តួប។ បន្ទាប់មកយើងអាចរំពឹងទុកថា ចំណេះដឹងនឹងប្រែក្លាយទៅជាគោលនយោបាយ រួចទើបបង្កើតជាផលជះ។

ពួកគេបង្កើតនូវយន្តការដែលមានការរៀបចំត្រឹមត្រូវ ដើម្បីឱ្យទិន្នន័យក្នុងមូលដ្ឋានអាចឈានទៅដល់ការពិភាក្សាថ្នាក់ជាតិ ហើយក្នុងពេលជាមួយគ្នានោះ អាចឱ្យមានការពិភាក្សា និងកែលម្អអាទិភាពថ្នាក់ជាតិ នៅថ្នាក់ក្រោមជាតិ។

រដ្ឋបាលខេត្តយល់ឃើញថាមានកត្តាជំរុញសំខាន់ៗ ដើម្បីពង្រឹងការផ្សារភ្ជាប់គ្នាបែបនេះគឺ៖

ទីមួយ ការស្រាវជ្រាវ និងទិន្នន័យក្នុងមូលដ្ឋានដែលអាចជឿទុកចិត្តបាន ត្រូវតែទទួលបានការគាំទ្រ។ នេះរួមបញ្ចូលទាំងកិច្ចសហការរវាងសាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ដែលអាចចុះដល់សហគមន៍ និងអាចកសាងការយល់ដឹងស៊ីជម្រៅ ដែលពាក់ព័ន្ធនឹងគោលនយោបាយ។

ទីពីរ យន្តការសម្រាប់ការពិភាក្សារវាងតួអង្គថ្នាក់ខេត្ត និងថ្នាក់ជាតិ ត្រូវតែមាននិរន្តរភាព។ ទិន្នន័យនឹងមានផលជះតិចតួចបំផុត ប្រសិនបើទិន្នន័យនោះមិនត្រូវបានជជែកដេញដោល និងបំប្លែងទៅជាជម្រើសគោលនយោបាយ។

ទីបី សមត្ថភាពនៅថ្នាក់ក្រោមជាតិត្រូវតែពង្រឹងបន្តទៀត មិនត្រឹមតែដើម្បីប្រមូលទិន្នន័យប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីវិភាគ បកស្រាយ និងប្រើប្រាស់ទិន្នន័យទាំងនោះជាយុទ្ធសាស្ត្រក្នុងការរៀបចំផែនការ និងការសម្របសម្រួលជាមួយក្រសួង និងមន្ទីរជំនាញផងដែរ។

បន្ថែមលើនេះ ខ្ញុំចង់ចែករំលែកថា ទិន្នន័យក្នុងមូលដ្ឋានមានឥទ្ធិពលបំផុត នៅពេលដែលវាមានលក្ខណៈបរិយាបន្ន។ ចំណុចសំខាន់គឺត្រូវធានាថា សំឡេងរបស់ស្ត្រី យុវជន ជនមានពិការភាព ជនជាតិដើមភាគតិច និងក្រុមដែលត្រូវបានផាត់ចេញដទៃទៀត ត្រូវបានដាក់បញ្ចូលនៅក្នុងដំណើរការគោលនយោបាយ ពីព្រោះជារឿយៗពួកគេទទួលរងផលជះខ្លាំងជាងគេពីការសម្រេចចិត្តលើគោលនយោបាយ។

នៅពេលយើងបញ្ជ្រាបទិន្នន័យប្រកបដោយបរិយាបន្នទៅក្នុងការតាក់តែងគោលនយោបាយ យើងមិនត្រឹមតែកែលម្អលទ្ធផលប៉ុណ្ណោះទេ ប៉ុន្តែយើងក៏បានពង្រឹងសម្ព័ន្ធភាពក្នុងសង្គម និងភាពជាម្ចាស់រួមគ្នាលើដំណើរការអភិវឌ្ឍន៍ផងដែរ។

ជាចុងក្រោយ ខ្ញុំចង់គូសបញ្ជាក់អំពីមេរៀនទូទៅចំនួនបី ដែលផុសចេញពីបទពិសោធន៍នៅថ្នាក់ខេត្តរបស់ខេត្តសៀមរាបៈ

ទីមួយ ការតាក់តែងគោលនយោបាយគឺជាដំណើរការបន្តដដែលៗ។ ទិន្នន័យគួរតែត្រូវបានប្រើប្រាស់ មិនត្រឹមតែជាទុនដល់ការរៀបចំគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការកែលម្អផងដែរ។

ទីពីរ បរិបទក្នុងមូលដ្ឋាន គឺជារឿងសំខាន់។ អ្វីដែលដំណើរការបានជោគជ័យនៅក្នុងខេត្តមួយ មិនប្រាកដថាជោគជ័យយកទៅអនុវត្តក្នុងខេត្តមួយទៀតនោះទេ។ ដូច្នេះ ខ្ញុំគិតថា គោលនយោបាយថ្នាក់ជាតិគួរតែមានភាពបត់បែនក្នុងការកែច្នៃតម្រូវតាមមូលដ្ឋាន និងប្រើ ដែលផ្អែកតាមទិន្នន័យជាក់ស្តែងនៅថ្នាក់ខេត្ត។

ទីបី ភាពជាដៃគូគឺជាគន្លឹះសំខាន់។ រដ្ឋបាលថ្នាក់ខេត្តតែម្នាងមិនអាចផលិត និងប្រើប្រាស់ទិន្នន័យតែឯងបានទេ គឺចាំបាច់ត្រូវមានកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ ស្ថាប័នស្រាវជ្រាវ សង្គមស៊ីវិល សហគមន៍ និងដៃគូអភិវឌ្ឍន៍។

ខ្ញុំសូមស្វាគមន៍សហការី និងតំណាងអាជ្ញាធរមូលដ្ឋានមកពីបណ្តាខេត្តផ្សេងទៀត ចូលរួមសហការជាមួយយើងក្នុងការអនុវត្ត ក៏ដូចជាកម្មវិធីនានា ដូចជាកម្មវិធីពន្លកចំណេះ ក្នុងការចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការលើកកម្ពស់ការប្រើប្រាស់ទិន្នន័យចម្រុះ  សម្រាប់ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន សំដៅសម្រេចបានការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា។

ជារួម  ខ្ញុំសូមសង្កត់ធ្ងន់ថាការពង្រឹងតួនាទីរបស់ទិន្នន័យក្នុងមូលដ្ឋាននៅក្នុងការតាក់តែងគោលនយោបាយថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ផ្តោតលើការកសាងអភិបាលកិច្ចដែលចេះស្តាប់ រួមគ្នាធ្វើការសម្រេចចិត្តប្រកបដោយបរិយាបន្ន និងធានាថាគោលនយោបាយទាំងឡាយរបស់យើងឆ្លើយតបទៅនឹងបរិបទក្នុងមូលដ្ឋាន។

តាងនាមឱ្យខេត្តសៀមរាប ខ្ញុំសូមបញ្ជាក់ថា យើងស្វាគមន៍កិច្ចសហការជាមួយសហការីមកពីបណ្ដាខេត្តផ្សេងទៀត ហើយយើងពិតជាវាយតម្លៃខ្ពស់ចំពោះការរួមចំណែករបស់កម្មវិធីនានា ដូចជា កម្មវិធីពន្លកចំណេះ ដែលជួយតភ្ជាប់ចំណេះដឹងក្នុងមូលដ្ឋាន និងការពិភាក្សាប្រកបដោយបរិយាបន្នទៅនឹងការសម្រេចចិត្តលើគោលនយោបាយ។

ក្នុងវេទិកានាថ្ងៃនេះ ខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកទាំងអស់គ្នាចូលរួមដោយបើកចំហ ចែករំលែកបទពិសោធន៍ដោយស្មោះត្រង់  និងឆ្លុះបញ្ចាំងពីរបៀបដែលយើងអាចផ្សារភ្ជាប់ចំណេះដឹងក្នុងសហគមន៍ ទិន្នន័យថ្នាក់ខេត្ត និងការសម្រេចចិត្តលើគោលនយោបាយថ្នាក់ជាតិ ឱ្យកាន់តែប្រសើរឡើង។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលអូស្ត្រាលី អង្គការមូលនិធិអាស៊ី និងអ្នកចូលរួមទាំងអស់ដែលខិតខំជួយពង្រឹងដំណើរការគោលនយោបាយប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យនៅកម្ពុជា។



## កិច្ចពិភាក្សាពេញអង្គ១៖

# “ដំណោះស្រាយនៅមូលដ្ឋានដែលមានប្រសិទ្ធភាព៖ តើសហគមន៍ប្រែក្លាយទិន្នន័យ និងការចូលរួមទៅជាសកម្មភាពដោយរបៀបណា?”

*រៀបចំដោយ  ក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម*



# សារតារ

គោលនយោបាយដ៏រឹងមាំមួយ ត្រូវបានកើតឡើងចេញពីការស្តាប់មតិយោបល់ជុំវិញខ្លួន និងការពិចារណាបញ្ហាឱ្យបានគ្រប់ជ្រុងជ្រោយ។ ដើម្បីធានាថា គោលនយោបាយមួយអាចអនុវត្តទៅបានជោគជ័យ ប្រាកដណាស់ត្រូវរៀនសូត្រពីបទពិសោធន៍របស់ប្រជាពលរដ្ឋតាមសហគមន៍។ ការចែករំលែកដំណោះស្រាយនៅមូលដ្ឋាន និងការអនុវត្តល្អបំផុត ជួយឱ្យយើងយល់ពីអ្វីដែលអាចដំណើរការនៅក្នុងស្ថានភាពជាក់ស្តែង និងប្រើប្រាស់ចំណេះដឹងទាំងនោះ ដើម្បីតាក់តែងគោលនយោបាយ ដែលជាក់ស្តែង ពាក់ព័ន្ធ និងមានអត្ថប្រយោជន៍សម្រាប់គ្រប់គ្នា។

ទោះជាមានភាពចន្លោះប្រហោងក្នុងដំណើរការតាក់តែងគោលនយោបាយក៏ដោយ[៩] វានៅតែមានឱកាសដើម្បីកែលម្អ តាមរយៈការចូលរួមពីគំនិតផ្តួចផ្តើមនៅតាមមូលដ្ឋាន ដោយស្តាប់មតិយោបល់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ នៅពេលដែលសហគមន៍ រួមទាំងក្រុមងាយរងគ្រោះ បានចូលរួមក្នុងដំណើរការនេះ វានឹងជួយបង្កើតគោលនយោបាយដែលឆ្លុះបញ្ចាំងកាន់តែប្រសើរឆ្លើយតបតម្រូវការក្នុងមូលដ្ឋាន និងនាំទៅរកលទ្ធផលដែលកាន់តែមានប្រសិទ្ធភាពជាងមុន។ ដូច្នេះ ចាំបាច់ត្រូវចែករំលែកគំនិតផ្តួចផ្តើមទាំងនេះឱ្យបានទូលំទូលាយ។

កិច្ចពិភាក្សាពេញអង្គនេះ រៀបចំឡើងដើម្បីផ្តល់វេទិកាមួយសម្រាប់ឱ្យសហគមន៍មកជួបជុំគ្នា ចែករំលែកបទពិសោធន៍របស់ពួកគេ និងគូសបញ្ជាក់ពីការអនុវត្តល្អៗ ដែលមានប្រសិទ្ធភាពនៅក្នុងបរិបទរបស់ពួកគេ។ តាមរយៈការរៀនសូត្រពីគ្នាទៅវិញទៅមក យើងអាចពង្រឹងដំណោះស្រាយក្នុងមូលដ្ឋាន និងធានាបានថាគោលនយោបាយ និងសកម្មភាពពិតជាឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋយ៉ាងពិតប្រាកដមែន។ វាគ្មិននឹងចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនក្នុងការរួមចំណែកដល់ដំណោះស្រាយមូលដ្ឋាននៅក្នុងសហគមន៍របស់ពួកគេ ដោយប្រើប្រាស់វិធីសាស្ត្ររបស់ពួកគេផ្ទាល់ ដូចជា ការស្រាវជ្រាវ ការពិភាក្សា ការតស៊ូមតិ និងវិធីសាស្ត្រផ្សេងៗទៀត។

ការចែករំលែកទាំងនេះនឹងជួយបង្កើតនូវដំណោះស្រាយដែលមានលក្ខណៈអនុវត្តជាក់ស្តែង ប្រកបដោយបរិយាបន្ន និងមាននិរន្តរភាព។ ជាចុងក្រោយ កិច្ចពិភាក្សាពេញអង្គនេះគូសបញ្ជាក់ពីសារៈសំខាន់នៃវិធីសាស្ត្រដែលដឹកនាំដោយសហគមន៍ ជាទីដែលការផ្លាស់ប្តូរពិតប្រាកដចាប់ផ្តើមឡើងគឺជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយផ្ទាល់។

អាជ្ញាធរមូលដ្ឋាននឹងចែករំលែកឧទាហរណ៍នៃការអនុវត្តល្អនានា ក្នុងករណីដែលសហគមន៍របស់ពួកគេបានដោះស្រាយបញ្ហាប្រឈមក្នុងមូលដ្ឋានដោយជោគជ័យ។ បន្ថែមពីកិច្ចពិភាក្សាក្រុម អ្នកចូលរួមដើរទស្សនាបទបង្ហាញ។ ជំនួសឲ្យការធ្វើបទបង្ហាញ វាគ្មិនទាំងអស់បង្ហាញពីដំណោះស្រាយ និងគំនិតផ្តួចផ្តើមនានាដែលពួកគាត់បានអនុវត្តកន្លងមក។

វគ្គពិភាក្សានេះបន្សុីគ្នានឹងគោលបំណងរួមនៃវេទិកាគោលនយោបាយថ្នាក់ខេត្ត ដើម្បីនាំយកបទពិសោធន៍ថ្នាក់ខេត្តទៅបញ្ចូលក្នុងការពិភាក្សាគោលនយោបាយ និងបង្ហាញពីរបៀបដែលចំណេះដឹងក្នុងមូលដ្ឋានអាចផ្តល់ព័ត៌មានដល់ការតាក់តែងគោលនយោបាយ ដែលកាន់តែឆ្លើយតបនឹងតម្រូវការជាក់ស្តែង និងប្រកបដោយបរិយាបន្ន។

---

[៩] Yalirozy, T. (2025, September 9). *Cambodia Struggles to Build Research Capacity as Evidence-Based Policy Lags Behind*. Cambodianess. Cambodia Struggles to Build Research Capacity as Evidence-Based Policy Lags Behind | Cambodianess

## គោលបំណង

កិច្ចពិភាក្សាពេញអង្គស្តីពី "ដំណោះស្រាយនៅមូលដ្ឋានដែលមានប្រសិទ្ធភាព" មានគោលបំណងបង្ហាញឧទាហរណ៍ជាក់ស្តែងអំពីរបៀបដែលសហគមន៍ និងតួអង្គក្នុងមូលដ្ឋាន ឆ្លើយតបទៅនឹងបញ្ហាប្រឈមក្នុងមូលដ្ឋាន ដោយប្រើប្រាស់ទិន្នន័យ ការចូលរួម ការផ្សព្វផ្សាយនិងការពិភាក្សា។ វគ្គនេះព្យាយាមបង្ហាញពីវិធីផ្សេងៗដែលទិន្នន័យនៅមូលដ្ឋាន និងសំឡេងសហគមន៍ អាចយកទៅប្រើប្រាស់បាន និងជាទុនដល់ការធ្វើសេចក្តីសម្រេចចិត្ត ព្រមទាំងកំណត់នូវកត្តានានា និងរបាំងទូទៅ  ដែលរារាំងសកម្មភាពប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យ នៅកម្រិតមូលដ្ឋាន។ តាមរយៈការផ្តោតលើការប្រើប្រាស់ទិន្នន័យប្រកបដោយបរិយាបន្ន ការធានាការចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការស្រាវជ្រាវ ការចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធភាពជាមួយសហគមន៍ និងការធ្វើការពិភាក្សាប្រកបដោយបរិយាបន្ន វគ្គពិភាក្សានេះបានគូសបញ្ជាក់ពីវិធីសាស្ត្រអនុវត្តជាក់ស្តែងនានា ដែលជួយពង្រឹងដំណោះស្រាយដែលមាន មូលដ្ឋានច្បាស់លាស់ និងឆ្លើយតបនឹងតម្រូវការចំពោះមុខ។

## ការពិភាក្សា

ការពិភាក្សាបានគូសបញ្ជាក់ថា ការអភិវឌ្ឍសហគមន៍ប្រកបដោយបរិយាបន្ន និងមានប្រសិទ្ធភាព ត្រូវផ្អែកលើទិន្នន័យត្រឹមត្រូវ ការចូលរួមប្រកបដោយក្រមសីលធម៌ ទំនាក់ទំនងដែលអាចទទួលបានព័ត៌មាន និងការសន្ទនាដែលមានការចូលរួម ដោយមានការផ្តោតសំខាន់លើការដោះស្រាយតម្រូវការរបស់ក្រុមងាយរងគ្រោះ។ ក្នុងប្រធានបទទាំងបួន វាគ្មិន និងអ្នកចូលរួមបានចែករំលែកបទពិសោធន៍ និងវិធីសាស្ត្រជាក់ស្តែងដែលបង្ហាញថាតើវិធីសាស្ត្រប្រកបដោយបរិយាបន្ន អាចនាំទៅរកដំណោះស្រាយក្នុងមូលដ្ឋានដែលកាន់តែឆ្លើយតបនឹងតម្រូវការ និងមាននិរន្តរភាពដោយរបៀបណា។

ការប្រើប្រាស់ទិន្នន័យប្រកបដោយបរិយាបន្ន និងការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើទិន្នន័យ ដែលគាំទ្រដោយការចុះជួបផ្ទាល់ជាប្រចាំ និងការពិគ្រោះយោបល់ជាមួយសហគមន៍ គឺជារឿងចាំបាច់ដែលជួយឱ្យអាជ្ញាធរមូលដ្ឋានអាចកំណត់តម្រូវការពិតប្រាកដ និងអនុវត្តដំណោះស្រាយចំគោលដៅ។ ទិន្នន័យនៅមូលដ្ឋាន ដែលទាញចេញពីបទពិសោធន៍នៃការដោះស្រាយបញ្ហាគ្រោះរាំងស្ងួត ការបង្កើនលទ្ធភាពទទួលបានទឹកស្អាត និងការពង្រឹងភាពធន់នឹងអាកាសធាតុ បង្ហាញពីរបៀបដែលទិន្នន័យត្រឹមត្រូវ ជាពិសេសទិន្នន័យស្តីពីក្រុមងាយរងគ្រោះ  អាចផ្តល់ព័ត៌មានដោយផ្ទាល់ដល់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងការរៀបចំផែនការរយៈពេលវែង។ វាគ្មិនបានច្បាមយកបទពិសោធន៍ដ៏រឹងមាំនៅក្នុងការផ្តល់សេវាសាធារណៈ និងការចូលរួមរបស់សហគមន៍ ដែលគាំទ្រដោយការប្រមូលទិន្នន័យជាប្រព័ន្ធ និងការចូលរួមផ្ទាល់ជាមួយប្រជាពលរដ្ឋ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះផ្តល់ព័ត៌មានដល់ការរៀបចំផែនការដោយមានការសម្របសម្រួលជាមួយក្រុមប្រឹក្សាអ្នកពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់លើ។ ឧទាហរណ៍ជាក់ស្តែងរួមមានការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត នៅឆ្នាំ២០២២ ឆ្នាំ២០២៤ និងឆ្នាំ២០២៥ ដែលបានពង្រឹងភាពធន់នឹងអាកាសធាតុតាមរយៈហេដ្ឋារចនាសម្ព័ន្ធ ដូចជាស្រះសហគមន៍ និងការពង្រីកលទ្ធភាពទទួលបានទឹកស្អាត។ បន្ថែមលើនេះ ការអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានការចូលរួមប្រកបដោយបរិយាបន្ន ការសម្របសម្រួលយ៉ាងល្អ និងការដាក់បញ្ចូលតម្រូវការសហគមន៍ទៅក្នុងក្របខ័ណ្ឌផែនការផ្លូវការ រួមទាំងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការសកម្មភាពប្រចាំឆ្នាំ ជាដើម។



ការចូលរួមប្រកបដោយអត្ថន័យនៅក្នុងការស្រាវជ្រាវ ទាមទារលើសពីការចូលរួម មិនត្រឹមតែការប្រមូលទិន្នន័យ ដើម្បីធានានូវក្រមសីលធម៌ ទំនុកចិត្ត និងការគោរពចំពោះអ្នកចូលរួម។ ធាតុផ្សំសំខាន់ៗរួមមាន៖ ១) តម្លាភាពនៃគោលបំណង ការផ្តល់ហិរញ្ញប្បទាន និងការប្រើប្រាស់ទិន្នន័យ ២) ការយល់ព្រមដោយទទួលបានព័ត៌មានគ្រប់គ្រាន់ និងការការពារក្រមសីលធម៌ ៣) ភាពបត់បែន និងការគាំទ្រស្មារតីក្នុងពេលសម្ភាសន៍ ៤) ទីកន្លែងដែលមានសុវត្ថិភាព ឯកជនភាព និងគ្មានការរើសអើង និង ៥) ការតាមដាន និងការគោរពអនាមិកភាព រួមទាំងការផ្ទៀងផ្ទាត់ការរកឃើញ។ ការអនុវត្តបែបនេះធានាបានថា ការស្រាវជ្រាវឆ្លុះបញ្ចាំងពីសំឡេងសហគមន៍ពិតប្រាកដ និងរួមចំណែកបង្កើតបានជាលទ្ធផលដែលអាចជឿទុកចិត្តបាន និងមានផលជះ។ សរុបមក ដើម្បីធានាការចូលរួមប្រកបដោយអត្ថន័យ ត្រូវមានបទដ្ឋានក្រមសីលធម៌តឹងរ៉ឹង ការគោរពចំពោះអ្នកចូលរួម និងតម្លាភាពក្នុងការអនុវត្តការស្រាវជ្រាវ និងការចែករំលែកការរកឃើញ។

ទាក់ទងនឹងការចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធភាព ការទំនាក់ទំនងតាមរយៈបណ្តាញចម្រុះដែលងាយស្រួលទទួលបានព័ត៌មាន គឺជារឿងចាំបាច់ដើម្បីធានាថាមិនមាននរណាម្នាក់ត្រូវបានទុកចោល។ ការច្របាច់បញ្ចូលគ្នានូវវិធីសាស្ត្របែបប្រពៃណី ដូចជា ការប្រជុំសហគមន៍ ឧបករណ៍បំពងសំឡេង និងការចុះសួរសុខទុក្ខតាមខ្នងផ្ទះ ជាមួយនឹងវិធីសាស្ត្របែបឌីជីថល ដូចជា បណ្តាញសង្គម និងកម្មវិធីផ្ញើសារ ជួយឱ្យគ្របដណ្តប់ដល់ទស្សនិកជនបានកាន់តែច្រើន។ ទោះជាយ៉ាងណា ក៏នៅតែមានភាពចន្លោះប្រហោងសម្រាប់ជនមានពិការភាពធ្ងន់ធ្ងរ និងអ្នកដែលរស់នៅតំបន់ដាច់ស្រយាល ហើយនេះគូសបញ្ជាក់ពីតម្រូវការមធ្យោបាយទំនាក់ទំនងដែលកាន់តែមានបរិយាបន្ន និងយុទ្ធសាស្ត្រចុះផ្សព្វផ្សាយចំគោលដៅ។ វាគ្មិនម្នាក់គឺជាអ្នកខិតខំតស៊ូមតិជំរុញដល់ការទំនាក់ទំនងក្នុងសហគមន៍ ដែលអាចឱ្យជនមានពិការភាពទទួលបានព័ត៌មាន។

គាត់សង្កត់ធ្ងន់លើសារៈសំខាន់នៃការចែករំលែកព័ត៌មានអំពីសិទ្ធិស្របច្បាប់ កម្មវិធីរបស់រដ្ឋាភិបាល និងព័ត៌មានថ្មីៗអំពីគ្រោះមហន្តរាយ ហើយទន្ទឹមនឹងនោះ កត់សម្គាល់ឃើញថា អ្នកមានពិការភាពធ្ងន់ធ្ងរ ឬអ្នករស់នៅតំបន់ដាច់ស្រយាល ច្រើនតែត្រូវបានគេផាត់ចេញ។ ការកែលម្អការចុះផ្សព្វផ្សាយ និងប្រព័ន្ធនានា ដែលជួយពង្រីកសំឡេងរបស់ក្រុមងាយរងគ្រោះបំផុត រួមទាំងស្ត្រី កុមារ មនុស្សចាស់ និងសហគមន៍ជនជាតិដើមភាគតិច ដើម្បីធានាសមធម៌ក្នុងការទទួលបានព័ត៌មាន និងសេវា គឺជារឿងចាំបាច់ និងសំខាន់បំផុត។

ទាក់ទងនឹងការពិភាក្សាប្រកបដោយបរិយាបន្ន ល្វែនឆ្លុះបញ្ចាំងពីតថភាពសហគមន៍ និងវិធីសាស្ត្របែបច្នៃប្រឌិត ត្រូវបានបង្កើតឡើង ដើម្បីបង្កើនភាពអង់អាចដល់ក្រុមងាយរងគ្រោះ តាមរយៈការប្រែក្លាយបទពិសោធន៍ជាក់ស្តែងទៅជាការសម្តែង ដែលរំលេចបញ្ហាប្រឈម និងជំរុញឱ្យមានដំណោះស្រាយរួមគ្នា។ វិធីសាស្ត្រដែលមានការចូលរួមនេះ ជួយកសាងទំនុកចិត្ត លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ និងសេវា ព្រមទាំងផ្សារភ្ជាប់សហគមន៍ជាមួយអ្នកពាក់ព័ន្ធ ដើម្បីរួមគ្នាបង្កើតដំណោះស្រាយដែលអាចអនុវត្តបាន ដោយបញ្ជាក់សារជាថ្មីអំពីសារៈសំខាន់នៃទីកន្លែងដែលមានសុវត្ថិភាព និងបរិយាបន្ន សម្រាប់ការបញ្ចេញមតិ។ ការរក្សាការចូលរួមជាបន្តបន្ទាប់ ទាំងដោយផ្ទាល់ និងតាមអនឡាញ ធានាបានថា គ្រប់សំឡេងទាំងអស់ត្រូវបានគេស្តាប់ឮ និងប្រើប្រាស់ជាជំនួយដល់ការដោះស្រាយបញ្ហាប្រកបដោយសមធម៌ និងប្រសិទ្ធភាព។

ការពិភាក្សាជាក្រុម ក៏បានពង្រឹងប្រធានបទទាំងនេះបន្ថែមទៀតផងដែរ តាមរយៈការកំណត់រកការអនុវត្តដែលមានភាពបត់បែន កត្តាជោគជ័យ និងចំណុចត្រូវកែលម្អ។ ការអនុវត្តសំខាន់ៗរួមមានការកែលម្អការចាត់ប្រភេទទិន្នន័យ និងបញ្ជីឈ្មោះនៅថ្នាក់ភូមិ ការចុះសួរសុខទុក្ខដល់ខ្នងផ្ទះ ការអនុវត្តបទដ្ឋានក្រមសីលធម៌ក្នុងការស្រាវជ្រាវ និងការប្រើប្រាស់បណ្តាញទំនាក់ទំនងចម្រុះ។ កត្តាជោគជ័យ ផ្តោតលើការកសាងទំនុកចិត្ត កិច្ចសហការរឹងមាំ ការចូលរួមរបស់សហគមន៍ អ្នកសម្របសម្រួលប្រកបដោយជំនាញ និងធនធានគ្រប់គ្រាន់។

អ្នកចូលរួមក៏បានគូសបញ្ជាក់ពីភាពចន្លោះប្រហោងសំខាន់ៗផងដែរ រួមមានភាពចាំបាច់ក្នុងការបង្កើនលទ្ធភាពជាក់ស្តែង និងលទ្ធភាពទទួលបានព័ត៌មាន ការពង្រឹងសមត្ថភាពរបស់ស្ថាប័នមូលដ្ឋាន និងអ្នកសម្របសម្រួល ការធ្វើឱ្យគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល និងដៃគូកាន់តែបន្សីគ្នា និងការធានាឱ្យមានការតាមដាន និងការគាំទ្រជាប់រហូត។ បន្ថែមលើនេះ អ្នកចូលរួមបានសង្កត់ធ្ងន់ជាបន្តបន្ទាប់លើសារៈសំខាន់នៃកិច្ចសហការពីភាគីពាក់ព័ន្ធជាច្រើនរួមមាន អាជ្ញាធរ អង្គការសង្គមស៊ីវិល អង្គការតំណាងជនមានពិការភាព និងសមាជិកសហគមន៍។

សរុបមក ការពិភាក្សាបានគូសបញ្ជាក់ថា ទិន្នន័យប្រកបដោយបរិយាបន្ន ការអនុវត្តការស្រាវជ្រាវប្រកបដោយក្រមសីលធម៌ ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងការពិភាក្សាដែលមានការចូលរួម គឺជាសសរស្តម្ភដែលជួយពង្រឹងគ្នាទៅវិញទៅមកសម្រាប់ការអភិវឌ្ឍសហគមន៍។ ការពង្រឹងធាតុផ្សំទាំងនេះ តាមរយៈការបន្តសហការគ្នា ធនធានគ្រប់គ្រាន់ និងវិធីសាស្ត្របែបនវានុវត្តន៍ ដូចជា ឧបករណ៍ឌីជីថល និងវិធីសាស្ត្របែបច្នៃប្រឌិត គឺជាកត្តាចាំបាច់ដើម្បីធានាថា ដំណើរការអភិវឌ្ឍន៍នៅតែប្រកបដោយបរិយាបន្ន ឆ្លើយតបនឹងតម្រូវការ និងមាននិរន្តរភាព ដោយមិនទុកនរណាម្នាក់ចោលឡើយ។



## វាគ្មិន និងអ្នកសម្របសម្រួល

វាគ្មិន

**លោកស្រី ប៉ែន សោភា**
*មេឃុំស្វាយជុក ខេត្តកំពង់ឆ្នាំង*

**កញ្ញា គុំ សុម៉ាលី**
*មន្រ្តីគម្រោង និងជាសមាជិកបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ ( SheThinks Network )*
*រាជធានីភ្នំពេញ*

**កញ្ញា ជាតិ សុខា**
*អង្គការតំណាងជនមានពិការភាព នាយិកាមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម*
*អ្នកជំងឺរបេងសខួរឆ្អឹងខ្នង ខេត្តបាត់ដំបង*

**លោកស្រី នូវ ស្រីលាប**
*ប្រធានក្រុមសិល្បៈល្ខោនឆ្លុះ ខេត្តសៀមរាប*

អ្នកសម្របសម្រួល

**លោកស្រី ផេង ផារ៉ូហ៊ីន**
*អ្នកគ្រប់គ្រងកម្មវិធីយេនឌ័រ នៃអង្គការនារីដើម្បីសន្តិភាព*

អ្នកសហការ
សម្របសម្រួល

**កញ្ញា រឹមផាត បុប្ផាភួង**
*ប្រធានកម្មវិធីតស៊ូមតិ និងបណ្តាញ នៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា*

ចំណុចសំខាន់ទី ១

# ការប្រើប្រាស់ទិន្នន័យដើម្បីដោះស្រាយ បញ្ហាសហគមន៍ប្រកបដោយបរិយាបន្ន

លោកស្រី ប៉ែន សោភា បានចាប់ផ្តើមអាជីពរបស់គាត់នៅក្នុងឆ្នាំ២០០៩ ក្នុងនាមជាមន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារ ហើយលោកស្រីបានបម្រើការជាមេឃុំចាប់ពីឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន។ សមិទ្ធផលលេចធ្លោរបស់លោកស្រី រួមមានការផ្តល់សេវាសាធារណៈ និងការចុះសួរសុខទុក្ខសហគមន៍ ដើម្បីតាមដានសុខុមាលភាពរបស់ប្រជាពលរដ្ឋ ការលើកកម្ពស់ការអប់រំកុមារតូច ការបង្កើនលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យ ព្រមទាំងការសម្របសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ចំណុចសំខាន់ៗមួយចំនួនពីការពិភាក្សារបស់លោកស្រី មានដូចខាងក្រោម៖

- ក្នុងនាមតួនាទីជាមេឃុំ ខ្ញុំតែងតែប្រមូលទិន្នន័យ ស្តាប់បញ្ហាប្រឈមផ្សេងៗរបស់ពួកគេ និងស្វែងរកដំណោះស្រាយសម្រាប់សមាជិកសហគមន៍។ ជារឿយៗ ខ្ញុំចុះជួបផ្ទាល់ជាមួយពួកគេ។ បន្ទាប់ពីទទួលបានព័ត៌មានពីពួកគេ ខ្ញុំ និងក្រុមការងារ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធផ្សេងៗ រួមទាំងអង្គការដៃគូ និងវិស័យឯកជន។ បន្ថែមលើនេះ ខ្ញុំរៀបចំសំណើផ្លូវការដាក់ជូនថ្នាក់ស្រុក និងខេត្ត ដើម្បីស្នើសុំការគាំទ្រ និងអន្តរាគមន៍។

- ក្នុងករណីមានគ្រោះទឹកជំនន់ ឬគ្រោះរាំងស្ងួត ខ្ញុំតែងតែប្រមូលទិន្នន័យពីគ្រប់ភាគីពាក់ព័ន្ធ និងប្រជាពលរដ្ឋ ដោយផ្តោតជាពិសេសលើក្រុមងាយរងគ្រោះ គឺជនដែលមានពិការភាព មនុស្សចាស់ និងកុមារ។ ក្នុងស្ថានភាពបែបនេះ ខ្ញុំ និងក្រុមការងារ បានជម្លៀសពួកគេទៅកាន់ទីទួលមានសុវត្ថិភាព។ ពេលទៅដល់ទីនោះ យើងធានាថាតម្រូវការសំខាន់ៗត្រូវបានបំពេញ ដែលមានដូចជា អាហារ ទឹកស្អាត បង្គន់អនាម័យ និងសម្ភារចាំបាច់ផ្សេងៗទៀត។ បន្ថែមលើនេះ យើងបែងចែកថវិកាអភិវឌ្ឍន៍យ៉ាងប្រុងប្រយ័ត្ន និងធ្វើការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយក្រុមការងាររបស់យើង។

- ក្នុងអំឡុងឆ្នាំ២០២២ ឃុំរបស់ខ្ញុំបានប្រឈមនឹងគ្រោះរាំងស្ងួតយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលឱ្យមានការខ្វះខាតទឹក ទាំងសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ និងធារាសាស្ត្រ។ នៅពេលនោះ ថ្នាក់ដឹកនាំភូមិ និងខ្ញុំបានធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាករទឹក។ យើងបានដឹងថា ការផ្គត់ផ្គង់ទឹកនឹងមិនគ្រប់គ្រាន់ទេ ប្រសិនបើយើងព្យាយាមផ្គត់ផ្គង់ទឹកទៅឱ្យភូមិទាំង ១១ ក្នុងពេលតែមួយ។ ដូច្នេះ យើងបានរៀបចំកិច្ចប្រជុំ ដើម្បីពន្យល់ពីស្ថានភាពនេះដល់ប្រជាពលរដ្ឋ។ យើងបានផ្តល់ការផ្គត់ផ្គង់ទឹកដោយប្តូរវេនគ្នា គឺយើងផ្គត់ផ្គង់ទឹកឱ្យ ៤ ភូមិក្នុងមួយថ្ងៃ។ យើងក៏បានលើកទឹកចិត្តឱ្យប្រជាពលរដ្ឋបង្កើនសមត្ថភាពស្តុកទឹករបស់ពួកគេ និងបំពេញតម្រូវការបន្ថែមដោយការប្រើប្រាស់អណ្តូង។

- ក្នុងឆ្នាំ២០២៤ ដើម្បីឆ្លើយតបនឹងបញ្ហាអាកាសធាតុ យើងបានដាក់សំណើទៅគ្រប់លំដាប់ថ្នាក់ រួមទាំងមន្ទីរ  និងក្រសួងអភិវឌ្ឍន៍ជនបទផងដែរ។ ជាលទ្ធផល យើងអាចជីកស្រះសហគមន៍ ដើម្បីស្តុកទឹកទុកជាវិធានការបង្ការសម្រាប់ប្រជាពលរដ្ឋ ក្នុងពេលមានគ្រោះរាំងស្ងួតនាពេលខាងមុខ។

- ក្នុងឆ្នាំ២០២៥ ប្រតិបត្តិការរបស់យើងបន្តប្រព្រឹត្តទៅយ៉ាងរលូន។ រដ្ឋបាលឃុំ ក្រុមប្រឹក្សាឃុំ និងមេភូមិ បានជួបប្រជុំគ្នា ដើម្បីលើកជាសំណើដោយផ្អែកលើការចុះជួបផ្ទាល់របស់យើងជាមួយប្រជាពលរដ្ឋ។ គោលដៅរបស់យើងគឺដើម្បីធានាថា ប្រជាពលរដ្ឋគ្រប់រូបទទួលបានសេវាដោយស្មើភាពគ្នា។ ថ្មីៗនេះ យើងបានធ្វើការសម្របសម្រួលសម្រាប់ប្រជាជន ១៣៧ គ្រួសារ ដើម្បីធានាថា ប្រជាជនងាយរងគ្រោះអាចទទួលបានសេវាទឹកស្អាត។ ទោះបីថ្លៃតបណ្តាញទឹកគឺរហូតដល់ជាង ៣០ ម៉ឺនរៀលក៏ដោយ ប៉ុន្តែរដ្ឋបាលឃុំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលរវាងប្រជាពលរដ្ឋ  អង្គការមិនមែនរដ្ឋាភិបាល  និងរដ្ឋាករទឹក ដើម្បីធានានូវលទ្ធផលជោគជ័យ ។

- សរុបមក ដើម្បីដោះស្រាយបញ្ហាសហគមន៍ឱ្យទទួលបានជោគជ័យ យើងទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ដូចដែលបានរៀបរាប់ខាងលើ ចំណុចនេះពាក់ព័ន្ធនឹងការពិគ្រោះយោបល់រួមគ្នារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូ វិស័យឯកជន និងប្រជាពលរដ្ឋ ជាពិសេសក្រុមងាយរងគ្រោះ។ ដោយសារតែពួកគេគឺជាអ្នកដែលយល់ច្បាស់បំផុតអំពីបញ្ហាប្រឈមដែលពួកគេកំពុងជួបប្រទះ យើងទទួលយកសំណើ និងសំណូមពររបស់ពួកគេ ហើយបញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការសកម្មភាពប្រចាំឆ្នាំរបស់យើង។

## កិច្ចពិភាក្សាពេញអង្គ២៖

# “ការពិភាក្សាប្រកបដោយបរិយាបន្ន នៅក្នុងការអនុវត្តជាក់ស្ដែង”

*រៀបចំដោយ  ក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម*



## សារតារ

ផ្អែកលើភាពជោគជ័យនៃកម្មវិធីពន្លកចំណេះ ដំណាក់កាលទី១ (២០១៩-២០២៣) ដែលមានគោលបំណងពង្រឹងសមត្ថភាពស្ថាប័នវិស័យស្រាវជ្រាវនៅកម្ពុជា ក្នុងការបង្កើតការស្រាវជ្រាវដែលផ្តល់ព័ត៌មានដល់គោលនយោបាយសាធារណៈ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ (២០២៣-២០២៧) ខិតខំ ធានាឱ្យបានថា ការសម្រេចចិត្តទាំងនេះផ្អែកលើទិន្នន័យ និងការពិភាក្សាប្រកបដោយបរិយាបន្ន។ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ សង្កត់ធ្ងន់លើសារៈសំខាន់នៃការផ្តល់ព័ត៌មានប្រកបដោយគុណភាពខ្ពស់ដល់អ្នកតាក់តែងគោលនយោបាយនៅកម្ពុជា ដើម្បីគាំទ្រដល់ដំណើរការនេះ។ ជាចុងក្រោយ កម្មវិធីនេះមានបំណងទទួលបានការទទួលស្គាល់យ៉ាងទូលំទូលាយ និងការវាយតម្លៃខ្ពស់ក្នុងចំណោមអ្នកតាក់តែងគោលនយោបាយ និងអ្នកពាក់ព័ន្ធចំពោះការពិភាក្សាប្រកបដោយបរិយាបន្ន និងការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើទិន្នន័យ ដោយបង្កើតបានជាការអនុវត្តស្តង់ដារនៅកម្ពុជា។

កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ឱ្យនិយមន័យ "ការពិភាក្សា" ថាជាការផ្លាស់ប្តូរព័ត៌មាន គំនិត ឬមតិរវាងភាគីពាក់ព័ន្ធ តាមរយៈពាក្យសម្តី ឬសំណេរ។ គោលដៅរបស់កម្មវិធីនេះ អាចរាប់ចាប់ពីការយោគយល់គ្នាទៅវិញទៅមក រហូតដល់ការស្វែងយល់ពីប្រធានបទផ្សេងៗ។ កម្មវិធីនេះមានភាពបត់បែន និងមានប្រយោជន៍សម្រាប់ការបញ្ជាក់ឱ្យបានច្បាស់ ការរៀនសូត្រ ឬការកសាងទំនាក់ទំនង។ ក្នុងបរិបទគោលនយោបាយ  ការពិភាក្សាសំដៅលើការសន្ទនា ឬការពិភាក្សាដែលមានការរៀបចំត្រឹមត្រូវ និងគោលបំណងច្បាស់លាស់ក្នុងចំណោមអ្នកពាក់ព័ន្ធផ្សេងៗ រួមមាន មន្ត្រីរដ្ឋាភិបាល អ្នកជំនាញ អ្នកស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសាធារណជន ដើម្បីចែករំលែកចំណេះដឹង រិះរកវិធីដោះស្រាយបញ្ហាគោលនយោបាយ ឬឱកាសជាក់លាក់ និងចុងក្រោយ ផ្តល់ព័ត៌មានដល់ការបង្កើត ការអនុវត្ត ឬការកែសម្រួលគោលនយោបាយ និងគំនិតផ្តួចផ្តើមនានា។ ទោះជាយ៉ាងណា មិនមែនគ្រប់ការពិភាក្សាទាំងអស់សុទ្ធតែមានការចូលរួមប្រកបដោយអត្ថន័យពីគ្រប់ភាគីពាក់ព័ន្ធនោះទេ។ នេះជាចំណុចដែលត្រូវមានការពិភាក្សាប្រកបដោយបរិយាបន្ន។

ក្នុងបរិបទនៃកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ "ការពិភាក្សាប្រកបដោយបរិយាបន្ន"  ពាក់ព័ន្ធនឹងការជំរុញការសន្ទនាបែបបើកទូលាយ និងមានការចូលរួម ក្នុងចំណោមអ្នកពាក់ព័ន្ធចម្រុះ រួមមាន ស្ត្រី ជនមានពិការភាព ជនជាតិភាគតិច អ្នកស្រឡាញ់ភេទដូចគ្នា និងក្រុមផ្សេងទៀតដែលមានតំណាងតិចតួច។ "ការពិភាក្សាប្រកបដោយបរិយាបន្ន" មានគោលបំណងធានាថា គ្រប់សំឡេងទាំងអស់ត្រូវបានគេស្តាប់ឮ គោរព និងអាចរួមចំណែកយ៉ាងសកម្មដល់ការពិភាក្សាគោលនយោបាយ។ "ការពិភាក្សាប្រកបដោយបរិយាបន្ន"  លើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តរួមគ្នា   និងជំរុញឱ្យមានការដាក់បញ្ចូលទស្សនៈចម្រុះទៅក្នុងដំណើរការគោលនយោបាយ។

ដោយទទួលស្គាល់សារៈសំខាន់នៃការពិភាក្សាប្រកបដោយបរិយាបន្ន កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ បានផ្តួចផ្តើមបង្កើត "គោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន"[២] ជាមួយដៃគូរបស់ខ្លួន រួមមានដៃគូយុទ្ធសាស្ត្រ[៣] និងក្រុមជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម[៤] ដើម្បីផ្តល់នូវជំហាន និងវិធីសាស្ត្រជាក់ស្តែង និងច្បាស់លាស់សម្រាប់លើកកម្ពស់ការពិភាក្សាបែបនេះ។

នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ "គោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន" ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ក្នុងអំឡុងវេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះ។[៥] គោលការណ៍ណែនាំទាំងនេះ មានគោលបំណងជួយភាគីពាក់ព័ន្ធក្នុងការបង្កើត និងសម្របសម្រួលការសន្ទនា ដែលមិនត្រឹមតែមានបរិយាបន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់លទ្ធផលផ្លែផ្កាទៀតផង តាមរយៈការធានាថា តម្រូវការផ្សេងៗ និងការយល់ដឹងរបស់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ គោលដៅគឺដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តរួមគ្នា និងការរួមបញ្ចូលទស្សនៈចម្រុះទៅក្នុងដំណើរការគោលនយោបាយ ដែលនឹងជួយលើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធជារួមនៃគោលនយោបាយសាធារណៈនៅកម្ពុជា។

## គោលបំណង

ការពិភាក្សាមានគោលបំណងជំរុញការយល់ដឹងកាន់តែស៊ីជម្រៅ ស្តីពីការពិភាក្សាប្រកបដោយបរិយាបន្ន ទាំងក្នុងនាមជាគោលការណ៍ផង និងជាវិធីសាស្ត្រអនុវត្តជាក់ស្តែងផង នៅក្នុងការស្រាវជ្រាវ ការតាក់តែងគោលនយោបាយ និងការអភិវឌ្ឍសហគមន៍។ វគ្គនេះព្យាយាមបញ្ជាក់ឱ្យកាន់តែច្បាស់អំពីរបៀបដែលគេអាចអនុវត្តការពិភាក្សាប្រកបដោយបរិយាបន្ន ដែលផ្អែកលើភាពជាម្ចាស់ ការបង្កលក្ខណៈងាយស្រួល ការគោរពភាពចម្រុះ និងសមធម៌ នៅទូទាំងដំណើរការទាំងមូលនៃការស្រាវជ្រាវ និងគោលនយោបាយ ចាប់តាំងពីការកំណត់រកបញ្ហា និងការប្រមូលទិន្នន័យ រហូតដល់ការវិភាគ ការផ្សព្វផ្សាយ និងការធ្វើសេចក្តីសម្រេចចិត្ត។ ការពិភាក្សាក៏មានគោលបំណងលើកកម្ពស់ការអនុវត្តផ្អែកលើសិទ្ធិ និងក្រមសីលធម៌ផងដែរ រួមទាំងការយល់ព្រមដោយទទួលបានព័ត៌មានគ្រប់គ្រាន់ ការរក្សាការសម្ងាត់ និងការចូលរួមប្រកបដោយអត្ថន័យពីសំណាក់ក្រុមដែលមានតំណាងតិចតួច ដូចជា ស្ត្រី ជនមានពិការភាព ជនជាតិដើមភាគតិច និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ មួយវិញទៀត វគ្គនេះមានគោលបំណងណែនាំ និងដាក់ឱ្យអនុវត្ត "គោលការណ៍ណែនាំសម្រាប់ការពិភាក្សា

---

[២] គោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន៖ https://policypulse.org/publications/references/guidelines-for-inclusive-dialogue/

[៣] ដៃគូយុទ្ធសាស្ត្រ រួមមានវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (អតីតដៃគូយុទ្ធសាស្ត្រ) មជ្ឈមណ្ឌលខេមរសិក្សា មជ្ឈមណ្ឌលសិក្សាគោលនយោបាយ និងវេទិកាអនាគត https://policypulse.org/ponlok-chomnes/strategic-partners/

[៤] ក្រុមជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម៖ https://policypulse.org/ponlok-chomnes/gedsi-consortium/

[៥] ចំណុចសំខាន់ៗពីវេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៥៖ https://policypulse.org/events/policy-forum/highlights-from-the-ponlok-chomnes-national-policy-forum-2025/

ប្រកបដោយបរិយាបន្ន” ជាឧបករណ៍ជាក់ស្តែងសម្រាប់ការធ្វើផែនការ ការរៀបចំចំវិកា និងការសម្របសម្រួល ដោយគូសបញ្ជាក់ថាតើការរៀបចំដែលបង្កលក្ខណៈងាយស្រួល ការរៀបចំថវិកាប្រកបដោយបរិយាបន្ន និងការពង្រឹងសមត្ថភាពជាប្រចាំ អាចជួយផ្លាស់ប្តូរទំនាក់ទំនងអំណាច លុបបំបាត់របាំងរារាំងការចូលរួម និងធានាថា សំឡេងចម្រុះពិតជាមានឥទ្ធិពលលើគោលនយោបាយ និងលទ្ធផលនៃការអភិវឌ្ឍដោយរបៀបណា។

## ការពិភាក្សា

វគ្គនេះផ្តោតលើទស្សនទាន និងការអនុវត្តការពិភាក្សាប្រកបដោយបរិយាបន្ន ជាពិសេសនៅក្នុងការស្រាវជ្រាវ ការតាក់តែងគោលនយោបាយ និងការអភិវឌ្ឍសហគមន៍ ដោយមានការណែនាំពីកម្មវិធីពន្លកចំណេះ។ ការពិភាក្សាប្រកបដោយបរិយាបន្ន ត្រូវបានកំណត់ដោយផ្អែកលើសសរស្តម្ភសំខាន់ៗបួន គឺភាពជាម្ចាស់ ការបង្កលក្ខណៈងាយស្រួល ការគោរពភាពចម្រុះ និងសមធម៌ ដោយធានាថា បុគ្គលគ្រប់រូប ជាពិសេសក្រុមដែលមានតំណាងតិចតួច ដូចជា ស្ត្រី ជនមានពិការភាព ជនជាតិដើមភាគតិច និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានទទួលស្គាល់ និងបង្កើនភាពអង់អាច ដើម្បីចូលរួមប្រកបដោយអត្ថន័យ។

វាគ្មិនបានគូសបញ្ជាក់ថា ការពិភាក្សាប្រកបដោយបរិយាបន្នគឺជាកត្តាសំខាន់នៅក្នុងដំណើរការស្រាវជ្រាវទាំងមូល ចាប់តាំងពីការកំណត់ប្រធានបទ និងការប្រមូលទិន្នន័យ រហូតដល់ការផ្សព្វផ្សាយការរកឃើញ ដោយសង្កត់ធ្ងន់លើបទដ្ឋានក្រមសីលធម៌ ការយល់ព្រមដោយទទួលបានព័ត៌មានគ្រប់គ្រាន់ ការរក្សាការសម្ងាត់ និងការគោរពសិទ្ធិ និងទស្សនៈរបស់អ្នកចូលរួម។

ការពិភាក្សាប្រកបដោយបរិយាបន្ននៅក្នុងការស្រាវជ្រាវ រួមបញ្ចូលទស្សនៈ សំឡេង និងចំណេះដឹងចម្រុះ នៅគ្រប់ដំណាក់កាលទាំងអស់នៃការស្រាវជ្រាវ រួមទាំងការកំណត់ប្រធានបទ ការប្រមូល និងវិភាគទិន្នន័យ សមាសភាពក្រុមស្រាវជ្រាវ និងការផ្សព្វផ្សាយការរកឃើញ។ ការពិភាក្សាប្រកបដោយបរិយាបន្នសង្កត់ធ្ងន់លើការគោរពភាពចម្រុះ និងការបង្កើនភាពអង់អាចដល់ក្រុមដែលមានតំណាងតិចតួច ដូចជា ស្ត្រី ជនមានពិការភាព ជនជាតិដើមភាគតិច និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ ការរកឃើញត្រូវតែឆ្លុះបញ្ចាំងពីតថភាពពិតប្រាកដរបស់អ្នកចូលរួម និងទទួលយកមតិស្ថាបនា ដើម្បីធានាថា អនុសាសន៍គោលនយោបាយឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ចំណុចស្នូលនៃវិធីសាស្ត្រនេះ គឺជាគោលការណ៍ "គ្មានអ្វីសម្រាប់យើង ដោយពុំមានការចូលរួមពីយើង” ដែលគូសបញ្ជាក់ពីសារៈសំខាន់នៃការរួមបញ្ចូលក្រុមអត្តសញ្ញាណទាំងអស់នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការពិគ្រោះយោបល់។



ការពិភាក្សាប្រកបដោយបរិយាបន្ននៅក្នុងការតាក់តែងគោលនយោបាយ ផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងអត្ថន័យ។ តាមរយៈកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ដែលទទួលបានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី អង្គការមូលនិធិអាស៊ីបានសង្កត់ធ្ងន់លើការបញ្ជ្រាបបរិយាបន្នទៅក្នុងសកម្មភាពទាំងអស់នៅដំណាក់កាលនេះ។ កម្មវិធីនេះខិតខំលើកទឹកចិត្តឱ្យដៃគូ និងស្ថាប័នពាក់ព័ន្ធដាក់បញ្ចូលការអនុវត្តប្រកបដោយបរិយាបន្នទៅក្នុងការស្រាវជ្រាវ និងការពិភាក្សារបស់ពួកគេ។ ដោយទទួលស្គាល់ថា ការជំរុញលើកទឹកចិត្តតែមួយមុខគឺមិនទាន់គ្រប់គ្រាន់ គំនិតផ្តួចផ្តើមនេះក៏ផ្តោតអាទិភាពផងដែរលើការចងក្រងឯកសារ និងសៀវភៅណែនាំផ្លូវការ ដើម្បីធានាថា បរិយាបន្នត្រូវបានអនុវត្តជាប្រព័ន្ធ និងដំណើរការយ៉ាងរលូន។



ដូច្នេះ ការពិភាក្សាបានស្វែងយល់បន្ថែមទៀតនូវ "គោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន" ដែលបង្កើតឡើងដោយក្រុមការងារឯកទេសរួមបញ្ចូលទាំង ក្រុមជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ គោលការណ៍ណែនាំនេះ រៀបរាប់អំពីគោលការណ៍ស្នូលចំនួនប្រាំ គឺ គោលការណ៍មិនបង្កគ្រោះថ្នាក់ គោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម គោលការណ៍ហ្វែមីនីស្ត គោលការណ៍អន្តរប្រសព្វ និងគោលការណ៍សិទ្ធិមនុស្ស ដោយផ្តោតលើការអនុវត្តជាក់ស្តែងជាចម្បងលើ "**គោលការណ៍មិនបង្កគ្រោះថ្នាក់**" និង "**គោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម**" ។

អ្នកស្រាវជ្រាវ និងអ្នកអនុវត្តការងារអភិវឌ្ឍន៍គួរប្រើប្រាស់គោលការណ៍ណែនាំទាំងនេះ ដើម្បីរៀបចំផែនការវាយតម្លៃ និងបន្តកែលម្អបរិយាបន្ននៃការពិភាក្សារបស់ពួកគេ រួមទាំងការពិចារណាលើការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព អ្នកថែទាំ និងក្រុមងាយរងគ្រោះដទៃទៀត។ ឧបករណ៍ដូចជា បញ្ជីត្រួតពិនិត្យការវាយតម្លៃ និងកម្រិតនៃការចូលរួម អាចឱ្យអ្នករៀបចំវាស់ស្ទង់បរិយាបន្ន ដើម្បីជំរុញឱ្យមានការចូលរួមប្រកបដោយអត្ថន័យ ពោលគឺអ្នកចូលរួមម្នាក់ៗសុទ្ធតែបានរួមចំណែក ចាប់តាំងពីការកំណត់រកបញ្ហា រហូតដល់ការធ្វើសេចក្តីសម្រេចចិត្តចុងក្រោយ។

ការពិភាក្សាប្រកបដោយបរិយាបន្ន គឺមានវិសាលភាពមិនត្រឹមតែការចូលរួមប៉ុណ្ណោះទេ តែគ្របដណ្តប់ហូតដល់ការរៀបចំថវិកា ដែលជួយលុបបំបាត់របាំងរារាំងនានាសម្រាប់ក្រុមដែលមានតំណាងតិចតួច។ ក្នុងនោះដែរ សំដៅលើការរៀបចំផែនការថវិកាជាមុន ដើម្បីធានាការបង្កលក្ខណៈងាយស្រួលដូចជាការកក់ទីតាំងដែលមានជម្រាល ជណ្តើរយន្ត និងបន្ទប់ទឹកធំទូលាយសម្រាប់ជនមានពិការភាព ការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមលើថ្លៃធ្វើដំណើរ និងការសម្រួលដល់អ្នកចូលរួមដែលមកពីតំបន់ដាច់ស្រយាល។ ការពិភាក្សាប្រកបដោយបរិយាបន្នក៏រួមបញ្ចូលទាំងការផ្តល់ជូនអ្នកបកប្រែភាសាសញ្ញា ឯកសារបកប្រែជាអក្សរស្ទាប ឬអក្សរផុស (Braille) សេវាបកប្រែ និងសូម្បីតែការពិចារណាផ្នែកភស្តុភារដូចជាការគោរពពេលវេលារបស់អ្នកចូលរួមមួយចំនួន រួមទាំងព្រះសង្ឃផងដែរ។

បន្ថែមលើ "គោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន" និងដើម្បីសម្រួលដល់ការអនុវត្តជាក់ស្តែង កម្មវិធីពន្លកចំណេះបានបោះពុម្ពខិត្តប័ណ្ណសង្ខេបចំនួន ៨ទំព័រ បង្ហាញជាជំហានៗសម្រាប់ការធ្វើផែនការ ការគ្រោងថវិកា និងការរៀបចំសកម្មភាពប្រកបដោយបរិយាបន្ន។ ក្រុមការងារ និងដៃគូកម្មវិធី បានទទួលការបណ្តុះបណ្តាល និងមានផែនការបន្ត ដើម្បីពង្រីកការកសាងសមត្ថភាពដល់អង្គការសង្គមស៊ីវិល គ្រឹះស្ថានអប់រំ និងអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

វាគ្មិនបានសង្កត់ធ្ងន់ថា បរិយាបន្នពាក់ព័ន្ធនឹងការសម្រេចបានការផ្លាស់ប្តូរប្រកបដោយអត្ថន័យនូវទំនាក់ទំនងអំណាច ការធានាលទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានធនធាន និងការជំរុញឱ្យមានការចូលរួមពិតប្រាកដនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ សៀវភៅព័ត៌មាននេះ និងឧបករណ៍ដែលអមមកជាមួយ គឺសម្រាប់ឱ្យអ្នកស្រាវជ្រាវ អ្នកអនុវត្តការងារអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ ឆ្លុះបញ្ចាំងយ៉ាងល្អិតល្អន់ថាតើការពិភាក្សា ការប្រមូលទិន្នន័យ និងសកម្មភាពរបស់ពួកគេ ពិតជាបន្សុីគ្នានឹងគោលការណ៍បរិយាបន្ន ឬទេ។ នេះគឺដើម្បីធានាថា សំឡេងទាំងអស់ត្រូវបានបន្លឺឡើង និងជំរុញភាពអង់អាច។

> ចុងបញ្ចប់ វាគ្មិនបានអះអាងពីសារៈសំខាន់នៃការលើកកម្ពស់ ការបណ្តុះបណ្តាល និងការអនុវត្តគោលការណ៍ទាំងនេះជាបន្តបន្ទាប់នៅក្នុងការស្រាវជ្រាវ ការតាក់តែងគោលនយោបាយ និងគំនិតផ្តួចផ្តើមតាមសហគមន៍។ ធនធានពីកម្មវិធីពន្លកចំណេះជាពិសេស "គោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន" ដើរតួជាឧបករណ៍ជាក់ស្តែងសម្រាប់អ្នកស្រាវជ្រាវ អង្គការសង្គមស៊ីវិល ស្ថាប័ន និងអ្នកតាក់តែងគោលនយោបាយ ដោយបញ្ជាក់ច្បាស់ថា ការពិភាក្សាប្រកបដោយបរិយាបន្ន មិនមែនគ្រាន់តែជានីតិវិធីនោះទេ ប៉ុន្តែជាមធ្យោបាយដើម្បីធានាភាពជាតំណាងប្រកបដោយអត្ថន័យ លទ្ធភាពទទួលបាន ប្រកបដោយសមធម៌ និងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តពិតប្រាកដសម្រាប់ក្រុមដែលមានតំណាងតិចតួច។



# វាគ្មិន និងអ្នកសម្របសម្រួល

វាគ្មិន

**កញ្ញា ជ័យ ម៉ារ៉ាមី**
*មន្ត្រីជាន់ខ្ពស់កម្មវិធី មកពីកម្មវិធីពន្លកចំណេះនៃអង្គការមូលនិធិអាស៊ី*

**លោក មាន វិបុលរតនៈ**
*អ្នកសម្របសម្រួលគម្រោង និងជាគ្រូបង្គោលផ្នែកបរិយាបន្នពិការភាព នៃអង្គការជនពិការកម្ពុជា*

**កញ្ញា ផាំង ម៉ារ៉ុង**
*អតីតសមាជិកក្រុមការងាររៀបចំគោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន នៃកម្មវិធីពន្លកចំណេះ*

អ្នកសម្របសម្រួល

**លោកស្រី អេង ចាន់ឌី**
*នាយិកាប្រតិបត្តិនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា*

ចំណុចសំខាន់ទី ២

# ការចូលរួមដ៏មានអត្ថន័យក្នុងដំណើរការស្រាវជ្រាវ

កញ្ញា គុំ សុម៉ាលី គឺជាអ្នកសម្របសម្រួលគម្រោងនៅអង្គការយុវសន្តិភាព និងជាសមាជិកនៃបណ្តាញស្ត្រីនៅក្នុងវិស័យស្រាវជ្រាវ (SheThinks Network)។ កញ្ញាបានធ្វើការក្នុងវិស័យសិទ្ធិមនុស្ស យុត្តិធម៌ និងរដ្ឋបាល តាំងពីឆ្នាំ២០១០ មក។ កញ្ញាទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិទ្ធិមនុស្ស និងប្រជាធិបតេយ្យពីក្របខ័ណ្ឌ European University Global Campus។

ខ្ញុំបានចូលរួមក្នុងការសម្ភាសន៍ជាច្រើន ទាំងក្នុងនាមជាអ្នកស្រាវជ្រាវ និងជាអ្នកផ្តល់បទសម្ភាសន៍លើប្រធានបទ ដូចជា យេនឌ័រ (ផ្តោតលើស្ត្រីក្នុងវិស័យច្បាប់ និងការអប់រំ) និងការរើសអើងពណ៌សម្បុរនៅក្នុងសហគមន៍។ បន្ថែមលើនេះ ការងាររបស់ខ្ញុំភាគច្រើនពាក់ព័ន្ធនឹងយុត្តិធម៌អន្តរកាល។ ក្នុងនោះ ការរួមចំណែករបស់ខ្ញុំផ្តោតលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសាលាក្តីខ្មែរក្រហម ការអប់រំប្រវត្តិសាស្ត្រ និងការកសាងសន្តិភាព។ ក្នុងចំណោមគម្រោងទាំងអស់នេះ មានគម្រោងពីរដែលខ្ញុំពេញចិត្តបំផុត។ គម្រោងទីមួយគឺការសិក្សាអំពីការរើសអើងពណ៌សម្បុរនៅកម្ពុជា ដែលមានការចូលរួមពីស្ត្រីដែលធ្លាប់ទទួលរងការរើសអើង និងគម្រោងទីពីរគឺការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសាលាក្តីខ្មែរក្រហម។

ហេតុអ្វីបានជាខ្ញុំចាត់ទុកការចូលរួមរបស់ខ្ញុំនៅក្នុងគម្រោងទាំងពីរនេះ ថាមានអត្ថន័យពិតប្រាកដ? នោះគឺដោយសារចំណុចសំខាន់ៗ ៥៖

១

**តម្លាភាព ៖**

នៅពេលអ្នកស្រាវជ្រាវទាក់ទងមកខ្ញុំ ពួកគេបានផ្តល់ព័ត៌មានច្បាស់លាស់អំពីគម្រោង។ ពួកគេបានពន្យល់ពីប្រភពមូលនិធិ របៀបដែលការសម្ភាសន៍នឹងត្រូវបានប្រើប្រាស់ និងអ្វីដែលពួកគេពិតជាត្រូវការពីខ្ញុំ។

២

**ការយល់ព្រមដោយទទួលបានព័ត៌មានគ្រប់គ្រាន់ និងក្រមសីលធម៌៖**

ពួកគេបានរៀបរាប់យ៉ាងច្បាស់អំពីសិទ្ធិរបស់ខ្ញុំ រួមទាំងការស្នើសុំការអនុញ្ញាតដើម្បីថតសំឡេង និងការប្រើប្រាស់ទម្រង់ផ្តល់ការយល់ព្រម។ ពួកគេបានបញ្ជាក់ថាខ្សែអាត់សំឡេងនឹងត្រូវបានប្រើប្រាស់សម្រាប់ការកត់ត្រា ហើយបន្ទាប់មក នឹងត្រូវលុបចោលវិញនៅពេលរបាយការណ៍ត្រូវបានបញ្ចប់។ នេះបង្ហាញពីក្រមសីលធម៌យ៉ាងពិតប្រាកដ។

៣

**ភាពបត់បែន និងការគាំទ្រ៖**

ក្នុងអំឡុងពេលសម្ភាសន៍ ពួកគេបានប្រាប់ខ្ញុំថា ខ្ញុំអាចរំលងសំណួរណាមួយដែលខ្ញុំមិនចង់ឆ្លើយ ឬឈប់សម្រាក នៅពេលណាដែលចាំបាច់។ នៅពេលពិភាក្សាអំពីប្រធានបទរសើប ឬគួរឱ្យតក់ស្លុត ពួកគេបានផ្តល់ការគាំទ្រផ្នែកស្មារតី និងការលើកទឹកចិត្ត។

៤

**បរិយាកាសសុវត្ថិភាព៖**

ការសម្ភាសន៍បានប្រព្រឹត្តទៅក្នុងបរិយាកាសស្ងប់ស្ងាត់ ដោយគ្មានការរំខានពីភាគីទីបី។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំអាចបញ្ចេញមតិដោយសេរី ព្រោះអ្នកស្រាវជ្រាវមិនបានវិនិច្ឆ័យថាអ្វីដែលខ្ញុំនិយាយនោះ 'ត្រូវ' ឬ 'ខុស' ឡើយ។

៥

**ការតាមដាន និងអនាមិកភាព៖**

បន្ទាប់ពីការវិភាគទិន្នន័យ ពួកគេបានទាក់ទងមកខ្ញុំម្តងទៀត ដើម្បីសួរថាតើខ្ញុំចង់ប្រើឈ្មោះពិត ឬរក្សាអនាមិកភាពនៅក្នុងរបាយការណ៍។ ពួកគេថែមទាំងបានផ្ញើរបាយការណ៍មកឱ្យខ្ញុំពិនិត្យ មុនពេលបោះពុម្ពផ្សាយជាផ្លូវការទៀតផង។

សរុបមក ការចូលរួមប្រកបដោយអត្ថន័យ អាស្រ័យលើអ្នកស្រាវជ្រាវដែលមានក្រមសីលធម៌ច្បាស់លាស់ ផ្តល់តម្លៃដល់អ្នកផ្តល់ព័ត៌មាន ផ្តល់ការគាំទ្រផ្នែកស្មារតី និងការជូនដំណឹងដល់ពួកយើងថាតើការស្រាវជ្រាវនឹងត្រូវបានបោះពុម្ពផ្សាយនៅទីណា ឬនៅលើវេទិកាណា។

## ការពិភាក្សាស្របពេលគ្នា ១ក៖

# “ការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមរយៈកម្មវិធីផ្ទេរសាច់ប្រាក់នៅកម្ពុជា”

*រៀបចំដោយ វិទ្យាស្ថានជាតិសង្គមកិច្ច*



# សារតារ

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសឱ្យប្រើប្រាស់ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្លើយតបនឹងគ្រោះមហន្តរាយ ឆ្នាំ២០២៥-២០៣០។ ក្របខ័ណ្ឌនេះមានគោលបំណងពង្រឹងយន្តការនានា ដើម្បីការពារ និងគាំទ្រដល់ប្រជាជនងាយរងគ្រោះបំផុត ជាពិសេសក្នុងពេលមានវិបត្តិ និងគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ។ ក្របខ័ណ្ឌគាំពារសង្គមរបស់កម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ប្រជាជនងាយរងគ្រោះ និងកសាងភាពធន់ទៅនឹងហានិភ័យដែលទាក់ទងនឹងអាកាសធាតុ តាមរយៈការផ្តល់ជំនួយចំគោលដៅ កម្មវិធីសន្តិសុខសង្គម និងវិធានការបន្សាំនឹងអាកាសធាតុ។

ទាក់ទងនឹងកិច្ចគាំពារសង្គម និងការឆ្លើយតបបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា រាជរដ្ឋាភិបាលបានសង្កត់ធ្ងន់លើសាមគ្គីភាពសង្គម និងការឆ្លើយតបយ៉ាងលឿនរហ័សក្នុងពេលមានវិបត្តិ ជាពិសេសសម្រាប់ប្រជាជនងាយរងគ្រោះ ដែលរងផលប៉ះពាល់ដោយគ្រោះអាសន្ន និងគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ។ ប្រព័ន្ធគាំពារសង្គមរបស់កម្ពុជាមានសមាសធាតុស្នូលពីរ គឺសន្តិសុខសង្គម និងជំនួយសង្គម ដែលផ្តល់ការគាំទ្រទាន់ពេលវេលាតាមរយៈយន្តការនានា ដូចជា ការឧបត្ថម្ភសាច់ប្រាក់ក្នុងពេលមានគ្រោះអាសន្ន និងការផ្តល់ជំនួយចំគោលដៅដល់កុមារ ស្ត្រី មនុស្សចាស់ និងក្រុមងាយរងគ្រោះដទៃទៀត។ ក្នុងពេលមានគ្រោះទឹកជំនន់ និងគ្រោះមហន្តរាយស្រដៀងគ្នានេះ រាជរដ្ឋាភិបាលផ្តោតអាទិភាពលើការផ្តល់ជំនួយដល់កុមារ និងស្ត្រី រួមទាំងស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោមពីរឆ្នាំ។ សុខភាពមាតា និងទារក ទទួលបានការយកចិត្តទុកដាក់ជាពិសេស តាមរយៈការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការពិនិត្យផ្ទៃពោះ និងការរ៉ាប់រងពេញលេញលើតម្រូវការវេជ្ជសាស្ត្រ។ របបសន្តិសុខសង្គមត្រូវបានពង្រីកឱ្យគ្របដណ្តប់ដល់កម្មករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ខណៈដែលជំនួយសង្គមជួយគ្រួសារឱ្យចៀសផុតពីភាពក្រីក្រធ្ងន់ធ្ងរដោយសារហានិភ័យការងារ ឬវិបត្តិគ្រួសារ។ កម្មវិធីគាំពារសង្គម ត្រូវបានធ្វើសមាហរណកម្មយ៉ាងជិតស្និទ្ធជាមួយនឹងវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងទប់ស្កាត់ភាពក្រីក្រដែលបណ្តាលមកពីអាកាសធាតុ។

គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ មូលនិធិជាតិជំនួយសង្គម បានគ្របដណ្តប់ដល់ប្រជាជនជាង ៧២៥.០០០ គ្រួសារ បានផ្តល់ការគាំទ្រដល់មនុស្សចាស់ចំនួន ៤៣៩.៤៩២ នាក់ និងបានឧបត្ថម្ភសាច់ប្រាក់យ៉ាងច្រើនដល់មាតា កុមារ និងក្រុមងាយរងគ្រោះផ្សេងទៀត។ នៅកម្រិតអន្តរជាតិ កម្ពុជាអនុវត្តតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដោយផ្តោតលើការពង្រឹងការត្រៀមខ្លួន និងការបន្សាំសម្រាប់ប្រជាជនងាយរងគ្រោះ ព្រមទាំងការពង្រឹងសមត្ថភាពបន្សាំ និងការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រែប្រួលអាកាសធាតុ។

ក្រឡេកទៅមើលឆ្នាំ២០២៥-២០៣៥ កម្ពុជាមានផែនការពង្រីកការគ្របដណ្តប់នៃកិច្ចគាំពារសង្គមឱ្យកាន់តែធំទូលាយ ដោយកំណត់គោលដៅលើគ្រួសារក្រីក្រចំនួន ៩៥% សាលារៀនជាង ១.១១១ ក្រោមកម្មវិធីផ្តល់អាហារតាមសាលារៀនដែលប្រើប្រាស់កសិផលក្នុងសហគមន៍ និងការចុះឈ្មោះចូលរួម ៨៥% ក្នុងកញ្ចប់គាំពារសុខភាពសង្គម។ ការពង្រីកកិច្ចគាំពារសង្គម គឺជារឿងចាំបាច់សម្រាប់ការពង្រឹងសមធម៌ និរន្តរភាព និងភាពធន់នៃសេដ្ឋកិច្ច ដោយធានាថា ស្ត្រី កុមារ ជនមានពិការភាព និងមនុស្សចាស់ មិនត្រូវបានទុកចោលឡើយ ហើយទន្ទឹមនឹងនោះ កសាងសង្គមមួយដែលមានស្ថិរភាព និងធន់នឹងអាកាសធាតុ។

មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ) ដែលត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ ៦៨ អនក្រ.បក (ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២) ដំណើរការជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានសាខានៅតាមបណ្តាខេត្ត ដើម្បីធានាការគ្របដណ្តប់ទូទាំងប្រទេស។ ម.ជ.ជ ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស គឺក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នៅថ្នាក់ខេត្ត សាខា ម.ជ.ជ ខេត្តកោះកុងអនុវត្តកម្មវិធីជំនួយសង្គមថ្នាក់ជាតិ និងគម្រោងសន្តិសុខសង្គមដែលបានជ្រើសរើស ដោយផ្តល់ការឧបត្ថម្ភសាច់ប្រាក់ ឧបត្ថម្ភធន និងសេវាដល់គ្រួសារក្រីក្រ ក្រុមងាយរងគ្រោះ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

កម្មវិធីសំខាន់ៗរបស់ ម.ជ.ជ រួមមាន៖

- **កម្មវិធីជាតិជំនួយសង្គម-កញ្ចប់គ្រួសារ (តាំងពីឆ្នាំ២០២៣)៖** គាំទ្រដល់ស្ត្រីមានផ្ទៃពោះ កុមារអាយុក្រោមពីរឆ្នាំ មនុស្សចាស់ដែលមានប័ណ្ណសមធម៌ ជនមានពិការភាព និងអ្នករស់នៅជាមួយមេរោគអេដស៍។

- **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ (ចាប់ពីខែមេសា ឆ្នាំ២០២៤)៖** លើកកម្ពស់សុខុមាលភាពមាតា និងកុមារ តាមរយៈការពិនិត្យផ្ទៃពោះ និងការគាំទ្រដល់ការចាក់វ៉ាក់សាំង។

- **ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជន៖** ផ្តល់ការបណ្តុះបណ្តាលដោយឥតគិតថ្លៃ និងប្រាក់ឧបត្ថម្ភប្រចាំខែដល់យុវជនដែលងាយប្រឈមហានិភ័យ ដើម្បីបង្កើនលទ្ធភាពរកបានការងារធ្វើ និងកាត់បន្ថយភាពក្រីក្រ។

- **ជំនួយសម្រាប់ទណ្ឌិតជាស្ត្រី៖** គាំទ្រដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោមពីរឆ្នាំនៅក្នុងពន្ធនាគារ ជាពិសេសអ្នកកាន់ប័ណ្ណសមធម៌។

- **ការគាំទ្រសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ និងគ្រួសារងាយប្រឈមហានិភ័យ៖** ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ និងការឧបត្ថម្ភគាំទ្រក្នុងពេល សម្រាលកូនដល់ម្តាយ និងកុមារតូចៗ។

- **របបសន្តិសុខសង្គម (ប.ស.ស)៖** ផ្តល់ការថែទាំសុខភាព ប្រាក់សោធននិវត្តន៍ និងការធានារ៉ាប់រងហានិភ័យការងារ សម្រាប់កម្មករនិយោជិតក្នុងវិស័យសាធារណៈ និងវិស័យឯកជន។

- **យន្តការឆ្លើយតបគ្រោះមហន្តរាយ៖** ផ្តល់ជំនួយស្បៀងអាហារ ជំនួយជាសាច់ប្រាក់ ទឹកស្អាត និងសេវាថែទាំសុខភាព ក្នុងពេលមានគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងគ្រោះអាសន្នផ្សេងទៀត ដែលទាក់ទងនឹងអាកាសធាតុ។

## គោលបំណង

ការពិភាក្សានេះមានគោលបំណងពិនិត្យមើលថាតើក្របខ័ណ្ឌគាំពារសង្គមរបស់កម្ពុជា ជាពិសេសកម្មវិធីកញ្ចប់គ្រួសារ ក្រោមសសរស្តម្ភជំនួយសង្គម បានគាំទ្រដល់គ្រួសារដែលក្រីក្រ និងងាយរងគ្រោះដោយសារអាកាសធាតុ ក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុយ៉ាងដូចម្តេច។ វគ្គនេះព្យាយាមវាយតម្លៃលើរបៀបដែលប្រព័ន្ធប័ណ្ណសមធម៌ (IDPoor) ផ្តល់ជំនួយចំគោលដៅ និងតាមកម្រិត ដល់គ្រួសារដែលប្រឈមនឹងគ្រោះទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត និងផលប៉ះពាល់តាមតំបន់ឆ្នេរ និងរបៀបដែលការឧបត្ថម្ភសាច់ប្រាក់រួមចំណែកដល់ការឆ្លើយតបនឹងវិបត្តិភ្លាមៗ និងភាពធន់យូរអង្វែង។ ការពិភាក្សាក៏មានគោលបំណងគូសបញ្ជាក់ពីបទពិសោធន៍ជាក់ស្តែងនៅថ្នាក់ខេត្ត រួមទាំងរបៀបដែលការរួមបញ្ចូលជំនួយហិរញ្ញវត្ថុ ជាមួយនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើពិពិធកម្មជីវភាពរស់នៅ ជួយពង្រឹងសមត្ថភាពបន្សុំារបស់គ្រួសារនីមួយៗ។ បន្ថែមលើនេះ ការពិភាក្សាបានស្វែងយល់ពីផលប៉ះពាល់អាកាសធាតុនៅកម្រិតសហគមន៍ ទស្សនៈរបស់អ្នកទទួលផលចំពោះការប្រើប្រាស់ជំនួយ និងតួនាទីរបស់អាជ្ញាធរមូលដ្ឋានក្នុងការផ្សព្វផ្សាយ និងអនុវត្តកម្មវិធីក្នុងគោលបំណងកំណត់រកមេរៀនផ្សេងៗ ដើម្បីពង្រឹង ពង្រីក និងកែលម្អកិច្ចគាំពារសង្គមដែលឆ្លើយតបនឹងអាកាសធាតុ សម្រាប់ប្រជាជនងាយរងគ្រោះ។

## ការពិភាក្សា

វាគ្មិនបានស្វែងយល់អំពីរបៀបដែលក្របខ័ណ្ឌគាំពារសង្គមរបស់កម្ពុជា ជាពិសេសកម្មវិធីកញ្ចប់គ្រួសារក្រោមសសរស្តម្ភជំនួយសង្គម ជួយគាំទ្រដល់គ្រួសារក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ។ ការពិភាក្សាបានសង្កត់ធ្ងន់ថា ក្របខ័ណ្ឌនេះស្ថាបនាពីលើសសរស្តម្ភចម្បងពីរគឺសន្តិសុខសង្គម និងជំនួយសង្គម ដោយផ្តោតជាពិសេសលើកម្មវិធីកញ្ចប់គ្រួសារ ដែលប្រើប្រាស់ប្រព័ន្ធប័ណ្ណសមធម៌ (IDPoor) ដើម្បីផ្តល់ឧបត្ថម្ភធនតាមកម្រិត ដោយផ្អែកលើភាពងាយរងគ្រោះរបស់គ្រួសារនីមួយៗ។ វគ្គនេះបានពិនិត្យមើលពីរបៀបដែលយន្តការទាំងនេះរួមចំណែកដល់ការកសាងភាពធន់របស់គ្រួសារដែលរស់នៅក្នុងភាពក្រីក្រ និងប្រឈមនឹងហានិភ័យអាកាសធាតុ ដូចជា ទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត និងការកើនឡើងនីវ៉ូទឹកសមុទ្រ។


YOUR DREAM HOME.



ទាក់ទងនឹងការអនុវត្តជាក់ស្តែងនៅថ្នាក់ខេត្ត កម្មវិធីកញ្ចប់គ្រួសារដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនភាពធន់របស់គ្រួសារ។ ឧទាហរណ៍មួយពីខេត្តកោះកុង ពាក់ព័ន្ធនឹងគ្រួសារកសិករមួយ ដែលត្រូវផ្លាស់ទីលំនៅដោយសារការខ្វះខាតទឹក ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ក្នុងនាមជាអ្នកកាន់ប័ណ្ណសមធម៌  ពួកគេបានទទួលជំនួយពីកម្មវិធីកញ្ចប់គ្រួសារ   និងបានចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ។ ឪពុកបានបញ្ចប់ការបណ្តុះបណ្តាលជំនាញសំណង់ដែលជួយបង្កើនប្រាក់ចំណូលប្រចាំថ្ងៃរបស់គាត់ពី ៣០.០០០ រៀល ក្នុងនាមជាកម្មករគ្មានជំនាញ ដល់ ៨០.០០០ រៀល បន្ទាប់ពីទទួលបានវិញ្ញាបនបត្រ។ ក្រោយមក កូនៗរបស់គាត់ក៏បានដើរតាមផ្លូវនេះដូចគ្នាដែលធ្វើឱ្យជីវភាពគ្រួសារមានលំនឹង និងអាចឱ្យពួកគេត្រៀមខ្លួនបានកាន់តែប្រសើរដើម្បីទប់ទល់នឹងហានិភ័យទឹកជំនន់ តាមរយៈការស្តុកទុកស្បៀងអាហារ និងសម្ភារចាំបាច់ផ្សេងៗ។ ឧទាហរណ៍នេះបានបង្ហាញពីរបៀបដែល ការប្របាច់បញ្ចូលការឧបត្ថម្ភសាច់ប្រាក់ជាមួយនឹងការអភិវឌ្ឍជំនាញ ជួយពង្រឹងភាពធន់យូរអង្វែង ជាជាងការផ្តល់តែជំនួយសង្គ្រោះរយៈពេលខ្លី។

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បានស្តែងឡើងនៅកម្រិតសហគមន៍។ ក្នុងឃុំប៉ាក់ខ្លង ខេត្តកោះកុង ប្រជាពលរដ្ឋប្រឈមនឹងការកើនឡើងនីវ៉ូទឹកសមុទ្រ ទឹកជំនន់ ខ្យល់បក់ខ្លាំង ការកញ្ជ្រោលឡើងនៃទឹករលក និងសំណឹកឆ្នេរ។ ការជ្រាបចូលទឹកប្រៃ រំខានដល់ការធ្វើដំណើរ និងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ។ ការនេសាទគឺជាមុខរបរចម្បង ប៉ុន្តែរដូវមានព្យុះរារាំងអ្នកនេសាទមិនឱ្យចេញទៅសមុទ្រ ដែលធ្វើ ឱ្យប្រែប្រួលដល់ប្រាក់ចំណូល។ ធាតុអាកាសអាក្រក់ ក៏បានបំផ្លិចបំផ្លាញផ្ទះសម្បែងផងដែរ។ កម្មវិធីកញ្ចប់គ្រួសារ ជួយរ៉ាប់រងតម្រូវការចាំបាច់ប្រចាំថ្ងៃ និងលើកកម្ពស់កម្រិតជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋជាច្រើន។

ពាក់ព័ន្ធនឹងទស្សនៈរបស់អ្នកទទួលផល គ្រួសារទទួលផលមួយបានពន្យល់ពីរបៀបដែលជំនួយជាសាច់ប្រាក់ត្រូវបានប្រើប្រាស់សម្រាប់ទិញថ្នាំសង្កូវចាំបាច់ ការបម្រុងទុកស្បៀងអាហារក្នុងអំឡុងពេលរកចំណូលមិនបាន និងការឧបត្ថម្ភគាំទ្រពេលអាសន្ន ក្នុងអំឡុងគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ។ ទោះបីជាថវិកាមានកម្រិត ប៉ុន្តែវាបានជួយបំពេញគម្លាតប្រាក់ចំណូលដ៏សំខាន់ ដោយបំពេញតម្រូវការគ្រួសារបានប្រមាណ ៥០% ក្នុងអំឡុងពេលដ៏លំបាក។ ព័ត៌មានអំពីកម្មវិធីនេះត្រូវបានផ្សព្វផ្សាយតាមរយៈអាជ្ញាធរភូមិ និងឃុំ។

ព្រះសីហនុគឺជាខេត្តតំបន់ឆ្នេរមួយ ដែលប្រឈមនឹងខ្យល់ព្យុះ និងទឹកជំនន់។ ដោយសារគ្រួសារជាច្រើនពឹងផ្អែកលើរបរនេសាទ ការអូសបន្លាយនៃបាតុភូតខ្យល់ព្យុះអាចធ្វើឱ្យពួកគាត់បាត់បង់ប្រាក់ចំណូលជាច្រើនសប្តាហ៍។ ជំនួយហិរញ្ញវត្ថុក្រោមកម្មវិធីកញ្ចប់គ្រួសារ ទោះមានចំនួនតិចតួចក្តី ប៉ុន្តែវាបានជួយឱ្យ គ្រួសារបង្កើនប្រភពចំណូល ឧទាហរណ៍ តាមរយៈការបើកអាជីវកម្មខ្នាតតូចលក់វត្ថុអនុស្សាវរីយ៍ជូនភ្ញៀវទេសចរ។ កម្មវិធីនេះបានឧបត្ថម្ភគាំទ្រដល់គ្រួសារជាង ៥០% ដែលរងផលប៉ះពាល់ ដោយជួយលើកកម្ពស់ការបន្ស៊ាំនឹងអាកាសធាតុនៅកម្រិតមូលដ្ឋាន។

ការពិភាក្សាបានឆ្លុះបញ្ចាំងថា ប្រព័ន្ធប័ណ្ណសមធម៌ (IDPoor) ផ្តល់ការគាំទ្រចំគោលដៅ និងតាមកម្រិត ដល់គ្រួសារដែលងាយរងគ្រោះបំផុត ដោយធានាថា ជំនួយបានដល់ដៃអ្នកដែលខ្វះខាតបំផុត។ ការឧបត្ថម្ភសាច់ប្រាក់មិនត្រឹមតែជាជំនួយសង្គ្រោះបន្ទាន់ភ្លាមៗប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមូលដ្ឋានគ្រឹះសម្រាប់ពង្រឹងជីវភាពរស់នៅរយៈពេលវែងផងដែរ។ នៅពេលរួមបញ្ចូលជាមួយការបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនួយហិរញ្ញវត្ថុជួយពង្រឹងសមត្ថភាពបន្ស៊ាំរបស់គ្រួសារ ដោយជួយឱ្យពួកគាត់ត្រៀមខ្លួនទប់ទល់គ្រោះមហន្តរាយនាពេលអនាគតបានកាន់តែប្រសើរ។ ការចុះផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពនៅកម្រិតសហគមន៍ តាមរយៈអាជ្ញាធរមូលដ្ឋាន ធានាបាននូវលទ្ធភាពយ៉ាងទូលំទូលាយក្នុងការចូលរួមកម្មវិធី ហើយសូម្បីតែការគាំទ្រតិចតួច ក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាលំនឹងគ្រួសារ នៅពេលមានវិបត្តិទាក់ទងនឹងអាកាសធាតុ។ សរុបមក ក្របខ័ណ្ឌគាំពារសង្គមរបស់កម្ពុជា ជាពិសេសកម្មវិធីកញ្ចប់គ្រួសារ បានរួមចំណែកយ៉ាងសំខាន់ដល់ការកសាងភាពធន់ ក្នុងចំណោមសហគមន៍ដែលរងផលប៉ះពាល់ដោយអាកាសធាតុ។ ការពង្រីក និងការពង្រឹងការគ្របដណ្តប់បន្ថែមទៀតអាចជួយបង្កើនការការពារប្រជាជនងាយរងគ្រោះ ក្នុងបរិបទនៃការកើនឡើងហានិភ័យបរិស្ថាន។

# វាគ្មិន និងអ្នកសម្របសម្រួល

---

អ្នកធ្វើបទបង្ហាញ

**ឯកឧត្តម សរ បូរីរក្ស**
*នាយកវិទ្យាស្ថានជាតិសង្គមកិច្ច*

**លោក គង់ សុមុន្នី**
*ប្រធានសាខាមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ) ខេត្តកោះកុង*

---

វាគ្មិន

**លោក គង់ សុមុន្នី**
*ប្រធានសាខាមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ) ខេត្តកោះកុង*

**លោកស្រី សំម ឌីណា**
*ប្រធានសាខា ម.ជ.ជ ខេត្តព្រះសីហនុ*

**លោកស្រី ឌឹម សុខធីតា**
*សមាជិកក្រុមប្រឹក្សាឃុំប៉ាក់ខ្លង ខេត្តកោះកុង*

**លោកស្រី សាយ ចន្ថា**
*តំណាងសហគមន៍*

---

អ្នកសម្របសម្រួល

**បណ្ឌិត សំ ចាន់ធី**
*ប្រធានក្រុមស្រាវជ្រាវនៃវិទ្យាស្ថានជាតិសង្គមកិច្ច*

ចំណុចសំខាន់ទី ៣

# ការចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធភាពជាមួយសហគមន៍

កញ្ញា ជាតិ សុខា មានពិការភាពខួរឆ្អឹងខ្នង និងត្រូវជិះរទេះរុញ។ បច្ចុប្បន្ន កញ្ញាបម្រើការជានាយិកាប្រតិបត្តិនៃសមាគមជនពិការខួរឆ្អឹងខ្នងកម្ពុជា ប្រចាំខេត្តបាត់ដំបង និងជាតំណាងនៃអង្គការតំណាងជនមានពិការភាព (OPD)។ កញ្ញាបានធ្វើការជាច្រើនឆ្នាំមកហើយនៅក្នុងវិស័យសិទ្ធិជនមានពិការភាព និងបានតស៊ូមតិជាមួយអ្នកតាក់តែងគោលនយោបាយ និងអង្គការសង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ ដោយទាញយកចេញពីបទពិសោធន៍ដ៏ទូលំទូលាយរបស់កញ្ញាផ្ទាល់។

- តាំងពីឆ្នាំ ២០១១ មក ខ្ញុំបានជួបប្រទះការលំបាកជាច្រើនទាក់ទងនឹងការធ្វើដំណើរ និងលទ្ធភាពចេញចូល។ សព្វថ្ងៃនេះ ខ្ញុំធ្វើការជានាយិកាប្រតិបត្តិនៃសមាគមជនពិការខួរឆ្អឹងខ្នងកម្ពុជា ប្រចាំខេត្តបាត់ដំបង ហើយខ្ញុំពិតជារីករាយណាស់ ដែលបានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន ទាក់ទងនឹងការទំនាក់ទំនងសហគមន៍ប្រកបដោយប្រសិទ្ធភាព។

- ការចែករំលែកព័ត៌មាន គឺលើសពីការនិយាយតែម្យ៉ាង។ វាជាខ្សែជីវិតសម្រាប់សហគមន៍ ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ និងជនមានពិការភាព។ វាពិតជាមានសារៈសំខាន់ណាស់ ដែលយើងត្រូវផ្តល់ព័ត៌មានអំពីកិច្ចការពារផ្លូវច្បាប់ ដែលផ្តល់ដោយរដ្ឋាភិបាល ដូចជា អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) យុទ្ធសាស្ត្រអ៊ីនឈាន់ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពរបស់យើង។ បច្ចុប្បន្ន មនុស្សជាច្រើននៅតែមិនដឹងថាមានច្បាប់ទាំងនេះសម្រាប់ការពារពួកគេឡើយ ដូច្នេះ យើងចាំបាច់ត្រូវតែកែលម្អរបៀបដែលយើងនាំយកព័ត៌មាននេះទៅផ្តល់ឱ្យពួកគេដោយផ្ទាល់។

- ខ្ញុំក៏ចង់គូសបញ្ជាក់ផងដែរអំពីការងារដ៏ល្អដែលអាជ្ញាធរមូលដ្ឋានកំពុងអនុវត្ត។ តាមរយៈការប្រើប្រាស់កិច្ចប្រជុំភូមិ ដើម្បីពិភាក្សាពីរឿងរ៉ាវនានា ដូចជាកម្មវិធីវិនិយោគបីឆ្នាំរំកិល ការប្រកាសអាសន្នអំពីគ្រោះមហន្តរាយ និងប្រព័ន្ធសង្គម ដូចជា M-Drive អាជ្ញាធរបាន និងកំពុងបន្តផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋមូលដ្ឋាន។ អ្វីដែលសំខាន់បំផុតនោះគឺនៅពេលដែលជនមានពិការភាពមិនអាចចូលរួមកិច្ចប្រជុំបាន អាជ្ញាធរបានចុះទៅដល់ផ្ទះរបស់ពួកគាត់ ដើម្បីចែករំលែកព័ត៌មានទាំងនោះ។

- ក្នុងនាមជាអង្គការតំណាងជនមានពិការភាព យើងក៏កំពុងបំពេញតួនាទីរបស់យើងផងដែរ។ យើងបានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាដើម្បីចែករំលែក 'ការអនុវត្តល្អ' និងព័ត៌មានថ្មីៗបំផុតស្តីពីគោលនយោបាយ។ មិនថាតាមរយៈកិច្ចប្រជុំអនឡាញ វេទិកាប្រចាំឆ្នាំ ឬការឆ្លើយតបទៅនឹងវិបត្តិ ដូចជា ជំងឺកូវីដ-១៩ នោះទេ គោលដៅរបស់យើងគឺការធានាថាសហគមន៍ជនមានពិការភាព មិនត្រូវបានទុកចោល។

- ព័ត៌មានកំពុងត្រូវបានចែករំលែក ប៉ុន្តែវាមិនបានជ្រួតជ្រាបដល់មនុស្សគ្រប់រូបដែលត្រូវការព័ត៌មានទាំងនោះទេ។ បច្ចុប្បន្ន យើងមើលឃើញថា អ្នកដែលមានពិការភាពកម្រិតស្រាលអាចចូលរួមកិច្ចប្រជុំ និងទទួលបានព័ត៌មាន ប៉ុន្តែអ្នកដែលមានពិការភាពធ្ងន់ធ្ងរ ឬអ្នកដែលរស់នៅឆ្ងាយ កំពុងត្រូវបានផាត់ចេញពីការទទួលបានព័ត៌មានបែបនេះ។

- ការណ៍ដែលមិនសូវមានការផ្សព្វផ្សាយព័ត៌មានបែបនេះ មានន័យថាមនុស្សជាច្រើនកំពុងបាត់បង់អត្ថប្រយោជន៍ដែលអាចផ្លាស់ប្តូរជីវិតរបស់ពួកគេ។ ពួកគេកំពុងបាត់បង់ឱកាសក្នុងការដាក់ពាក្យស្នើសុំប័ណ្ណសមធម៌ IDPoor ពោលគឺពួកគេបាត់បង់លទ្ធភាពទទួលបានប្រាក់ឧបត្ថម្ភ និងសេវាសុខភាពសាធារណៈ។

- យើងចាំបាច់ត្រូវផ្លាស់ប្តូររបៀបធ្វើការរបស់យើង។ យើងត្រូវតែស្វែងរកមធ្យោបាយនាំយកព័ត៌មានទាំងនេះទៅផ្តល់ដល់អ្នកដែលមិនអាចចេញពីផ្ទះបាន ដោយផ្ទាល់។ យើងត្រូវធានាថាពួកគេយល់ពីគោលនយោបាយរបស់រដ្ឋាភិបាល ហើយអ្វីដែលសំខាន់ជាងនេះទៅទៀត យើងត្រូវផ្តល់ឱ្យពួកគេនូវវេទិកាមួយដើម្បីបញ្ចេញមតិ។ យើងត្រូវស្តាប់បញ្ហា និងតម្រូវការរបស់ពួកគេ ដើម្បីឱ្យយើងអាចដោះស្រាយបញ្ហាជាមួយគ្នា។

- ក្នុងនាមជាស្ត្រីមានពិការភាពម្នាក់ និងជាអ្នកតស៊ូមតិ ខ្ញុំសង្ឃឹមថា យើងអាចធ្វើឱ្យព័ត៌មានងាយស្រួលទទួលបានយ៉ាងពិតប្រាកដ។ តាមរយៈការផ្តោតលើតម្រូវការរបស់ជនងាយរងគ្រោះបំផុត មានជាអាទិ៍ ស្ត្រី កុមារ មនុស្សចាស់ និងសហគមន៍ជនជាតិដើមភាគតិច យើងនឹងអាចកសាងអនាគតមួយ ដែលមនុស្សគ្រប់រូបទទួលបានព័ត៌មានដែលពួកគេត្រូវការ ដើម្បីភាពរីកចម្រើន។

## ការពិភាក្សាស្របពេលគ្នា ១៥៖

# “ការបែងចែកថវិកាឃុំសម្រាប់ការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់លើសហគមន៍ងាយរងគ្រោះ”

*រៀបចំដោយ អង្គការភូមិខ្ញុំ*



## សាវតារ

ប្រទេសកម្ពុជាប្រឈមនឹងហានិភ័យគ្រោះមហន្តរាយក្នុងកម្រិតខ្ពស់ ដោយឈរនៅលេខរៀងទី ៥៥ ក្នុងចំណោម ១៩១ ប្រទេស កាលពីឆ្នាំ២០១៩។ ការប្រែប្រួលអាកាសធាតុបានបង្កផលជះមកលើប្រទេសកម្ពុជា។ ឧទាហរណ៍ តាមការប៉ាន់ស្មាន មានប្រជាពលរដ្ឋខ្មែរប្រមាណ ៩០.០០០ នាក់ បានរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់ជារៀងរាល់ឆ្នាំ ខណៈដែលការខូចខាតហេដ្ឋារចនាសម្ព័ន្ធទីក្រុងត្រូវបានរំពឹងថាមានទំហំទឹកប្រាក់ ១០៥ លានដុល្លារអាមេរិក។ តាមការរំពឹងទុក ការអភិវឌ្ឍសេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យតួលេខទាំងនេះកើនឡើង។ ចំនួនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងទំហំនៃការខូចខាតទីក្រុងត្រូវបានរំពឹងថានឹងកើនឡើងជារៀងរាល់ឆ្នាំ គឺនឹងដល់ ២២៦ លានដុល្លារអាមេរិក នៅត្រឹមឆ្នាំ២០៣០។ ក្រុមប្រឹក្សាខេត្ត ស្រុក ឃុំ និងសង្កាត់ ដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងភាពធន់របស់សហគមន៍។ រដ្ឋបាលមូលដ្ឋានបានធ្វើអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ប៉ុន្តែពួកគេមិនសុទ្ធតែអាចដោះស្រាយតម្រូវការបន្ទាន់ ដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ ដែលសហគមន៍ងាយរងគ្រោះកំពុងប្រឈមមុខនោះទេ។

បច្ចុប្បន្ន រដ្ឋបាលថ្នាក់ឃុំបានបង្ហាញចំណាប់អារម្មណ៍កាន់តែខ្លាំងលើការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ខណៈពេលដែលសហគមន៍ជួបប្រទះគ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះកាន់តែញឹកញាប់។ សម្ពាធបរិស្ថានទាំងនេះ កំពុងធ្វើឱ្យប៉ះពាល់ដល់របរចិញ្ចឹមជីវិតនៅជនបទ និងបង្កផលជះលើក្រុមងាយរងគ្រោះ រួមមានស្ត្រី កុមារ ជនមានពិការភាព មនុស្សចាស់ និងសហគមន៍ជនជាតិដើមភាគតិច។

## គោលបំណង

ការពិភាក្សាមានគោលបំណងពិនិត្យមើលថាតើគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ ធ្វើឱ្យប៉ះពាល់ដូចម្ដេចដល់ជីវភាពរស់នៅប្រចាំថ្ងៃ និងមុខរបរក្នុងសហគមន៍ ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ  និងស្វែងយល់ពីតួនាទីរបស់រដ្ឋបាលមូលដ្ឋានក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះតាមរយៈការត្រៀមខ្លួនទប់ទល់គ្រោះមហន្តរាយ ការស្ដារឡើងវិញ និងការផ្ដល់សេវា។ វគ្គនេះខិតខំវាយតម្លៃការអនុវត្តការឆ្លើយតបបច្ចុប្បន្ននៅថ្នាក់មូលដ្ឋាន យន្តការសម្របសម្រួល និងឧបករណ៍រៀបចំផែនការ ដែលប្រើប្រាស់នៅថ្នាក់ភូមិ ឃុំ និងស្រុក ព្រមទាំងកំណត់រកចន្លោះប្រហោងក្នុងវិភាជថវិកា សមត្ថភាពបច្ចេកទេស និងការផ្សព្វផ្សាយព័ត៌មាន។ ការពិភាក្សាក៏មានគោលបំណងស្វែងយល់ផងដែរអំពីឱកាសដែលកើតចេញពីសេចក្តីណែនាំគោលនយោបាយថ្មីៗ ដើម្បីបង្កើនភាពបត់បែននៃថវិកា ពង្រឹងការដាក់បញ្ចូលភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន និងលើកកម្ពស់កិច្ចសហការជាមួយមន្ទីរជំនាញ។

# ការពិភាក្សា

**ផលជះទាក់ទងនឹងអាកាសធាតុមកលើសហគមន៍៖** តំណាងសហគមន៍បានពណ៌នាអំពីរបៀបដែលព្រឹត្តិការណ៍ទាក់ទងនឹងអាកាសធាតុ បង្កផលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ ទឹកជំនន់អាចបំផ្លាញដំណាំស្រូវក្នុងរយៈពេលប៉ុន្មានថ្ងៃ និងបង្កើតជាស្ថានភាពខ្វះអនាម័យ ខណៈដែលគ្រោះរាំងស្ងួតធ្វើឱ្យខ្សត់ទឹកសម្រាប់ការធ្វើកសិកម្ម និងការប្រើប្រាស់ក្នុងគ្រួសារ។ នៅក្នុងសហគមន៍ដាច់ស្រយាល និងសហគមន៍តាមកោះ កង្វះហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ធ្វើឱ្យមានការលំបាកដល់ការទទួលបានសេវាក្នុងពេលមានគ្រោះអាសន្ន។ សម្រាប់ជនមានពិការភាព និងស្ត្រីមានផ្ទៃពោះ គ្រោះមហន្តរាយអាចបង្កឧបសគ្គបន្ថែមទៀតដល់ការធ្វើដំណើរ ការថែទាំសុខភាព និងការប្រកបរបរចិញ្ចឹមជីវិត។ គ្រោះមហន្តរាយអាកាសធាតុ ក៏ប៉ះពាល់ដល់ការអប់រំរបស់កុមារផងដែរ ព្រោះទឹកជំនន់ ឬការខូចខាតផ្លូវ អាចរារាំងពួកគេមិនឱ្យធ្វើដំណើរទៅសាលារៀន។

**តួនាទីរបស់រដ្ឋបាលមូលដ្ឋានក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ៖** រដ្ឋបាលមូលដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ។ ជារឿយៗ មេភូមិជាអ្នកប្រមូលព័ត៌មានអំពីគ្រោះមហន្តរាយ និងរាយការណ៍ទៅក្រុមប្រឹក្សាឃុំ ដែលសម្របសម្រួលការឆ្លើយតប និងស្នើសុំការគាំទ្រពីមន្ទីរពាក់ព័ន្ធនៅពេលចាំបាច់។ អន្តរាគមន៍ រួមមានការផ្តល់គ្រាប់ពូជដល់កសិករ បន្ទាប់ពីទឹកជំនន់បំផ្លាញផលដំណាំ ការស្នើសុំជំនួយបច្ចេកទេសពីមន្ទីរកសិកម្ម ដើម្បីដោះស្រាយបញ្ហាសត្វល្អិតចង្រៃ និងមន្ទីរអភិវឌ្ឍន៍ជនបទ ដើម្បីបង្កើនលទ្ធភាពទទួលបានទឹក តាមរយៈអណ្តូង ស្រះ និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ មានគោលបំណងជួយឱ្យសហគមន៍ស្តារឡើងវិញ និងរក្សាផលិតកម្មកសិកម្ម។



**ការសម្របសម្រួលការឆ្លើយតបគ្រោះអាសន្ន៖** នៅថ្នាក់ស្រុក រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលការឆ្លើយតបគ្រោះអាសន្ន។ ជាទូទៅ ក្រុមប្រតិបត្តិការត្រូវបានចាត់តាំងឱ្យដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការស្វែងរក និងសង្គ្រោះ អនាម័យ និងទឹកស្អាត ការផ្សព្វផ្សាយព័ត៌មាន និងជំនួយសង្គ្រោះបន្ទាន់។ អាជ្ញាធរមូលដ្ឋានក៏សហការជាមួយមណ្ឌលសុខភាព និងមន្ទីរពាក់ព័ន្ធផ្សេងទៀតផងដែរ ដើម្បីជួយគាំទ្រដល់គ្រួសារងាយរងគ្រោះក្នុងអំឡុងពេលមានគ្រោះមហន្តរាយ។




**ថវិកាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ៖** ទោះបីជាមានគំនិតផ្តួចផ្តើមទាំងនេះក៏ដោយ ប៉ុន្តែវិភាជថវិកាសម្រាប់សកម្មភាពទាក់ទងនឹងអាកាសធាតុនៅមានកម្រិតនៅឡើយ។ ជារឿយៗ ថវិកាឃុំផ្តោតអាទិភាពលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ខណៈដែលការផ្តល់មូលនិធិសម្រាប់សេវាសង្គម ឬការឆ្លើយតបផ្នែកបរិស្ថានមានទំហំតូច។ ឃុំមួយចំនួនបែងចែកធនធានក្នុងកម្រិតមធ្យម ដើម្បីជួយគាំទ្រគ្រួសារងាយរងគ្រោះក្នុងអំឡុងពេលមានគ្រោះមហន្តរាយ ឬផ្តល់ធាតុចូលកសិកម្មដល់កសិករដែលរងផលប៉ះពាល់។ គោលការណ៍ណែនាំថ្មីៗពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈសារាចរលេខ ០០៧ បានណែនាំឱ្យរដ្ឋបាលថ្នាក់ឃុំមានភាពបត់បែនកាន់តែច្រើនក្នុងការបែងចែកថវិកាទៅលើសេវាសង្គម អនាម័យ និងសកម្មភាពបរិស្ថានដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណា មន្ត្រីមូលដ្ឋានជាច្រើននៅមិនទាន់ស្គាល់ច្បាស់អំពីលេខកូដថវិកា និងនីតិវិធីពាក់ព័ន្ធនៅឡើយ។

**ការដាក់បញ្ចូលសកម្មភាពអាកាសធាតុទៅក្នុងផែនការមូលដ្ឋាន៖** យន្តការរៀបចំផែនការមូលដ្ឋាន ដូចជា កម្មវិធីវិនិយោគឃុំ និងផែនការបីឆ្នាំរំកិល ផ្តល់ឱកាសក្នុងការដាក់បញ្ចូលអាទិភាពដែលទាក់ទងនឹង អាកាសធាតុ។ អាជ្ញាធរកំពុងចាប់ផ្តើមដាក់បញ្ចូលសកម្មភាពនានា ដូចជា ការកែលម្អហេដ្ឋារចនាសម្ព័ន្ធទឹក ការគាំទ្រផ្នែកកសិកម្ម និងការត្រៀមខ្លួនទប់ទល់គ្រោះមហន្តរាយ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន។ ការរក្សាទុកទិន្នន័យស្តីពីគ្រួសារងាយរងគ្រោះ ក៏ជួយឱ្យអាជ្ញាធរមូលដ្ឋានអាចផ្តល់ការគាំទ្រចំគោលដៅបាន កាន់តែប្រសើរ ក្នុងអំឡុងពេលមានគ្រោះអាសន្នផងដែរ។

**គំនិតផ្តួចផ្តើមដ៏ជោគជ័យ៖** ការអនុវត្តល្អមួយចំនួនបានស្តែងឱ្យឃើញរួចទៅហើយ។ ការសម្របសម្រួល រវាងអាជ្ញាធរឃុំ និងមន្ទីរជំនាញ ជួយឱ្យសហគមន៍ទទួលបានការគាំទ្រផ្នែកកសិកម្ម ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាផ្សេងទៀត នៅពេលដែលថវិកាមូលដ្ឋានមិនគ្រប់គ្រាន់។ ការផ្សព្វផ្សាយព័ត៌មានតាមរយៈការប្រជុំភូមិ និងការប្រកាសតាមមេក្រូ ក៏បានជួយបង្កើនការយល់ដឹងអំពីការត្រៀមខ្លួនទប់ទល់គ្រោះមហន្តរាយផងដែរ។

**បញ្ហាប្រឈមដែលនៅសេសសល់៖** នៅចំពោះមុខវឌ្ឍនភាពដែលសម្រេចបាន គឺនៅមានបញ្ហាប្រឈម មួយចំនួន។ ធនធានថវិកាសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅមានកម្រិត ហើយជារៀងរាល់ឆ្នាំ ព័ត៌មានច្រើនតែត្រូវបានផ្សព្វផ្សាយដល់ភូមិមួយចំនួនតូចប៉ុណ្ណោះ ដែលធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ ការយល់ដឹង មិនសូវមានប្រសិទ្ធភាព។ ក្រុមងាយរងគ្រោះ ក៏អាចជួបប្រទះការលំបាកក្នុងការចូលរួមកិច្ចប្រជុំ ឬទទួលបានសេវាគាំទ្រ ក្នុងអំឡុងពេលមានគ្រោះមហន្តរាយផងដែរ។

> **ដំណើរឆ្ពោះទៅមុខ៖** ការពង្រឹងភាពធន់នឹងអាកាសធាតុ នឹងទាមទារ ការវិនិយោគកាន់តែច្រើន។ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធទឹក ដូចជា អណ្តូង និងស្រះ អាចជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងគ្រោះរាំងស្ងួត ខណៈដែលការ ផ្តល់ការគាំទ្រកាន់តែប្រសើរដល់ការធ្វើកសិកម្ម អាចជួយដល់កសិករដែលរងផល ប៉ះពាល់ដោយទឹកជំនន់។ ការបង្កើនវិភាជថវិកាឃុំ និងស្រុកសម្រាប់សកម្មភាព ទាក់ទងនឹងអាកាសធាតុ រួមជាមួយនឹងកិច្ចសហការកាន់តែរឹងមាំជាមួយមន្ទីរ បច្ចេកទេស នឹងជួយធានាបានថា ការឆ្លើយតបនឹងអាកាសធាតុមានបរិយាបន្ន ហើយឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ងាយរងគ្រោះ។

# វាគ្មិន និងអ្នកសម្របសម្រួល

---

វាគ្មិន

**លោកស្រី យូ ចាន់បុប្ផា**
*មន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំអូរម្រេះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង*

**លោកស្រី ឡា ចិន្តា**
*អភិបាលរងស្រុក ទទួលបន្ទុកហិរញ្ញវត្ថុ និងវិភាជថវិកាឃុំ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង*

**លោកស្រី ហ៊ិន សុវណ្ណារ៉ា**
*សមាជិកក្រុមប្រឹក្សាឃុំអូរម្រេះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង*

**លោក ឆែង ពឿន**
*ជនជាតិដើមភាគតិចកួយ មានពិការភាព រស់នៅភូមិកោះជ្រឹង ឃុំអូរម្រេះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង*

---

អ្នកសម្របសម្រួល

**លោក ជួន វីរៈ**
*មន្ត្រីគម្រោង "ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានធម្មជាតិ" នៃអង្គការភូមិខ្ញុំ*

ចំណុចសំខាន់ទី ៤

# ការធ្វើកិច្ចពិភាក្សាប្រកបដោយបរិយាបន្ននៅក្នុងសហគមន៍

លោកស្រី នូវ ស្រីលាប គឺជាតួល្ខោន ជាអ្នកដឹកនាំរឿង និងជាស្ថាបនិកនៃក្រុមសិល្បៈល្ខោនឆ្លុះ។ ជាមួយនឹងបទពិសោធន៍ជាង១០ឆ្នាំ លោកស្រីធ្វើការនៅក្នុងរោងល្ខោនសហគមន៍ និងចូលរួមក្នុងសកម្មភាពសង្គម ដែលផ្តោតលើសមភាពយេនឌ័រ ការបង្កើនភាពអង់អាចដល់ស្ត្រី និងសិទ្ធិមនុស្ស។ ការងាររបស់កញ្ញាសង្កត់ធ្ងន់លើវិធីសាស្ត្រប្រកបដោយបរិយាបន្ន និងការចូលរួម ដោយប្រើប្រាស់ល្ខោនជាឧបករណ៍សម្រាប់ការពិភាក្សាសហគមន៍ និងការផ្លាស់ប្តូរជាវិជ្ជមាន។

- នាងខ្ញុំជាស្ថាបនិក និងប្រធានក្រុមសិល្បៈល្ខោនឆ្លុះ ហើយនាងខ្ញុំមានកិត្តិយសណាស់ដែលទទួលបានពានរង្វាន់ "ការពិភាក្សាប្រកបដោយបរិយាបន្ន" នៅចុងឆ្នាំ២០២៥ ពីកម្មវិធីពន្លកចំណេះ។

- ក្រុមល្ខោនឆ្លុះ ធ្វើការដោយផ្ទាល់ជាមួយក្រុមងាយរងគ្រោះ ឬក្រុមដែលត្រូវបានគេមើលរំលង ដូចជាស្ត្រីដែលទទួលរងអំពើហិង្សា អ្នកស្រឡាញ់ភេទដូចគ្នា និងជនជាតិភាគតិច។ ក្រុមនេះប្រើប្រាស់ការសម្តែងល្ខោនជាឧបករណ៍ ដើម្បីចែករំលែក និងឆ្លុះបញ្ចាំងពីបញ្ហាប្រឈមរបស់ពួកគេដែលមិនទាន់ដោះស្រាយ។ តាមរយៈការសម្តែងល្ខោនបង្ហាញជូនសាធារណជន ឬអ្នកពាក់ព័ន្ធ វត្ថុបំណងនៃល្ខោនគឺបង្កើតឱកាសធ្វើការជាមួយគ្នា ដើម្បីស្វែងរកដំណោះស្រាយ។

- វិធីសាស្ត្ររបស់យើងគឺការប្រើប្រាស់ការសម្តែងល្ខោន ដើម្បីបង្ហាញពីបញ្ហាប្រឈមទាំងនេះ តាមរយៈការប្រែក្លាយបទពិសោធន៍ពិតក្នុងជីវិត ទៅជាការសម្តែង។ ចុងបញ្ចប់នៃការសម្តែងទាំងនេះមិនមែនជារឿងរ៉ាវរីករាយ ឬរឿងរ៉ាវជោគជ័យនោះទេ ប៉ុន្តែវាពណ៌នាអំពីការតស៊ូពិតប្រាកដ ព្រោះថាជីវិតពិត ជាពិសេសជីវិតរបស់ក្រុមងាយរងគ្រោះ គឺមិនងាយស្រួលឡើយ។ ក្នុងអំឡុងពេលសម្តែង ទាំងទស្សនិកជន និងអ្នកសម្តែងដែលមកពីក្រុមងាយរងគ្រោះផ្ទាល់ ត្រូវបានលើកទឹកចិត្តឱ្យគិតរួមគ្នា និងស្វែងរកដំណោះស្រាយដែលអាចទៅរួច ក្នុងពេលកំពុងទស្សនាសាច់រឿង។

**ដំណាក់ទីពីរ គឺការប្រែក្លាយការពិភាក្សាទៅជាការផ្លាស់ប្តូរជាក់ស្តែង៖**

- ទីមួយ យើងប្រើប្រាស់ការសម្តែងល្ខោន ដើម្បីកសាងទំនុកចិត្ត និងទំនាក់ទំនងជាមួយក្រុមងាយរងគ្រោះ។ នៅពេលដែលពួកគេចាប់ផ្តើមមានអារម្មណ៍ជឿជាក់ និងមានទំនាក់ទំនងជិតស្និទ្ធ យើងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអប់រំ សិទ្ធិតាមផ្លូវច្បាប់ និងការទទួលបានសេវាសាធារណៈ។ ចំណេះដឹងទាំងនេះក្លាយជាមូលដ្ឋានគ្រឹះ ដែលពួកគេអាចយកទៅប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃ ក្នុងទំនាក់ទំនង និងជាការយល់ដឹងទូទៅ។

- បន្ទាប់ពីទទួលបានចំណេះដឹង និងការអប់រំទាំងនេះ យើងចាប់ផ្តើមផលិតការសម្តែង ដោយផ្អែកលើបញ្ហាប្រឈមក្នុងជីវិតពិតរបស់ពួកគេ។ ល្ខោនផ្ទះ អញ្ជើញសមាជិកនៃក្រុមងាយរងគ្រោះឱ្យមកជួបជុំគ្នា ចែករំលែកបទពិសោធន៍របស់ពួកគេ កំណត់រកបញ្ហារួម និងជួយគ្នាកំណត់បញ្ហាប្រឈម ដែលបានបង្ហាញក្នុងការសម្តែង។ បន្ទាប់មក ការសម្តែងត្រូវបានចែករំលែកជាមួយភាគីពាក់ព័ន្ធ រួមទាំងអាជ្ញាធរ អង្គការដៃគូ និងសមាជិកសហគមន៍ ដែលមាននាទីការដោះស្រាយបញ្ហាទាំងនេះ។

- បន្ទាប់ពីការសម្តែង គ្រប់គ្នាយល់ច្បាស់អំពីបញ្ហាប្រឈម ដែលជួបប្រទះដោយក្រុមងាយរងគ្រោះ។ ពេលកំពុងទស្សនា ភាគីពាក់ព័ន្ធត្រូវបានលើកទឹកចិត្តឱ្យគិតពីដំណោះស្រាយដែលអាចទៅរួច។ បន្ទាប់មក យើងភ្ជាប់ទំនាក់ទំនងជនងាយរងគ្រោះជាមួយនឹងអ្នកជំនាញ និងភាគីពាក់ព័ន្ធ ដូចជា អាជ្ញាធរមូលដ្ឋាន ដែលមាននាទីអនុវត្តដំណោះស្រាយ។ យើងក៏ភ្ជាប់ទំនាក់ទំនងពួកគេជាមួយអ្នកជំនាញខាងប្រឹក្សាយោបល់ ជំនួយផ្នែកច្បាប់ និងសេវាគាំទ្រផ្សេងទៀតផងដែរ ដើម្បីជួយបន្តដំណើរការដោះស្រាយបញ្ហារបស់ពួកគេ។

- បន្ថែមពីលើការភ្ជាប់ទំនាក់ទំនងទាំងនេះ យើងមិនទុកពួកគេចោលនោះទេ។ យើងបង្កើតក្រុម Telegram ឬក្រុម Facebook ដើម្បីរក្សាការទំនាក់ទំនង និងការគាំទ្រ។ សូម្បីតែនៅពេលដែលយើងមិនបានធ្វើសកម្មភាពរួមគ្នាដោយផ្ទាល់ ក៏យើងនៅតែបន្តចែករំលែកព័ត៌មាន និងផ្តល់ជំនួយ រាល់ពេលដែលមានបញ្ហាកើតឡើង។ ប្រសិនបើគ្មានការបន្តគាំទ្របែបនេះទេ សកម្មភាពនឹងត្រូវបញ្ចប់ ហើយបុគ្គលម្នាក់ៗប្រហែលជាមិនដឹងថាត្រូវស្វែងរកជំនួយនៅទីណាឡើយ។ នៅពេលប្រឈមនឹងបញ្ហាសុខភាពផ្លូវចិត្ត ឬមានអារម្មណ៍ទាល់ច្រក ពួកគេអាចនឹងយល់ថា ខ្លួនឯងតែលតោល ឬគិតខ្លី។ ដូច្នេះ យើងត្រូវរក្សាទំនាក់ទំនងជាមួយអ្នកជំនាញ ក្រុមគាំទ្រ និងអាជ្ញាធរ។

- សមាសធាតុសំខាន់មួយទៀត គឺការពិភាក្សាប្រកបដោយបរិយាបន្ន។ នេះមានន័យថាជាការបង្កើតទីកន្លែង ឬវេទិកាសុវត្ថិភាពមួយ ដែលមនុស្សគ្រប់រូប ទោះចេះ ឬមិនចេះអក្សរ ក្មេង ឬចាស់ សុទ្ធតែអាចចូលរួម ចែករំលែកមតិយោបល់ និងបង្ហាញបទពិសោធន៍បាន។ ទីកន្លែងនេះមានសុវត្ថិភាព ឯកជនភាព និងគ្មានការរើសអើង ឬសម្ពាធអ្វីឡើយ។ នៅពេលដែលសំឡេងរបស់ពួកគេត្រូវបានស្តាប់ឮ និងគោរព ពួកគេមានអារម្មណ៍ថា ខ្លួនឯងត្រូវបានគេទទួលស្គាល់ និងយល់ចិត្ត។ ការស្តាប់ដោយការគោរព ការយកចិត្តទុកដាក់ និងការប្រុងប្រយ័ត្ន កសាងមូលដ្ឋានសម្រាប់ការដោះស្រាយបញ្ហា។

- ការពិភាក្សាប្រកបដោយបរិយាបន្ន មានសារៈសំខាន់ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ និងក្រុមដែលត្រូវបានគេមើលរំលង ព្រោះវាផ្តល់ឱ្យពួកគេនូវឱកាសលើកឡើងពីបញ្ហា តម្រូវការ និងសិទ្ធិរបស់ពួកគេ។ ការពិភាក្សាប្រកបដោយបរិយាបន្ន លើកទឹកចិត្តដល់ការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងលើកកម្ពស់សមភាពយេនឌ័រ សមធម៌ និងយុត្តិធម៌សង្គម។ នៅពេលដែលសំឡេងរបស់ពួកគេត្រូវបានរួមបញ្ចូល គេនឹងយល់ច្បាស់អំពីបញ្ហា ហើយដំណោះស្រាយនឹងកាន់តែមានប្រសិទ្ធភាព។

- ការពិភាក្សាប្រកបដោយបរិយាបន្ន ធានាថា គោលនយោបាយ និងកម្មវិធីឆ្លើយតបបានយ៉ាងសមស្របទៅនឹងបញ្ហាប្រឈមពិតប្រាកដដែលប្រជាពលរដ្ឋកំពុងជួបប្រទះ។ នៅពេលដែលសំឡេងរបស់ពួកគេត្រូវបានស្តាប់ឮ ការពិភាក្សាក៏ប្រែជាមានភាពពាក់ព័ន្ធ និងមានអត្ថន័យ។ គ្មាននរណាម្នាក់ត្រូវបានទុកចោលឡើយ ព្រោះមនុស្សគ្រប់រូបសុទ្ធតែត្រូវបានរាប់បញ្ចូល។ ការពិភាក្សាប្រកបដោយបរិយាបន្ន មិនមែនគ្រាន់តែជាការនិយាយនោះទេ ប៉ុន្តែជាការធានាថាសំឡេងត្រូវបានស្តាប់ឮយ៉ាងពិតប្រាកដ និងត្រូវបានពិចារណានៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីឱ្យសកម្មភាពដែលបានអនុវត្ត មានប្រសិទ្ធភាព ហើយឆ្លើយតបនឹងតម្រូវការរបស់ពួកគេ។

## ការពិភាក្សាស្របពេលគ្នា ២កៈ

# "ប្រព័ន្ធនវានុវត្តន៍ថ្នាក់តំបន់តាមរយៈ កិច្ចសហការរវាងសាកលវិទ្យាល័យ អាជ្ញាធរខេត្ត មន្ទីរជំនាញពាក់ព័ន្ធ និងវិស័យឧស្សាហកម្មនៅភូមិភាគពាយ័ព្យ នៃប្រទេសកម្ពុជា"

*រៀបចំដោយ សាកលវិទ្យាល័យជាតិបាត់ដំបង*



# សារតារ

សាកលវិទ្យាល័យ និងឧស្សាហកម្មនៅកម្ពុជា មិនសូវមានទំនាក់ទំនងគ្នានោះទេ ទោះបីជាទំនាក់ទំនងទាំងនេះអាចលើកកម្ពស់គុណភាពអប់រំ និងជួយអភិវឌ្ឍ ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់នវានុវត្តន៍ក៏ដោយ។ ដោយប្រើប្រាស់សំណាកអ្នកចូលរួម ៤៦នាក់ មកពីស្ថាប័នពាក់ព័ន្ធ Sam and Dahles ២០១៧ បានរកឃើញថា ទោះបីជាប្រភេទអ្នកពាក់ព័ន្ធ ដូចជា រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានឧត្តមសិក្សា និងឧស្សាហកម្ម ពិតជាបានចូលរួមក្នុងការអភិវឌ្ឍវិស័យឧត្តមសិក្សាក៏ដោយ ប៉ុន្តែកិច្ចសហការរបស់ពួកគេគឺមានតិចតួច។ យោងតាម Sam et al., ២០១៦ កម្ពុជាប្រឈមនឹងបញ្ហាមួយចំនួនក្នុងការតម្រង់ទិសវិស័យឧត្តមសិក្សាឱ្យឆ្ពោះទៅរកនិន្នាការក្នុងតំបន់ ឬពិភពលោក ដែលហាក់គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងផ្នែកសហគ្រិនភាព។ កង្វះទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងឧស្សាហកម្ម មានន័យថា សាកលវិទ្យាល័យនៅកម្ពុជា បាត់បង់ឱកាសក្នុងការធ្វើពិពិធកម្មប្រភពចំណូលរបស់ពួកគេ និងលើកកម្ពស់ការអប់រំឧត្តមសិក្សា និងការអភិវឌ្ឍសេដ្ឋកិច្ច។

ការបង្កើតគោលនយោបាយនៅថ្នាក់ខេត្ត នៅតែជាគោលគំនិតថ្មីមួយ។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវដែលបានធ្វើឡើងនៅខេត្តបាត់ដំបង បានរំលេចរបកគំហើញដ៏មានតម្លៃស្តីពីការកែលម្អប្រព័ន្ធអនុវត្តន៍កម្រិតភូមិភាគ។ ការសិក្សាទាំងនេះបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមបែបសហការរវាងសាកលវិទ្យាល័យ មន្ទីរជំនាញ និងតួអង្គឧស្សាហកម្ម ដើម្បីពង្រឹងសមត្ថភាពសហគ្រាសក្នុងមូលដ្ឋាន។ សមត្ថភាពផលិតកម្មក្នុងស្រុករបស់កម្ពុជាគឺនៅមានកម្រិត ជាពិសេសការផ្លាស់ប្តូរពីការពឹងផ្អែកលើស្តង់ដារ និងវត្ថុធាតុដើមនាំចូលទៅជាការប្រើប្រាស់វត្ថុធាតុដើមដែលផលិតក្នុងស្រុក។ ទោះបីជាផលិតកម្មក្នុងស្រុកមានការរីកចម្រើនក៏ដោយ ប៉ុន្តែនៅតែមានឧបសគ្គធំៗក្នុងផ្នែកស្ថិរភាពខ្សែចង្វាក់ផ្គត់ផ្គង់ រចនាសម្ព័ន្ធថ្លៃដើម សមត្ថភាពបច្ចេកវិទ្យា និងការសម្របសម្រួលស្ថាប័ន។

ការរកឃើញពីការស្រាវជ្រាវបង្ហាញថា យុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពបំផុត គឺត្រូវកំណត់រកបញ្ហាប្រឈមជាប្រព័ន្ធដែលសហគ្រាសជួបប្រទះជាប្រចាំថ្ងៃ ជាមុនសិន។ នៅពេលបានគូសវាសច្បាស់អំពីឧបសគ្គផ្នែករចនាសម្ព័ន្ធទាំងនេះ គេអាចរៀបចំដំណោះស្រាយបច្ចេកវិទ្យាចំគោលដៅ និងអន្តរាគមន៍ពង្រឹងសមត្ថភាពគ្រប់គ្រងឱ្យស្របតាមតម្រូវការនោះ។



## គោលបំណង

ការពិភាក្សាជាមួយវាគ្មិន ផ្តោតលើការពង្រឹងប្រព័ន្ធនវានុវត្តន៍កម្រិតភូមិភាគនៅក្នុងខេត្តបាត់ដំបង តាមរយៈកិច្ចសហការកាន់តែជិតស្និទ្ធរវាងសាកលវិទ្យាល័យ អាជ្ញាធរខេត្ត មន្ទីរជំនាញ និងសហគ្រាសក្នុងមូលដ្ឋាន។ គោលបំណងចម្បងគឺដើម្បីកំណត់បញ្ហាប្រឈមជាក់ស្តែង ដែលអាជីវកម្មក្នុងមូលដ្ឋានជួបប្រទះ និងស្វែងរកដំណោះស្រាយដែលមានការសម្របសម្រួល ដើម្បីបង្កើនភាពប្រកួតប្រជែង កាត់បន្ថយថ្លៃដើមផលិតកម្ម និងកសាងមូលដ្ឋានផលិតកម្មរឹងមាំក្នុងស្រុក។

## ការពិភាក្សា

ការពិភាក្សាបានគូសបញ្ជាក់ពីបញ្ហាប្រឈមជាប្រព័ន្ធ និងប្រទាក់ក្រឡាគ្នា នៅក្នុងវិស័យកែច្នៃកសិផលរបស់កម្ពុជា និងតម្រូវការដំណោះស្រាយឆ្លងវិស័យ ដែលមានការសម្របសម្រួល និងរឹងមាំជាងមុន ដោយរួមបញ្ចូលទស្សនៈពីសហគ្រាស រដ្ឋបាលខេត្ត និងមន្ទីរឧស្សាហកម្ម និងមន្ទីរកសិកម្ម។

**ទស្សនៈរបស់សហគ្រាសក្នុងមូលដ្ឋាន៖** តាមយោបល់របស់សហគ្រាស អ្នកផលិត និងសហគ្រាសក្នុងមូលដ្ឋានប្រឈមនឹងអស្ថិរភាពក្នុងការផ្គត់ផ្គង់វត្ថុធាតុដើមការបង្អាក់រំខានដែលទាក់ទងនឹងអាកាសធាតុ ចំណាយច្រើនលើថ្លៃអគ្គិសនី និងភស្តុភារ និងការពឹងផ្អែកលើធាតុចូលនាំចូល។ ឧបសគ្គទាំងនេះ បានកម្រិតលទ្ធភាពពង្រីកទីផ្សារ



រារាំងការប្រើប្រាស់ពេញលេញនូវសម្ភារឧបករណ៍ទំនើបៗ កាត់បន្ថយភាពប្រកួតប្រជែង និងរាំងស្ទះដល់វឌ្ឍនភាពឆ្ពោះទៅរកស្តង់ដារនាំចេញ។

**ទស្សនៈរបស់រដ្ឋបាលខេត្ត៖** នៅកម្រិតរដ្ឋបាលខេត្ត និងគិតពីជ្រុងគោលនយោបាយ មានការឯកភាពគ្នាយ៉ាងទូលំទូលាយថា បញ្ហាប្រឈមទាំងនេះមានលក្ខណៈជាប្រព័ន្ធ និងទាមទារឱ្យមានការឆ្លើយតបឆ្លងវិស័យ បែបរួមបញ្ចូលគ្នា។ ការដោះស្រាយបញ្ហារចនាសម្ព័ន្ធ ដូចជាអស្ថិរភាពក្នុងសកលលោក ការប្រែប្រួលតម្លៃថាមពល និងការបង្អាក់រំខានខ្សែចង្វាក់ផ្គត់ផ្គង់ជាបន្តបន្ទាប់ ត្រូវការចាំបាច់នូវការរៀបចំផែនការដោយមានការសម្របសម្រួល។ អាទិភាពសំខាន់ៗ រួមមានការពង្រឹងផលិតកម្មក្នុងស្រុក ជាពិសេសជាតុចូលសំខាន់ៗ ដូចជា ចំណីសត្វ និងជី ការពង្រឹងទំនាក់ទំនងរវាងកសិកម្ម និងឧស្សាហកម្មកែច្នៃ និងការកាត់បន្ថយការពឹងផ្អែកលើការនាំចូល។ អ្វីដែលសំខាន់ផងដែរនោះ គឺចាំបាច់ត្រូវស្តារទំនុកចិត្តអ្នកប្រើប្រាស់ឡើងវិញ តាមរយៈការគ្រប់គ្រងគុណភាពយ៉ាងតឹងរ៉ឹង ការកែលម្អស្តង់ដារអនាម័យ និងការបង្កើនតម្លាភាពក្នុងការអនុវត្តផលិតកម្ម។ ការរក្សាស្ថិរភាពទីផ្សារក្នុងស្រុក នៅតែជាចំណុចដែលត្រូវផ្តោតសំខាន់ភ្លាមៗ ព្រោះការធានាគុណភាពរឹងមាំ និងទំនុកចិត្តសាធារណៈគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការពង្រីកការនាំចេញនាពេលអនាគត។

**ទស្សនៈរបស់សាកលវិទ្យាល័យ៖**
វាគ្មិនមកពីសាកលវិទ្យាល័យនានា បានគូសបញ្ជាក់ពីសារៈសំខាន់នៃការខិតខំធ្វើយ៉ាងណាឱ្យការស្រាវជ្រាវ និងនវានុវត្តន៍កាន់តែបន្សុីគ្នានឹងតម្រូវការទីផ្សារ។ សាកលវិទ្យាល័យអាចដើរតួនាទីយ៉ាងសំខាន់ តាមរយៈការផ្តល់ការស្រាវជ្រាវដែល ជំរុញដោយតម្រូវការ ការសម្របសម្រួលការផ្ទេរបច្ចេកវិទ្យានិងការអភិវឌ្ឍកម្លាំងពលកម្មជំនាញ ដែលស្របតាមតម្រូវការឧស្សាហកម្ម។ ទោះជាយ៉ាងណា យន្តការសម្របសម្រួលរឹងមាំ គឺជាកត្តាចាំបាច់ដើម្បីផ្គូផ្គងតម្រូវការសហគ្រាសជាមួយនឹងសមត្ថភាពស្រាវជ្រាវដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយកិច្ចខិតខំប្រឹងប្រែងត្រួតគ្នា។ សាកលវិទ្យាល័យជាតិបាត់ដំបង មានគោលបំណងធ្វើឱ្យការស្រាវជ្រាវស្របទៅនឹងតម្រូវការជាក់ស្តែងរបស់សហគ្រាសធុនតូច និងមធ្យម និងបម្រើជាមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យា។ ក្នុងបរិបទនេះ មានការស្នើឱ្យបង្កើតយន្តការគូសផែនទីធនធាន ដើម្បីផ្សារភ្ជាប់តម្រូវការសហគ្រាសជាមួយនឹងអ្នកជំនាញផ្នែកសិក្សាធិការឱ្យកាន់តែប្រសើរ និងលើកកម្ពស់ប្រសិទ្ធភាពជារួម។

**ទស្សនៈពីវិស័យឧស្សាហកម្ម៖** វិស័យឧស្សាហកម្មក៏បានកត់សម្គាល់ផងដែរថា សហគ្រាសធុនតូច និងមធ្យម នៅតែបន្តប្រឈមនឹងបញ្ហាជាប់ជាប្រចាំ រួមមានលទ្ធភាពមានកម្រិតក្នុងការទទួលបានហិរញ្ញប្បទាន ចំណាយច្រើនលើថ្លៃភស្តុភារ និងការប្រកួតប្រជែងយ៉ាងខ្លាំងពីក្រុមហ៊ុនធំៗ។ ទោះបីជាមានផ្តល់ជូនការបណ្តុះបណ្តាលបច្ចេកទេស និងស្តង់ដារ ដូចជា GHP GMP GAP និង GAHP  ក៏ដោយ ប៉ុន្តែកម្រិតនៃការទទួលយកដោយសហគ្រាស នៅតែមិនស្មើគ្នា និងមិនទាន់ប្រើប្រាស់ឱ្យអស់សក្តានុពលនៅឡើយ។ ស្ថាប័នពាក់ព័ន្ធបានសង្កត់ធ្ងន់លើតម្រូវការពង្រឹងការចូលរួមរបស់វិស័យឯកជន និងជំរុញកិច្ចសហការឱ្យកាន់តែជិតស្និទ្ធជាមួយសាកលវិទ្យាល័យ ដើម្បីបង្កើនសមត្ថភាពផលិតកម្ម និងការអនុលោមតាមស្តង់ដារ។ ការលើកកម្ពស់វប្បធម៌នៃការបន្តរៀនសូត្រ និងការបន្សុាំខ្លួន នឹងមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការបង្កើនផលិតភាព គុណភាពផលិតផល និងភាពប្រកួតប្រជែងជារួម។

**ទស្សនៈរបស់មន្ទីរកសិកម្ម៖** មន្ទីរកសិកម្មបានពិភាក្សាអំពីយុទ្ធសាស្ត្រសំខាន់ៗ ដែលផ្តោតលើការពង្រឹងសមត្ថភាពផលិតកម្ម តាមរយៈការអនុម័តស្តង់ដារដូចជា GAP និង GAHP ការរៀបចំកសិករទៅជាសហគមន៍ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ និងការពង្រីកការរៀបចំកសិកម្មតាមកិច្ចសន្យា ដើម្បីធានាបានលំនឹងនៃការផ្គត់ផ្គង់ និងគុណភាពថេរសម្រាប់ក្រុមហ៊ុនកែច្នៃ។ វិធានការទាំងនេះមានសារៈសំខាន់ណាស់ចំពោះការកែលម្អការសម្របសម្រួលនៅទូទាំងខ្សែចង្វាក់តម្លៃ និងការជំរុញដំណើរការរបស់វិស័យទាំងមូល។ ទោះជាយ៉ាងណាបញ្ហាប្រឈមជាបន្តបន្ទាប់ រួមមានផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងកង្វះខាតហេដ្ឋារចនាសម្ព័ន្ធនៅតែបន្តរាំងស្ទះដល់ផលិតភាព និងភាពប្រកួតប្រជែង។ ការដោះស្រាយហានិភ័យទាំងនេះ ជាគន្លឹះសំខាន់ដើម្បីរក្សាកំណើនរយៈពេលវែង និងភាពធន់នៅក្នុងវិស័យកសិកម្ម។

> សរុបមក ការពិភាក្សាបានសង្កត់ធ្ងន់ថា ការពង្រឹងទីផ្សារក្នុងស្រុក ត្រូវតែធ្វើឡើងមុនការពង្រីកការនាំចេញ។ ការបង្កើនគុណភាពផលិតផល ការកាត់បន្ថយថ្លៃដើមផលិតកម្ម និងការកែលម្អការធ្វើសមាហរណកម្មខ្សែចង្វាក់ផ្គត់ផ្គង់ នឹងទាមទារឱ្យមានសកម្មភាពសម្របសម្រួលរវាងទីភ្នាក់ងាររដ្ឋាភិបាល សាកលវិទ្យាល័យ និងវិស័យឯកជន។ ការធានាសុវត្ថិភាពចំណីអាហារ និងការអនុលោមតាមស្តង់ដារ ទន្ទឹមនឹងការជំរុញការរៀនសូត្រជាបន្តបន្ទាប់ និងនវានុវត្តន៍ គឺជាកត្តាចាំបាច់ដើម្បីកសាងទំនុកចិត្តអ្នកប្រើប្រាស់ និងភាពប្រកួតប្រជែងឡើងវិញ។ ក្នុងន័យនេះ ការបង្កើតយន្តការសម្របសម្រួលកម្រិតភូមិភាគ ទោះផ្លូវការ ឬក្រៅផ្លូវការក៏ដោយ នឹងមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធ្វើឱ្យកសិកម្ម ឧស្សាហកម្ម ការស្រាវជ្រាវ និងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ខេត្ត កាន់តែស៊ីសង្វាក់គ្នា ដោយត្រួសត្រាយផ្លូវនាំទៅរក កំណើនប្រកបដោយនិរន្តរភាព និងការត្រៀមខ្លួនរួចជាស្រេចសម្រាប់ការនាំចេញនាពេលអនាគត។

## វាគ្មិន និងអ្នកសម្របសម្រួល

---

វាគ្មិន

**លោក ទេព នារ៉ា**
*សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិបាត់ដំបង*

**ឯកឧត្តម មូល ធន**
*អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង*

**លោកស្រី ហួរ ដានី**
*អនុប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*

**លោកបណ្ឌិត ប៉ុញ ឧត្តម**
*អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

**លោកស្រី អ៊ូច សុម៉ាលី**
*ម្ចាស់សហគ្រាស សីហាម៉ាលី (សហគ្រាសផលិតណែម និងប្រហុក/ផ្អកបាត់ដំបង)*

---

អ្នកសម្របសម្រួល

**លោកបណ្ឌិត ថាច់ ប៊ុនរឿន**
*ព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យជាតិបាត់ដំបង*

## ការពិភាក្សាស្របពេលគ្នា ២ខ៖

# "ការពង្រឹងកិច្ចគាំពារសង្គមសម្រាប់ពលករចំណាកស្រុកកម្ពុជា នៅក្នុងប្រទេស"

*រៀបចំដោយ មជ្ឈមណ្ឌលសំរាប់ការវិភាគបញ្ហាអភិវឌ្ឍន៍*



# សារតោរ

ប្រទេសកម្ពុជាសំបូរកម្លាំងពលកម្ម ប៉ុន្តែមិនសូវមានឱកាសការងារនៅក្នុងសហគមន៍មូលដ្ឋាន។ ហេតុនេះហើយទើបកម្មករខ្មែរជាច្រើន សម្រេចចិត្តធ្វើចំណាកស្រុកទៅប្រទេសជិតខាង ជាពិសេសប្រទេសថៃ ដើម្បីស្វែងរកប្រាក់ចំណូលប្រសើរជាងមុន និងការងារដែលមានស្ថិរភាពជាងមុន។ ជារឿយៗ ការសម្រេចចិត្តធ្វើចំណាកស្រុក រងឥទ្ធិពលពីសមាជិកគ្រួសារដែលកំពុងធ្វើការនៅទីនោះស្រាប់ ក្តីសង្ឃឹមថានឹងទទួលបានជំនាញថ្មីៗ និងឱកាសលើកស្ទួយជីវភាព។

យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០២៣ មានប្រជាពលរដ្ឋខ្មែរប្រមាណ ១,២ លាននាក់កំពុងធ្វើការនៅក្រៅប្រទេស ហើយក្នុងចំណោមនោះ ប្រមាណ ៩២% កំពុងធ្វើការនៅប្រទេសថៃ។ ខណៈដែលការធ្វើចំណាកស្រុកជួយឱ្យគ្រួសារទទួលបានប្រាក់ចំណូល វាក៏បង្កើតជាបញ្ហាប្រឈមជាច្រើននៅក្នុងសង្គមផងដែរ ជាពិសេសសម្រាប់ពលករដែលវិលត្រឡប់មកវិញ និងកូនៗរបស់ពួកគេ។ គ្រួសារពលករចំណាកស្រុកជាច្រើន ជាពិសេសអ្នកដែលគ្មានឯកសារស្របច្បាប់ ប្រឈមការលំបាកក្នុងការទទួលបានសេវាគាំពារសង្គម ដូចជា ការថែទាំសុខភាព ការអប់រំ និងកម្មវិធីគាំទ្ររបស់រដ្ឋាភិបាល ដូចជា ប័ណ្ណសមធម៌ (IDPoor) ជាដើម។

ការស្រាវជ្រាវបែបគុណវិស័យ ដោយផ្អែកលើបទសម្ភាសន៍ស៊ីជម្រៅនៅខេត្តពោធិ៍សាត់ បាត់ដំបង និងបន្ទាយមានជ័យ ដែលមានអ្នកចូលរួមសរុប ៩០ នាក់ បានរកឃើញថា ពលករចំណាកស្រុកភាគច្រើនមិនមានប័ណ្ណសមធម៌នោះទេ ទោះបីនេះជាឯកសារដែលអាចផ្តល់អត្ថប្រយោជន៍ដល់ពួកគេនៅក្នុងប្រទេសកម្ពុជាដែលជាប្រទេសកំណើតរបស់ពួកគេក៏ដោយ។ ក្នុងឆ្នាំ២០២៤-២០២៥ មជ្ឈមណ្ឌលសិក្សាប់ការវិភាគបញ្ហាអភិវឌ្ឍន៍ បានធ្វើការជាមួយនាយករង និងសិស្សានុសិស្សមកពីវិទ្យាល័យកំរៀង ប្រមាណ ៣០ នាក់ ដើម្បីរៀបចំការស្រាវជ្រាវ និងការប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថល ដោយចុះអនុវត្តផ្ទាល់នៅមូលដ្ឋាន។ ក្រុមយុវជនបានសម្ភាសប្រជាជនប្រមាណ ៣១៩ គ្រួសារ ដោយផ្តោតលើស្រុកកំរៀង ជាពិសេសឃុំអូរដា និងឃុំបឹងរាំង។ លទ្ធផលបង្ហាញថា ពលករចំណាកស្រុកដែលមានប័ណ្ណឆ្លងដែន នៅតែប្រឈមការលំបាក នៅពេលត្រឡប់មកប្រទេសកម្ពុជាវិញក្នុងអំឡុងជំងឺរាតត្បាតកូវីដ-១៩។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺមានគ្រួសារដែលក្រីក្រ ប៉ុន្តែមិនទាន់ទទួលបានប័ណ្ណសមធម៌ ឬប័ណ្ណក្រីក្រ ហើយចំណុចនេះបានធ្វើឱ្យរាំងស្ទះដល់ការទទួលបានសេវាថែទាំសុខភាព និងសេវាផ្សេងៗទៀត។

ក្នុងរយៈពេលមួយឆ្នាំជាមួយកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ក្រុមការងារមជ្ឈមណ្ឌលសម្រាប់ការវិភាគបញ្ហាអភិវឌ្ឍន៍ បានផ្តោតលើ ៤ ដំណាក់កាល៖ ១) ការរៀបចំការស្រាវជ្រាវជាមួយយុវជន ២) ការចុះអនុវត្តនៅមូលដ្ឋានផ្ទាល់ជាមួយយុវជន និងការផលិតការរកឃើញ ៣) ការបណ្តុះបណ្តាលយុវជនមកពីក្រុមប្រឹក្សាឃុំស្តីពីកម្មវិធីវិនិយោគឃុំ និង ៤) ការប្រើប្រាស់លទ្ធផលពីការស្រាវជ្រាវ សម្រាប់ធ្វើបទបង្ហាញ និងតស៊ូមតិដើម្បីផលប្រយោជន៍សហគមន៍ នៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ និងវេទិកាផ្សេងៗទៀត។

ការស្រាវជ្រាវដែលធ្វើឡើងដោយ មជ្ឈមណ្ឌលសំរាប់ការវិភាគបញ្ហាអភិវឌ្ឍន៍ បានបង្ហាញថា ជារឿយៗ កូនៗរបស់ពលករចំណាកស្រុកជួបប្រទះការលំបាកក្នុងការទទួលបានការអប់រំ និងការថែទាំសមរម្យ ក្នុងពេលរស់នៅឬធ្វើការឆ្លងដែន។ គ្រួសារខ្លះត្រូវបែកបាក់គ្នាក្នុងអំឡុងពេលធ្វើចំណាកស្រុក ដែលបង្កើនភាពងាយរងគ្រោះសម្រាប់កុមារ និងស្ត្រី។ ការស្រាវជ្រាវដែលដឹកនាំដោយយុវជននៅក្នុងស្រុកកំរៀង ក៏បានបង្ហាញពីរបៀបដែលយុវជនអាចជួយដល់អាជ្ញាធរមូលដ្ឋាន តាមរយៈការប្រមូលទិន្នន័យ និងជួយលើកយកបញ្ហាពលករចំណាកស្រុកទៅដាក់ក្នុងការពិភាក្សាកម្មវិធីវិនិយោគឃុំផងដែរ។

## គោលបំណង

ការពិភាក្សាជាមួយវាគ្មិននេះ ផ្តោតលើប្រធានបទសំខាន់ៗចំនួន ៥ រួមមានបញ្ហានៃការធ្វើចំណាកស្រុកជាទូទៅ របៀបដែលបញ្ហានានាត្រូវបានដោះស្រាយនៅក្នុងផែនការអភិវឌ្ឍន៍ របៀបដាក់បញ្ចូលការធ្វើចំណាកស្រុកទៅក្នុងកម្មវិធីវិនិយោគឃុំ តួនាទីនៃការស្រាវជ្រាវ និងការស្រាវជ្រាវដែលដឹកនាំដោយយុវជន ទាក់ទងនឹងកម្មវិធីវិនិយោគឃុំ និងដំណើរឆ្ពោះទៅមុខ។

## ការពិភាក្សា

**ការទទួលស្គាល់បញ្ហា៖** គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ប្រមូលព័ត៌មានស្តីពីពលករចំណាកស្រុក រួមមានយេនឌ័រ ស្ថានភាពភាពក្រីក្រ (ក្រ១ និងក្រ២)និងសមាសភាពគ្រួសារ។ ពលករចំណាកស្រុក ជាច្រើនគឺជាយុវជន និងកុមារ ហើយឪពុកម្តាយខ្លះធ្វើចំណាកស្រុកដោយទុកកូននៅផ្ទះ។ ទន្ទឹមនឹងនេះ មន្ត្រីឃុំកត់ត្រាអំពីពលករចំណាកស្រុកដែលវិលត្រឡប់មកពីប្រទេសថៃ និងរាយការណ៍ព័ត៌មានទៅថ្នាក់លើ។ ក្នុងករណីខ្លះ ពលករចំណាកស្រុកត្រូវបានបណ្តេញចេញ ឬចាប់ដាក់ពន្ធនាគារក្នុងអំឡុងពេលមានជម្លោះព្រំដែន។ គ្រួសារដែលវិលត្រឡប់មកកម្ពុជាវិញ រាយការណ៍ជូនឃុំ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ ដូចជា ប័ណ្ណសមធម៌។ អនុប្រធានភូមិទទួលព័ត៌មានពីពលករចំណាកស្រុកផ្ទាល់ ដើម្បីរាយការណ៍ទៅថ្នាក់ឃុំ ដោយមានលក្ខខណ្ឌតម្រូវពិសេសសម្រាប់កុមារអាយុក្រោម ៥ ឆ្នាំ ដើម្បីរៀបចំតម្រូវការចាំបាច់សម្រាប់ពួកគេ។ មណ្ឌលទទួលពលករកំរៀង ក៏បានទទួលពលករចំណាកស្រុកចំនួន ៣.៣៣២ នាក់ នៅក្នុងខែមករា ឆ្នាំ២០២៦ ផងដែរ ដែលក្នុងនោះរួមមានទាំងស្ត្រី កុមារ និងមនុស្សចាស់។ ថ្មីៗនេះមានពលករចំណាកស្រុកចំនួន ២០០ នាក់ បានឆ្លងដែនតាមច្រករបៀងធម្មជាតិ ដែលប្រឈមនឹងហានិភ័យសុខភាព និងសុវត្ថិភាពក្នុងអំឡុងពេលធ្វើដំណើរ។ មណ្ឌលផ្តល់ជំនួយភ្លាមៗ ដូចជា អាហារ ការពិនិត្យសុខភាព និងការសង្គ្រោះបឋម ហើយក៏ជួយដល់ពលករចំណាកស្រុកដោយផ្តល់ព័ត៌មានអំពីឯកសារច្បាប់ និងការអប់រំផងដែរ។



**ការដាក់បញ្ចូលបញ្ហាពលករចំណាកស្រុកទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ៖** គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ អនុវត្តតាមដំណើរការ ៣ជំហាន គឺការប្រមូលទិន្នន័យ ការកំណត់បញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋ និងការផ្តោតអាទិភាពលើបញ្ហាសំខាន់ៗ។ បញ្ហាពលករចំណាកស្រុក ត្រូវបានលើកមកពិចារណានៅដំណាក់កាលកំណត់បញ្ហា ប៉ុន្តែនៅតែមានចន្លោះប្រហោងក្នុងការដាក់បញ្ចូលព័ត៌មានពលករចំណាកស្រុកឱ្យបានពេញលេញទៅក្នុងការរៀបចំផែនការឃុំ។ វិស័យមួយចំនួន ជាពិសេសកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានគោលបំណងរួមបញ្ចូល និងដោះស្រាយតម្រូវការរបស់ពលករចំណាកស្រុក។ មណ្ឌលទទួលពលករកំរៀង ជួយដល់ពលករចំណាកស្រុក ដោយផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ។ មណ្ឌលក៏បានគូសបញ្ជាក់ផងដែរនូវភាពខុសគ្នារវាងការបញ្ជូនពលករចំណាកស្រុកត្រឡប់ទៅសហគមន៍កំណើតរបស់ពួកគេវិញ និងការធ្វើសមាហរណកម្មពលករចំណាកស្រុកទៅក្នុងប្រព័ន្ធគាំទ្រដ៏ទូលំទូលាយនៅទូទាំងខេត្ត។



**ការដាក់បញ្ចូលបញ្ហាពលករចំណាកស្រុកទៅក្នុងកម្មវិធីវិនិយោគឃុំ៖** មិនមានបញ្ហាប្រឈមធំដុំពាក់ព័ន្ធនឹងពលករចំណាកស្រុកទេ ព្រោះឃុំបានបែងចែកថវិការួចហើយ និងបានបញ្ចូលបញ្ហាទាំងនេះទៅក្នុងផែនការសកម្មភាព។ ពលករចំណាកស្រុកទទួលបានជំនួយ ដូចជា កញ្ចប់ស្បៀងអាហារ ប័ណ្ណសមធម៌ និងប្រាក់ឧបត្ថម្ភប្រចាំខែ (២៨០.០០០ រៀល) នៅពេលចូលរួមក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ អាជ្ញាធរក៏ជួយពលករចំណាកស្រុកឱ្យទទួលបានឯកសារស្របច្បាប់ និងផ្តល់ព័ត៌មានអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងស្របច្បាប់ផងដែរ។ ក្រៅពីនេះ ដៃគូអភិវឌ្ឍន៍បានចូលរួមចំណែកតាមរយៈការទ្រទ្រង់ឱកាសប្រកបរបរចិញ្ចឹមជីវិត ដូចជា ការផ្តល់មាន់ និងសម្ភារ ដើម្បីជួយពលករចំណាកស្រុកឱ្យចាប់ផ្តើមអាជីវកម្មខ្នាតតូច ឬសកម្មភាពកសិកម្ម។

**តួនាទីនៃការស្រាវជ្រាវ និងការស្រាវជ្រាវដែលដឹកនាំដោយយុវជន នៅក្នុងការរៀបចំផែនការឃុំ៖** នាយករងដែលជាវាគ្មិននៅក្នុងការពិភាក្សា បានទទួលស្គាល់សមត្ថភាពរបស់សិស្សានុសិស្ស ដែលបានចូលរួមនៅក្នុងដំណើរការស្រាវជ្រាវនេះ ដោយពួកគេបានជួយបង្កើនសុក្រឹតភាពនៃទិន្នន័យ។ មេភូមិជាច្រើនមិនសូវថ្នឹកជាមួយឧបករណ៍ឌីជីថល ហើយយុវជនអាចជួយបំពេញចន្លោះប្រហោងនេះបាន តាមរយៈការជួយប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថល និងការចែករំលែកព័ត៌មានតាមរយៈកម្មវិធីវិនិយោគឃុំ។ មណ្ឌលទទួលពលករកំរៀង ក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរឃុំ តាមរយៈកិច្ចប្រជុំប្រចាំខែ និងការចែករំលែកទិន្នន័យផងដែរ។ កិច្ចសហការនេះជួយពង្រឹងការទំនាក់ទំនង និងលើកកម្ពស់បរិយាបន្ន តាមរយៈការភ្ជាប់ទំនាក់ទំនងយុវជនជាមួយនឹងអាជ្ញាធរមូលដ្ឋាន។

**ដំណើរឆ្ពោះទៅមុខ៖** ក្តីបារម្ភចម្បងមួយ គឺពលករចំណាកស្រុកជាច្រើនខ្វះឯកសារស្របច្បាប់ត្រឹមត្រូវ ដែលបង្កជាបញ្ហាប្រឈមដល់ការការពារ និងការធ្វើសមាហរណកម្មឡើងវិញ។ អាជ្ញាធរត្រូវបានលើកទឹកចិត្តឱ្យមានភាពបត់បែនជាងមុន នៅពេលជួយគាំទ្រដល់ពលករចំណាកស្រុកដែលគ្មានឯកសារ។ ពលករចំណាកស្រុកក៏គួរតែត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងកិច្ចប្រជុំឃុំផងដែរ ដើម្បីអាចបញ្ចូលសំឡេងរបស់ពួកគេទៅក្នុងការរៀបចំផែនការថ្នាក់មូលដ្ឋាន។

ការខិតខំប្រឹងប្រែងនាពេលអនាគត គួរតែផ្តោតលើការបង្កើនកម្រិតជីវភាពរបស់ពលករចំណាកស្រុក តាមរយៈការគាំទ្រដល់របរចិញ្ចឹមជីវិតដែលមាននិរន្តរភាព ដូចជា ការដាំបន្លែ និងសកម្មភាពបង្កើតប្រាក់ចំណូលផ្សេងទៀត។

> ការពិភាក្សាជារួម បានផ្តល់នូវការយល់ដឹងដ៏សំខាន់ តាមរយៈកិច្ចសហការនៅថ្នាក់ក្រោមជាតិ ដែលអនុញ្ញាតឱ្យយុវជនទទួលបានបទពិសោធន៍ និងជួយជ្រោមជ្រែងក្នុងការប្រមូលទិន្នន័យ។ ការពិភាក្សាបានគូសបញ្ជាក់ពីតម្រូវការកិច្ចការពារផ្លូវច្បាប់សម្រាប់ពលករចំណាកស្រុកដែលវិលត្រឡប់មកផ្ទះវិញ និងវិស័យគាំទ្រសំខាន់ៗផ្សេងទៀត។ ដើម្បីពង្រឹងកិច្ចគាំពារសង្គមសម្រាប់ពលករចំណាកស្រុកកម្ពុជា ចាំបាច់ត្រូវមានការសម្របសម្រួលកាន់តែប្រសើររវាងអាជ្ញាធរមូលដ្ឋាន សហគមន៍ យុវជន និងដៃគូអភិវឌ្ឍន៍។



# វាគ្មិន និងអ្នកសម្របសម្រួល

វាគ្មិន

**លោក ឡុង ចំរើន**
*នាយករងវិទ្យាល័យកំរៀង*

**លោក រិទ្ធិ សុធីរ៉ា**
*អនុប្រធានភូមិ*

**កញ្ញា លន ម៉ាឡា**
*គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ*

**កញ្ញា ប៉ែន ពិន**
*ជំនួយការរដ្ឋបាលឃុំ*

**លោក ហែម ប៊ុនហ៊ាន**
*នាយកប្រតិបត្តិនៃមណ្ឌលទទួលពលករកំរៀង*

អ្នកសម្របសម្រួល

**លោក អ៊ីល អឿ**
*នាយកប្រតិបត្តិមជ្ឈមណ្ឌលសំរាប់ការវិភាគបញ្ហាអភិវឌ្ឍន៍*




ឯកឧត្តម ថោង សុគន្ធ

អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការបរិស្ថាន
និងហេដ្ឋារចនាសម្ព័ន្ធនៃទីស្តីការគណៈរដ្ឋមន្ត្រី

# សុន្ទរកថាបិទកម្មវិធី

“

សាកលវិទ្យាល័យ  អ្នករៀបចំគោលនយោបាយជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ តំណាងសហគមន៍ អង្គការសង្គមស៊ីវិល និងដៃគូស្រាវជ្រាវ បានជួបជុំគ្នានៅទីនេះក្នុងថ្ងៃនេះ ដើម្បីចូលរួមក្នុងការពិភាក្សាដ៏មានអត្ថន័យ និងរៀនសូត្រពីគ្នាទៅវិញទៅមក។ ការយល់ដឹងដែលបានចែករំលែក ចាប់ពីគំនិតផ្តួចផ្តើមបន្សាំនឹងការប្រែប្រួលអាកាសធាតុ រហូតដល់ការរៀបចំថវិកាមូលដ្ឋានប្រកបដោយបរិយាបន្ន កិច្ចគាំពារសង្គមសម្រាប់ពលករចំណាកស្រុក និងប្រព័ន្ធនវានុវត្តន៍កម្រិតភូមិភាគ បានបង្ហាញពីភាពសម្បូរបែបនៃបទពិសោធន៍ក្នុងមូលដ្ឋាន និងគូសបញ្ជាក់ពីសារៈសំខាន់នៃការស្តាប់ដោយយកចិត្តទុកដាក់នូវអ្វីដែលសហគមន៍កំពុងប្រាប់យើងនៅពេលនេះ។

ឯកឧត្តម បានផ្តល់នូវការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនមួយចំនួន។ នៅពេលដែលលោកបានចូលរួមជាលើកដំបូងក្នុងគណៈកម្មាធិការប្រឹក្សាផ្នែកបច្ចេកទេសរបស់កម្មវិធីពន្លកចំណេះ លោកចង់ស្វែងយល់ឱ្យកាន់តែច្បាស់អំពីរបៀបដែលការស្រាវជ្រាវ និងការពិភាក្សា អាចគាំទ្រដល់ការងាររបស់រាជរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសនៅថ្នាក់ក្រោមជាតិ។ បើតាមទីស្តីការគណៈរដ្ឋមន្ត្រី ការទទួលខុសត្រូវរបស់យើងគឺជានាសង្គតិភាពនៃគោលនយោបាយ ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងការអនុវត្តយ៉ាងស៊ីសង្វាក់គ្នានៅទូទាំងវិស័យ និងកម្រិតរដ្ឋបាលទាំងអស់។

ក្នុងន័យនេះ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ផ្តល់នូវក្របខ័ណ្ឌជាតិដ៏ទូលំទូលាយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា។ យុទ្ធសាស្ត្របញ្ចកោណ  តម្កល់ប្រជាពលរដ្ឋជាចំណុចស្នូលនៃគោលនយោបាយ ដោយសង្កត់ធ្ងន់លើអភិបាលកិច្ចល្អ ប្រសិទ្ធភាពស្ថាប័ន និរន្តរភាព និងកំណើនប្រកបដោយបរិយាបន្ន នៅទូទាំងវិស័យ និងកម្រិតរដ្ឋបាលទាំងអស់។

ការពិភាក្សាក្នុងវេទិកាគោលនយោបាយថ្នាក់ខេត្ត ឆ្នាំ២០២៦ បានផ្តល់ការយល់ដឹងកាន់តែច្បាស់លាស់ និងជាក់ស្តែង។ យើងបានស្តាប់នូវឧទាហរណ៍ជាក់ស្តែងពីបណ្តាខេត្តនានាអំពីរបៀបដែលទិន្នន័យក្នុងមូលដ្ឋានត្រូវបានប្រើប្រាស់ របៀបដែលសហគមន៍ត្រូវបានជំរុញឱ្យចូលរួម និងបញ្ហាប្រឈមដែលនៅសេសសល់។ ទាំងនេះមិនមែនជាការឆ្លុះបញ្ចាំងបែបអរូបីនោះទេ ប៉ុន្តែវាតំណាងឱ្យតថភាពជាក់ស្តែងរបស់រដ្ឋបាលខេត្ត ស្រុក ឃុំ ព្រមទាំងសហគមន៍ដែលពួកគេផ្តល់សេវាជូន។ ចំណុចដែលខ្ញុំចាប់អារម្មណ៍បំផុត គឺតួអង្គថ្នាក់ខេត្តកំពុងដោះស្រាយបញ្ហាប្រឈមដ៏ស្មុគស្មាញ ដែលកើតឡើងជាញឹកញាប់នៅក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ។ ក្នុងបរិបទនេះ ទិន្នន័យ និងអភិបាលកិច្ចគឺពាក់ព័ន្ធគ្នា ព្រោះទិន្នន័យជាឧបករណ៍ដ៏សំខាន់ ដែលជួយឱ្យអាជ្ញាធរមូលដ្ឋានធ្វើសេចក្តីសម្រេចចិត្តដោយទទួលបានព័ត៌មានគ្រប់គ្រាន់ បែងចែកធនធានប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបយ៉ាងសមស្របទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

”

តាមបទពិសោធន៍របស់ខ្ញុំ គោលនយោបាយដែលជំរុញដោយទិន្នន័យ និងប្រកបដោយបរិយាបន្ន ដែលចាត់ទុកប្រជាពលរដ្ឋជាចំណុចស្នូល គឺជាគន្លឹះសំខាន់ក្នុងការប្រែក្លាយយុទ្ធសាស្ត្រពញ្ញកោណ ដំណាក់កាលទី ១ ទៅជាលទ្ធផលជាក់ស្តែង។ យុទ្ធសាស្ត្រជាតិមួយអាចទទួលបានជោគជ័យ លុះត្រាតែវាទទួលបានធាតុចូលពីគ្រប់មជ្ឈដ្ឋាន ជាពិសេសពីថ្នាក់មូលដ្ឋាន និងប្រសិនបើមានការគាំទ្រដោយកិច្ចសហការបែបស្ថាបនា រវាងសហគមន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នថ្នាក់ជាតិ។

វេទិកានេះបញ្ជាក់ជាថ្មីថា គោលនយោបាយប្រកបដោយប្រសិទ្ធភាព ត្រូវតែផ្អែកលើការអនុវត្តជាក់ស្តែង។ នេះមិនត្រឹមតែទាមទារឱ្យមានការតម្រង់ទិសច្បាស់លាស់នៅថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានការផ្តល់មតិស្ថាបនាជាបន្តបន្ទាប់ពីបណ្តាខេត្ត និងសហគមន៍ អំពីអ្វីដែលដំណើរការបានល្អ និងអ្វីដែលត្រូវមានការកែសម្រួលផងដែរ។ វេទិកានានាដូចជា វេទិកានេះ បានផ្តល់នូវយន្តការដ៏មានតម្លៃសម្រាប់ការផ្លាស់ប្តូរយោបល់ និងរៀនសូត្រពីគ្នាទៅវិញទៅមក។

យើងបានស្តាប់ពីវិធីសាស្ត្រចម្រុះសម្រាប់ការស្រាវជ្រាវដែលមានការចូលរួម ការធ្វើឱ្យព័ត៌មានងាយស្រួលទទួលបានសម្រាប់ក្រុមគោលដៅផ្សេងៗ និងការរៀបចំការពិភាក្សាប្រកបដោយបរិយាបន្ននៅទូទាំងខេត្ត និងសហគមន៍នានា។ វេទិកានេះបានសង្កត់ធ្ងន់លើការពិភាក្សាប្រកបដោយបរិយាបន្ន។ បរិយាបន្នមិនមែនគ្រាន់តែជាការចូលរួមកិច្ចប្រជុំនោះទេ ប៉ុន្តែជាការស្វែងយល់ថាតើក្រុមផ្សេងៗទទួលបានបទពិសោធន៍បែបណាពីគោលនយោបាយនៅមូលដ្ឋាន និងការធានាថា ទស្សនៈរបស់ពួកគេផ្តល់ព័ត៌មានដល់ការធ្វើសេចក្តីសម្រេចចិត្ត។ នេះជាចំណុចសំខាន់បំផុតសម្រាប់អភិបាលកិច្ចមូលដ្ឋាន ដែលខ្វះមិនបាននូវទំនុកចិត្តរវាងអាជ្ញាធរ និងសហគមន៍។

សរុបមក ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី យើងបានសង្កេតឃើញកម្លាំងផ្តួបរឹងមាំរវាងការពិភាក្សានាថ្ងៃនេះ និងកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់យើងក្នុងការពង្រឹងការសម្របសម្រួលការជំរុញវិមជ្ឈការ និងការកែលម្អការផ្តល់សេវាសាធារណៈ។ ការលើកកម្ពស់ការប្រើប្រាស់ទិន្នន័យក្នុងមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងការជំរុញការពិភាក្សាប្រកបដោយបរិយាបន្ន គឺជាកត្តាសំខាន់សម្រាប់ការធានាថា យុទ្ធសាស្ត្រជាតិផ្តល់នូវអត្ថប្រយោជន៍ជាក់ស្តែងដល់ប្រជាពលរដ្ឋគ្រប់រូប និងរួមចំណែកដល់ការសម្រេចបានអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល។

**ក្នុងន័យនេះ យើងចាំបាច់ត្រូវប្រែក្លាយការពិភាក្សាក្នុងវេទិកាគោលនយោបាយថ្នាក់ខេត្តទៅជាសកម្មភាពជាក់ស្តែង៖**

- សម្រាប់អាជ្ញាធរខេត្ត៖ បន្តចូលរួមយ៉ាងសកម្មជាមួយសហគមន៍ ប្រមូល និងវិភាគទិន្នន័យជាប្រព័ន្ធ និងសម្រេចចិត្តដោយផ្អែកលើភស្តុតាងច្បាស់លាស់។

- សម្រាប់អ្នកតាក់តែងគោលនយោបាយជាតិ៖ ប្រើប្រាស់ការយល់ដឹងថ្នាក់ខេត្តដែលបានចែករំលែកនៅថ្ងៃនេះ ជាធាតុចូលដ៏មានតម្លៃសម្រាប់យុទ្ធសាស្ត្រ និងការសម្រេចចិត្តគោលនយោបាយដែលប្រកបដោយបរិយាបន្ន និងឆ្លើយតបនឹងបរិបទ។

- សម្រាប់សង្គមស៊ីវិល និងសហគមន៍៖ បន្តជួយបន្លឺសំឡេងអំពីស្ត្រី យុវជន ជនមានពិការភាព ជនជាតិដើមភាគតិច អ្នករស់នៅតំបន់ដាច់ស្រយាល និងក្រុមងាយរងគ្រោះដទៃទៀត ដែលកម្រត្រូវបានគេឮ ឱ្យកាន់តែលាន់ឮខ្លាំងឡើង។

- សម្រាប់អ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ៖ បន្តការប្តេជ្ញាចិត្តរបស់អ្នកក្នុងការផលិតការស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់ និងជាក់ស្តែង ដែលអ្នកតាក់តែងគោលនយោបាយអាចយកទៅអនុវត្តបានយ៉ាងងាយស្រួល។

វេទិកានេះមិនមែនជាចំណុចបញ្ចប់នោះទេ ប៉ុន្តែជាបង្គោលចរមួយនៅក្នុងដំណើរដ៏បន្តបន្ទាប់។ ទំនាក់ទំនងដែលបានបង្កើតឡើង បណ្តាញដែលបានពង្រឹង និងមេរៀនដែលបានចែករំលែកនៅថ្ងៃនេះ គឺជាទ្រព្យសម្បត្តិដ៏មានតម្លៃសម្រាប់កែលម្អការបង្កើតគោលនយោបាយ ការរៀបចំផែនការខេត្ត និងយុទ្ធសាស្ត្រជាតិនៅឆ្នាំបន្តបន្ទាប់ទៀត។

សូមថ្លែងអំណរគុណដល់រដ្ឋាភិបាលអូស្ត្រាលី អង្គការមូលនិធិអាស៊ី ស្ថាប័នស្រាវជ្រាវនៅកម្ពុជា សាកលវិទ្យាល័យ និងដៃគូទាំងអស់ ដែលបានសហការរៀបចំវេទិកានេះឡើង ហើយក៏សូមថ្លែងអំណរគុណជាពិសេសចំពោះអ្នកចូលរួមមកពីបណ្តាខេត្ត និងសហការីនៅថ្នាក់ក្រោមជាតិ សម្រាប់ភាពបើកចំហ ការលះបង់ និងការប្តេជ្ញាចិត្តរបស់អ្នកទាំងអស់គ្នា ដើម្បីកសាងកម្ពុជាមួយ ដែលប្រកបដោយបរិយាបន្ន និងផ្អែកតាមទិន្នន័យ និងភស្តុតាងដ៏រឹងមាំ។

សូមឱ្យយើងទាំងអស់គ្នាចាកចេញទៅវិញជាមួយនឹងការប្តេជ្ញាចិត្តរួមគ្នា ដើម្បីធានាថាសំឡេង ចំណេះដឹង និងបទពិសោធន៍ពីខេត្តនីមួយៗ នៅតែបន្តផ្តល់ព័ត៌មាន និងពង្រឹងគោលនយោបាយថ្នាក់ជាតិ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋខ្មែរទាំងអស់។ រួមគ្នា យើងអាចធ្វើការសម្រេចចិត្ត ដែលមិនត្រឹមតែមានប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែក៏មានសមធម៌ បរិយាបន្ន និងនិរន្តរភាពផងដែរ។



# សេចក្តីសន្និដ្ឋាន

វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៦ ដែលបានប្រារព្ធធ្វើឡើងនៅខេត្តសៀមរាប បានកត់សម្គាល់នូវជំហានដ៏សំខាន់មួយនៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការពង្រឹងការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យនៅថ្នាក់ក្រោមជាតិ។ រៀបចំឡើងក្រោមមូលបទ "ការផ្សារភ្ជាប់សហគមន៍ ទិន្នន័យ និងគោលនយោបាយ៖ ការពង្រឹងការសម្រេចចិត្តនៅថ្នាក់ក្រោមជាតិដើម្បីអនាគតកម្ពុជា" វេទិកានេះបានគូសបញ្ជាក់ពីតួនាទីកាន់តែច្រើនរបស់តួអង្គថ្នាក់ខេត្ត ដែលមិនត្រឹមតែជាអ្នកអនុវត្តគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអ្នកមានចំណេះដឹង និងជាអ្នកនវានុវត្តន៍ដ៏សំខាន់ផងដែរ។អ្នកចូលរួមបានបញ្ជាក់ជាថ្មីថា ដំណោះស្រាយគោលនយោបាយប្រកបដោយប្រសិទ្ធភាពត្រូវតែផ្អែកលើតថភាពជាក់ស្តែង និងទស្សនៈចម្រុះរបស់សហគមន៍នៅទូទាំងប្រទេសកម្ពុជា។

ក្នុងវេទិកានេះទាំងមូល ការពិភាក្សាបានគូសបញ្ជាក់ពីវិធីដាក់ស្ដែងនៃការលុបបំបាត់គម្លាតរវាងទិន្នន័យក្នុងមូលដ្ឋាន និងការធ្វើសេចក្ដីសម្រេចចិត្ត។ វគ្គពិភាក្សានានាបានស្វែងយល់អំពីការប្រើប្រាស់ទិន្នន័យប្រកបដោយបរិយាបន្ន ដើម្បីដោះស្រាយបញ្ហាប្រឈមនៅថ្នាក់ឃុំ វិធីសាស្ត្រក្នុងការពង្រឹងការចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការស្រាវជ្រាវ និងឱកាសផ្សារភ្ជាប់ភាពធន់នឹងអាកាសធាតុជាមួយនឹងប្រព័ន្ធគាំពារសង្គមដែលឆ្លើយតបនឹងគ្រោះមហន្តរាយ។ វេទិកានេះក៏បានពិនិត្យមើលផងដែរថា តើកិច្ចសហការរវាងសាកលវិទ្យាល័យ ឧស្សាហកម្មក្នុងស្រុក និងអាជ្ញាធរខេត្ត អាចជួយគាំទ្រដូចម្ដេចដល់នវានុវត្តន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចកម្រិតភូមិភាគ។ ចំណុចសំខាន់មួយនៃព្រឹត្តិការណ៍នេះ គឺការដាក់ឱ្យប្រើប្រាស់ "គោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន" ដែលជាឧបករណ៍ដាក់ស្ដែងមួយ សម្រាប់ធានាថា បរិយាបន្នក្លាយជាការអនុវត្តស្តង់ដារនៅក្នុងការពិភាក្សាគោលនយោបាយ ជាជាងគ្រាន់តែជាលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី ដើម្បីជំរុញឱ្យស្ត្រី យុវជន ជនមានពិការភាព និងសហគមន៍ជនជាតិដើមភាគតិចអាចចូលរួមចំណែកយ៉ាងសកម្មដល់ដំណោះស្រាយគោលនយោបាយ។

មេរៀនឆ្លងវិស័យជាច្រើន បានលេចចេញពីការពិភាក្សាថ្នាក់ខេត្តនេះ។ ទីមួយ អាជ្ញាធរខេត្ត និងសហគមន៍មូលដ្ឋានមានចំណេះដឹងដ៏មានតម្លៃ និងដំណោះស្រាយដាក់ស្ដែងរួចជាស្រេច ដើម្បីដោះស្រាយបញ្ហាប្រឈមដ៏ស្មុគស្មាញ ដូចជាការប្រែប្រួលអាកាសធាតុ ការប្រែប្រួលសេដ្ឋកិច្ច និងកិច្ចគាំពារសង្គម។ ការពង្រឹងទំនាក់ទំនងរវាងទិន្នន័យក្នុងមូលដ្ឋាន និងដំណើរការធ្វើសេចក្ដីសម្រេចចិត្តជាផ្លូវការ នៅតែជារឿងចាំបាច់។ ទីពីរ បរិយាបន្នប្រកបដោយអត្ថន័យ ទាមទារលើសពីភាពជាតំណាង ពោលគឺត្រូវមានការខិតខំប្រឹងប្រែងប្រកបដោយចេតនា ដើម្បីលុបបំបាត់របាំងរចនាសម្ព័ន្ធ តាមរយៈហេដ្ឋារចនាសម្ព័ន្ធដែលបង្កលក្ខណៈងាយស្រួល ការរៀបចំថវិកាប្រកបដោយបរិយាបន្ន និងវិធីសាស្ត្រផ្សព្វផ្សាយដែលឆ្លើយតបនឹងតម្រូវការរបស់ក្រុមងាយរងគ្រោះ។ ទីបី ទំនុកចិត្ត និងកិច្ចសហការរវាងអាជ្ញាធរ អ្នកស្រាវជ្រាវ និងសហគមន៍ នៅតែជាមូលដ្ឋានគ្រឹះសម្រាប់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។ ការចែករំលែកទិន្នន័យប្រកបដោយតម្លាភាព និងការពិភាក្សាប្រកបដោយនិរន្តរភាព ជួយធានាថា គោលនយោបាយឆ្លើយតបបានយ៉ាងត្រឹមត្រូវទៅនឹងអាទិភាពក្នុងមូលដ្ឋាន។

វេទិកានេះបានឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ី ក្នុងការពង្រឹងបរិយាកាសគោលនយោបាយ ដែលផ្ដល់តម្លៃដល់ការយល់ដឹងពីមូលដ្ឋាន ទិន្នន័យដែលអាចជឿទុកចិត្តបាន និងការចូលរួមប្រកបដោយបរិយាបន្ន។ វេទិកានេះក៏បានបង្ហាញផងដែរនូវសមត្ថភាពកាន់តែប្រសើរឡើងរបស់រដ្ឋបាលខេត្ត អ្នកស្រាវជ្រាវក្នុងមូលដ្ឋាន និងអង្គការសង្គមស៊ីវិលក្នុងការរួមចំណែកដល់ការពិភាក្សាគោលនយោបាយ និងដំណោះស្រាយលើការអភិវឌ្ឍ។

តទៅមុខ ការយល់ដឹង និងបទពិសោធន៍ដែលបានចែករំលែកនៅខេត្តសៀមរាប នឹងរួមចំណែកដល់ ការពង្រឹងដំណើរការរៀបចំផែនការខេត្ត និងផ្ដល់ព័ត៌មានដល់យុទ្ធសាស្ត្រគោលនយោបាយជាតិ។ តាមរយៈការពង្រឹងភាពពាក់ព័ន្ធគ្នារវាងសហគមន៍ ទិន្នន័យ និងគោលនយោបាយ វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៦ បានពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធអេកូឡូស៊ីគោលនយោបាយមួយ ដែលកាន់តែឆ្លើយតបនឹងតម្រូវការ ប្រកបដោយបរិយាបន្ន និងផ្អែកលើតថភាព ក្នុងមូលដ្ឋាន ដែលអាចគាំទ្រដល់គោលបំណងអភិវឌ្ឍន៍របស់កម្ពុជា។

# ឧបសម្ព័ន្ធ ១៖ វាគ្មិន និងអ្នកសម្របសម្រួល



## កញ្ញា ជាតិ សុខា

*នាយិកាប្រតិបត្តិនៃសមាគមជនពិការខ្វះខ្វាក់ភ្នែកកម្ពុជា ប្រចាំខេត្តបាត់ដំបង*

កញ្ញា ជាតិ សុខា មានពិការភាពខ្វះខ្វាក់ភ្នែក និងប្រើប្រាស់ រទេះរុញជាឧបករណ៍ជំនួយ។ បច្ចុប្បន្ន កញ្ញាបម្រើការជា នាយិកាប្រតិបត្តិនៃសមាគមជនពិការខ្វះខ្វាក់ភ្នែកកម្ពុជា ប្រចាំខេត្តបាត់ដំបង ដែលតំណាងឱ្យជនមានពិការភាព។ កញ្ញាបាន និងកំពុងធ្វើការយ៉ាងសកម្មនៅក្នុងវិស័យសិទ្ធិ ជនមានពិការភាព ព្រមទាំងបានតស៊ូមតិ និងចូលរួម ជាមួយអ្នកតាក់តែងគោលនយោបាយ និងអង្គការ សង្គមស៊ីវិល ទាំងនៅកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ដោយ ទាញចេញពីបទពិសោធន៍របស់កញ្ញាផ្ទាល់ ក្នុងនាមជា ជនមានពិការភាព។



## កញ្ញា ជ័យ ម៉ារ៉ាមី

*មន្ត្រីជាន់ខ្ពស់កម្មវិធី នៃកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២*

កញ្ញា ជ័យ ម៉ារ៉ាមី គឺជាមន្ត្រីកម្មវិធីជាន់ខ្ពស់នៃកម្មវិធី ពន្លកចំណេះ របស់អង្គការមូលនិធិអាស៊ី។ តួនាទីរបស់កញ្ញា ពាក់ព័ន្ធនឹងកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយដៃគូកម្មវិធី និងការសម្របសម្រួលកិច្ចការពាក់ព័ន្ធ នឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ កញ្ញាទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ពី សាកលវិទ្យាល័យណាហ្គូយ៉ា ( Nagoya University ) ប្រទេសជប៉ុន។



## កញ្ញា ផាំង ម៉ារ៉ុង

កញ្ញា ផាំង ម៉ារ៉ុង ជាអតីតសមាជិកក្រុមការងារតាក់តែងគោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន របស់កម្មវិធីពន្លកចំណេះ ដំណាក់កាលទី ២។ កន្លងមក កញ្ញាធ្លាប់ធ្វើការជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដែលនៅទីនោះ កញ្ញាបានទទួលខុសត្រូវលើភារកិច្ចជាច្រើន រួមទាំងការសម្របសម្រួលការពិភាក្សាប្រកបដោយបរិយាបន្ន ទាំងកម្រិតថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ កញ្ញា ម៉ារ៉ុង បានរួមចំណែកផ្តល់ការយល់ដឹងស៊ីជម្រៅដល់ការរៀបចំគោលការណ៍ណែនាំសម្រាប់ការពិភាក្សាប្រកបដោយបរិយាបន្ន និងបាននិពន្ធឯកសារបោះពុម្ពផ្សាយ ដែលពង្រឹងសមត្ថភាពបន្សាំក្នុងបរិបទនៃការធ្វើចំណាកស្រុកដោយផ្អែកលើយេនឌ័រ ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ កញ្ញា ម៉ារ៉ុង បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យកូរ៉េ លើជំនាញគោលនយោបាយសង្គម ក្នុងឆ្នាំ២០២៣។ កញ្ញាទទួលបានបរិញ្ញាបត្រផ្នែកសង្គមវិទ្យាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០១៦។ នៅឆ្នាំ ២០១៧ ដល់ ២០២០ កញ្ញាជាជំនួយការផ្នែកស្រាវជ្រាវ និងនៅឆ្នាំ ២០២៤ កញ្ញាបានក្លាយជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។



## លោក ឆែង ពឿន

*កសិករ និងជាអតីតយុទ្ធជន*

លោកជាជនជាតិដើមភាគតិចកួយ មានពិការភាព ដែលរស់នៅក្នុងភូមិកោះជ្រឹង ឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។ លោក ពឿន គឺជាអតីតយុទ្ធជន។ លោកបានរងរបួសដៃស្តាំដោយសារគ្រាប់កាំភ្លើងជាច្រើនគ្រាប់ និងងងឹតភ្នែកខាងឆ្វេង ក្នុងអំឡុងពេលសង្គ្រាមខ្មែរក្រហម។ លោកមកពីគ្រួសារក្រីក្រ និងមានប័ណ្ណសន្តិសុខសង្គម។ នាពេលបច្ចុប្បន្ន លោកគឺជាកសិកររស់នៅភូមិកោះជ្រឹង ឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។



### លោក ជួន វីរៈ

*មន្ត្រីគម្រោង "ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានធម្មជាតិ" នៃអង្គការភូមិខ្ញុំ*

លោក ជួន វីរៈ គឺជាមន្ត្រីគម្រោង "ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានធម្មជាតិ" នៅអង្គការភូមិខ្ញុំ ក្នុងខេត្តស្ទឹងត្រែង។ លោកមានបទពិសោធន៍ជាង ៧ឆ្នាំ ក្នុងនាមជាប្រធានផ្នែកលក់ក្នុងក្រុមហ៊ុនផ្គត់ផ្គង់បរិក្ខារ និងសេវាកម្ម។ លោកក៏មានបទពិសោធន៍ ៥ឆ្នាំ ក្នុងនាមជាមន្ត្រីគម្រោងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ងាយរងគ្រោះបំផុត តាមរយៈការបង្កើតអាជីវកម្មខ្នាតតូចផងដែរ។ លោក វីរៈ ទទួលបានបរិញ្ញាបត្រផ្នែកច្បាប់សាធារណៈ និងបានបម្រើការងារយ៉ាងច្រើនជាមួយក្រុមហ៊ុនឯកជន អង្គការថ្នាក់ជាតិ និងស្ថាប័នរដ្ឋាភិបាល ដើម្បីអភិវឌ្ឍសហគមន៍ដែលធន់នឹងអាកាសធាតុ។



### លោកស្រី ឌឹម សុខធីតា

*សមាជិកក្រុមប្រឹក្សាឃុំប៉ាក់ខ្លង ខេត្តកោះកុង*

លោកស្រីបានទទួលអាហារូបករណ៍ក្រោមកម្មវិធីអាហារូបករណ៍សម្តេចតេជោ ហ៊ុន សែន ដើម្បីបន្តការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងធនធានមនុស្ស នៅសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច។ បច្ចុប្បន្ន លោកស្រីបម្រើការជាសមាជិកក្រុមប្រឹក្សាឃុំ។ លោកស្រីធ្លាប់បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលនៅរាជធានីភ្នំពេញស្តីពីវិធីសាស្ត្រប្រកបដោយបរិយាបន្នទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងជនមានពិការភាព។ លោកស្រីក៏បានចូលរួមវគ្គចែករំលែកបទពិសោធន៍ស្តីពីការបង្កើតបណ្តាញសហគមន៍ សម្រាប់ការផ្លាស់ប្តូរចំណេះដឹង និងការអនុវត្តល្អផងដែរ។ បន្ថែមលើនេះ លោកស្រីធ្លាប់បានចុះប្រមូលទិន្នន័យ សម្របសម្រួល និងអនុវត្តសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ភូមិក្នុងឃុំប៉ាក់ខ្លង ដោយផ្តោតលើផលប៉ះពាល់ចំពោះគ្រួសារ ដែលរងគ្រោះដោយខ្យល់បក់ខ្លាំង ខ្យល់ព្យុះ និងគ្រោះមហន្តរាយផ្សេងទៀតនៅក្នុងឃុំ។



### លោកស្រី អេង ចាន់ឌី

*នាយិកាប្រតិបត្តិនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា*

លោកស្រី  អេង ចាន់ឌី  គឺជាអ្នកដឹកនាំហ្វែមមីនីសម្នាក់នៅកម្ពុជា  និងជានាយិកាប្រតិបត្តិនៃអង្គការ យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា ដែលមានបទពិសោធន៍ជាងមួយទសវត្សរ៍ក្នុងការងារលើកកម្ពស់សមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំហ្វែមមីនីសនៅទូទាំងតំបន់អាស៊ាន។ លោកស្រីទទួលបានបរិញ្ញាបត្រផ្នែកច្បាប់ និងសិទ្ធិមនុស្សអន្តរជាតិ ហើយបច្ចុប្បន្ន កំពុងបន្តការសិក្សាថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយ ដោយផ្តោតលើតួនាទីរបស់ស្ត្រីក្នុងការកសាងសន្តិភាពនៅតាមព្រំដែនកម្ពុជា។ ក្នុងនាមជាសមាជិកគណៈកម្មាធិការវេទិកាប្រជាជនអាស៊ាន ចាប់តាំងពីឆ្នាំ២០១៨ មក លោកស្រីត្រូវបានគេទទួលស្គាល់ចំពោះភាពជាអ្នកដឹកនាំប្រកបដោយការផ្លាស់ប្តូរ និងការតស៊ូមតិក្នុងតំបន់។



### លោក ហែម ប៊ុនហ៊ាន

*នាយកប្រតិបត្តិនៃមណ្ឌលទទួលពលករកំរៀង*

លោក ហែម ប៊ុនហៀន កើតនៅភូមិព្រៃខ្មែរ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ក្នុងឆ្នាំ២០១៩ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅរាជធានីភ្នំពេញ។ បច្ចុប្បន្ន លោករស់នៅភូមិស្វាយ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ចាប់តាំងពីឆ្នាំ២០១៧ មក លោកបានបម្រើការជាអនុមន្ត្រីសង្គមកិច្ច និងសុខុមាលភាពសង្គម (ទទួលបន្ទុកធម្មការ និងសាសនាស្រុក) នៅរដ្ឋបាលស្រុកកំរៀង។ លោកក៏ជានាយកប្រតិបត្តិនៃមណ្ឌលទទួលពលករកំរៀងផងដែរ។



### លោកស្រី ហ៊ិន សុវណ្ណារ៉ា

*សមាជិកក្រុមប្រឹក្សាឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង*

លោកស្រី ហ៊ិន សុវណ្ណារ៉ា គឺជាសមាជិកក្រុមប្រឹក្សាឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។ លោកស្រីមានបទពិសោធន៍ជាង ១០ ឆ្នាំ ក្នុងការងារជាមន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ដោយសម្របសម្រួលដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងការចុះបញ្ជីអត្រានុកូលដ្ឋាន។ បច្ចុប្បន្ន លោកស្រីគឺជាប្រធានក្រុមប្រឹក្សាឃុំ។



### លោកស្រី ហួរ ដានី

*អនុប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*

លោកស្រី ហួរ ដានី គឺជាអនុប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍  ខេត្តបាត់ដំបង។ ក្នុងតួនាទីនេះ លោកស្រីជួយដល់ការអនុវត្តគោលនយោបាយជាតិស្តីពីឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៅថ្នាក់ខេត្តដោយផ្តោតលើការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម (SME) ការលើកកម្ពស់នវានុវត្តន៍ និងការសម្របសម្រួលស្ថាប័ន។ លោកស្រីបានចូលរួមយ៉ាងសកម្មក្នុងគំនិតផ្តួចផ្តើមថ្នាក់ខេត្ត និងអន្តរជាតិ ទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងកិច្ចសហការជាមួយសាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍។ លោកស្រី ហួរ ដានី បានធ្វើជាតំណាងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅក្នុងកម្មវិធីផ្លាស់ប្តូរចំណេះដឹងថ្នាក់ភូមិភាគ និងសិក្ខាសាលាបច្ចេកទេស ដែលមានគោលបំណងពង្រឹងប្រព័ន្ធនវានុវត្តន៍ និងផ្សារភ្ជាប់ការស្រាវជ្រាវទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។





### លោក អ៊ីល អឿ

*នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសំរាប់ការវិភាគបញ្ហាអភិវឌ្ឍន៍*

លោក អ៊ីល អឿ គឺជាសហស្ថាបនិក និងជានាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសំរាប់ការវិភាគបញ្ហាអភិវឌ្ឍន៍ តាំងពីឆ្នាំ ២០១១ មកម្ល៉េះ ហើយការងាររបស់លោកផ្តោតលើអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិ និងការផ្លាស់ប្តូរសង្គម ជាពិសេសការធ្វើចំណាកស្រុកឆ្លងដែន។ លោកមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់ការគិតត្រិះរិះពិចារណា និងការជំរុញការស្រាវជ្រាវដែលមានការចូលរួម ក្នុងសហគមន៍មូលដ្ឋាននៅកម្ពុជា ជាពិសេសជាមួយសហគមន៍ជនជាតិដើមភាគតិចនៅភាគឦសាននៃប្រទេសកម្ពុជា។ ប្រវត្តិការសិក្សារបស់លោក រួមមានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្រ្ត ជំនាញគោលនយោបាយសាធារណៈលើឯកទេសការអភិវឌ្ឍប្រកបដោយនិរន្តរភាព ពីសាកលវិទ្យាល័យ Maastricht ប្រទេសហូឡង់ ក្នុងឆ្នាំ ២០១០ សញ្ញាបត្រក្រោយបរិញ្ញាបត្រលើជំនាញវិភាគគោលនយោបាយ ពីវិទ្យាស្ថានសិក្សាសង្គម នៃសាកលវិទ្យាល័យ Erasmus ប្រទេសហូឡង់ ក្នុងឆ្នាំ ២០០៥ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យន័រតុន ប្រទេសកម្ពុជា ក្នុងឆ្នាំ២០០២។

### លោក គង់ សុមុន្នី

*ប្រធានសាខាមូលនិធិជាតិជំនួយសង្គម ខេត្តកោះកុង*

លោក សុមុន្នី បានបម្រើការក្នុងការិយាល័យសង្គមកិច្ច តាំងពីឆ្នាំ២០១៤។ ដំបូងឡើយ លោកកាន់តំណែងនៅការិយាល័យរដ្ឋបាល ហើយភារកិច្ចរបស់លោក រួមមានការត្រួតពិនិត្យឯកសារ និងការរៀបចំ និងរក្សាទុកឯកសារឱ្យបានត្រឹមត្រូវ។ ក្នុងឆ្នាំ២០១៧ លោកត្រូវបានតម្លើងឋានៈទៅជាអនុប្រធានការិយាល័យរដ្ឋបាល។ ក្នុងតួនាទីនេះ លោកទទួលខុសត្រូវលើការរៀបចំលិខិតផ្លូវការ ការត្រួតពិនិត្យឯកសារច្បាប់ និងការរៀបចំរបាយការណ៍ប្រចាំខែ របាយការណ៍ប្រាំបួនខែ និងរបាយការណ៍ប្រចាំឆមាស។ លោកត្រូវបានតែងតាំងជាប្រធានការិយាល័យអតីតយុទ្ធជនក្នុងឆ្នាំ២០១៩។ ភារកិច្ចរបស់លោករួមមានការគ្រប់គ្រង និងរៀបចំឯកសារសម្រាប់អតីតយុទ្ធជន ជនមានពិការភាព ជនដែលទទួលមរណភាព និងអ្នកដែលបាត់បង់របរចិញ្ចឹមជីវិត។ ក្នុងឆ្នាំ២០២៤ លោកត្រូវបានជ្រើសរើសតាមរយៈដំណើរការសម្ភាស ឱ្យបម្រើការជាប្រធានសាខាមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ) ខេត្តកោះកុង។ ក្នុងតួនាទីនេះ លោកទទួលខុសត្រូវលើការគ្រប់គ្រងទូទៅ ការសម្របសម្រួល និងគណនេយ្យភាពរបស់សាខាខេត្ត។



## កញ្ញា គុំ សុម៉ាលី

*អ្នកសម្របសម្រួលគម្រោងនៃអង្គការយុវសន្តិភាព*

កញ្ញា គុំ សុម៉ាលី គឺជាអ្នកសម្របសម្រួលគម្រោងនៅអង្គការយុវសន្តិភាព និងជាសមាជិកនៃបណ្ដាញ ស្ត្រីក្នុងវិស័យស្រាវជ្រាវ។  កញ្ញាបានធ្វើការក្នុងវិស័យសិទ្ធិមនុស្ស យុត្តិធម៌ និងកិច្ចការរដ្ឋបាល តាំងពីឆ្នាំ២០១០។ អត្ថបទ និងឯកសារស្រាវជ្រាវរបស់កញ្ញាគឺផ្ដោតសំខាន់លើយុត្តិធម៌អន្តរកាលនៅកម្ពុជា តាមរយៈទស្សនៈវិស័យច្បាប់ និងយេនឌ័រ។ កញ្ញាមានបទពិសោធន៍ការងារជាមួយសង្គមស៊ីវិល និស្សិតសាកលវិទ្យាល័យ និងសហគមន៍តាមរយៈគម្រោងផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល។ កញ្ញាធ្លាប់ធ្វើការជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន RWI ក្នុងគម្រោង "នីតិរដ្ឋ"។ កញ្ញាគឺជាអ្នកប្រឹក្សាយោបល់ និងជាមន្ត្រីគម្រោងក្នុងកម្មវិធីនៅកម្ពុជាសម្រាប់មជ្ឈមណ្ឌល WSD Handa សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិនៅសាកលវិទ្យាល័យ Stanford។ កញ្ញាធ្លាប់ធ្វើការនៅអង្គការអាដហុក ក្នុងតួនាទីជាជំនួយការគម្រោង។ កញ្ញាទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិទ្ធិមនុស្ស និងប្រជាធិបតេយ្យនីយកម្ម សាកលវិទ្យាល័យ Mahidol។ កញ្ញាក៏ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលសាធារណៈ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផងដែរ។ កញ្ញាមានបរិញ្ញាបត្រផ្នែកគ្រប់គ្រងពីវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ និងសញ្ញាបត្រគណនេយ្យពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។



## លោកស្រី ឡា ចិន្ដា

*អភិបាលរងស្រុក ទទួលបន្ទុកហិរញ្ញវត្ថុ និងវិភាជថវិកាឃុំ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង*

លោកស្រី ឡា ចិន្ដា គឺជាអភិបាលរងស្រុក ទទួលបន្ទុកហិរញ្ញវត្ថុ និងវិភាជថវិកាឃុំ នៅក្នុងស្រុកសៀមបូក ខេត្តស្ទឹងត្រែង។ លោកស្រីមានបទពិសោធន៍ជាង ៣ ឆ្នាំ ជាមន្ត្រីរដ្ឋបាលថ្នាក់ស្រុក  ព្រមទាំងបទពិសោធន៍ ៦ ឆ្នាំ ជាអនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុស្រុក។ លោកស្រីក៏មានបទពិសោធន៍ ៥ ឆ្នាំ ជានាយករដ្ឋបាលស្រុកផងដែរ។ បច្ចុប្បន្ន លោកស្រីគឺជាអភិបាលរងស្រុក។ លោកស្រី ចិន្ដា ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់សាធារណៈ។ ហើយលោកស្រីក៏ធ្លាប់ជា អ្នកស្ម័គ្រចិត្ត និងមន្ត្រីរបស់អង្គការ សហការជាមួយអង្គការដៃគូក្នុងស្រុក ដើម្បីអភិវឌ្ឍសហគមន៍។



### កញ្ញា លន ម៉ាឡា

*មន្ត្រីបង្គោលនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំអូរដា*

បច្ចុប្បន្ន កញ្ញារស់នៅភូមិអូរដា ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង។ កញ្ញាបានរៀនចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យកំរៀង នៅឆ្នាំ២០១១ ខេត្តបាត់ដំបង។ ក្រោយពីបញ្ចប់ការសិក្សា កញ្ញាត្រូវបានមេភូមិផ្តល់ព័ត៌មានអំពីការជ្រើសរើសជំនួយការរដ្ឋបាលឃុំ។ ក្រោយមក កញ្ញាបានបម្រើការជាជំនួយការរដ្ឋបាលឃុំនៅសាលាឃុំអូរដា ពីឆ្នាំ២០១៦ ដល់ ២០២២។ ពីឆ្នាំ ២០២០ ដល់ ២០២៨ កញ្ញាបាន និងកំពុងបម្រើការជាមន្ត្រីបង្គោលនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំអូរដា  ដោយផ្តោតលើបញ្ហាទាក់ទងនឹងស្ត្រី និងកុមារ។ បច្ចុប្បន្ន កញ្ញាជាសមាជិកក្រុមប្រឹក្សាឃុំអូរដា ក្នុងស្រុកកំរៀង។ បន្ថែមលើតួនាទីបច្ចុប្បន្ន កញ្ញាទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងជនមានពិការភាពនៅកម្រិតឃុំ រួមទាំងការកំណត់ប្រភេទក្រុមងាយរងគ្រោះ និងក្រុមដែលប្រឈមហានិភ័យ ដូចជា ស្ត្រី កុមារ និងយុវជន។ បន្ថែមលើនេះ កញ្ញាទទួលខុសត្រូវលើការប្រមូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យក្រោមកិច្ចសហការជាមួយអង្គការ Caritas Switzerland ដោយផ្តោតលើពលករចំណាកស្រុកដែលវិលត្រឡប់មកវិញ និងពលករចំណាកស្រុកដែលងាយរងគ្រោះ។ កញ្ញាក៏បម្រើការជាមន្ត្រីបង្គោលនៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារផងដែរ។



### លោក ឡុង ចំរើន

*នាយករងវិទ្យាល័យកំរៀង*

លោក ឡុង ចំរើន មានទីលំនៅនៅភូមិអូរដា ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង។ បច្ចុប្បន្ន លោកគឺជានាយករងវិទ្យាល័យកំរៀង។ បន្ថែមលើតួនាទីនេះ លោកទទួលខុសត្រូវលើការគ្រប់គ្រងវិន័យ ហើយក៏បម្រើការជាគ្រូបណ្តុះបណ្តាលជាមួយអង្គការមិនមែនរដ្ឋាភិបាលលើការអប់រំស្តីពីគុណតម្លៃ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពផងដែរ។



## លោក មាន វិបុលរតនៈ

*លោក មាន វិបុលរតនៈ ជាអ្នកប្រើប្រាស់រទេះរុញ។ បច្ចុប្បន្នលោកមានតួនាទីជាសម្របសម្រួលគម្រោង និងជាអ្នកបណ្តុះបណ្តាលបរិយាបន្នពិការភាពនៅក្នុងអង្គការជនពិការកម្ពុជា។*

លោកបានក្លាយជាអ្នកបណ្តុះបណ្តាលលើផ្នែកពិការភាព ហើយលោកក៏មានមានបទពិសោធន៍ផ្តល់ការបណ្តុះបណ្តាលរយៈពេល ៦ ឆ្នាំ ក្នុងចលនាពិការភាពនៅកម្ពុជា រួមមានការចូលរួនបណ្តុះបណ្តាលគ្រូបង្គោលស្តីពីបរិយាបន្នពិការភាពនៅក្នុងអភិបាលកិច្ច បណ្តុះបណ្តាលគ្រូបង្គោលស្តីពីទឹកស្អាត និងអនាម័យជាមួយអង្គការ Water Aid និងការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ (GIZ) ជាមួយអាកាសយានដ្ឋានអន្តរជាតិ អង្គការ ChildFund កម្ពុជា អង្គការ Marie Stopes កម្ពុជា កម្មវិធីវិនិយោគឃុំ និងវិស័យឯកជន។ លោកក៏ជាអ្នកសហការសម្របសម្រួលវគ្គបណ្តុះបណ្តាលកម្រិតខ្ពស់ស្តីពីការអភិវឌ្ឍប្រកបដោយបរិយាបន្នពិការភាព និងជាសមាជិកនៅក្នុងក្រុមជំនាញ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ក្នុងកម្មវិធីពន្លកចំណេះ ដំណាក់កាលទី ២ ផងដែរ។ ក្រៅពីនេះ លោកបានជួយរៀបចំយុទ្ធសាស្ត្របរិយាបន្នពិការភាពនៅក្នុងសង្គម។



## ឯកឧត្តម មូល ធន

*អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង*

ឯកឧត្តម មូល ធន គឺជាអភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង ជាទីដែលឯកឧត្តមដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់រដ្ឋបាលខេត្ត ការសម្របសម្រួលជាមួយក្រសួងស្ថាប័នថ្នាក់ជាតិ និងការអនុវត្តអាទិភាពអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ។ ឯកឧត្តមតែងតែធ្វើជាតំណាងរដ្ឋបាលខេត្តនៅក្នុងពិធីផ្លូវការ ការពិភាក្សាគោលនយោបាយ និងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នៅទូទាំងវិស័យផ្សេងៗ រួមមានការអភិវឌ្ឍសេដ្ឋកិច្ច បរិយាបន្នហិរញ្ញវត្ថុ គណនេយ្យភាពសង្គម និងការផ្តល់សេវាសាធារណៈ។ ការងាររបស់ឯកឧត្តមសង្កត់ធ្ងន់លើកិច្ចសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ដើម្បីលើកកម្ពស់កំណើនប្រកបដោយបរិយាបន្ន និងពង្រឹងអភិបាលកិច្ចនៅថ្នាក់ខេត្ត។





## លោកស្រី នូវ ស្រីលាប

## លោកស្រី អ៊ូច សុម៉ាលី

លោកស្រី នូវ ស្រីលាប គឺជាសិល្បៈការិនីល្ខោន និងជាអ្នកដឹកនាំរឿងនៅកម្ពុជា ហើយក៏ជាស្ថាបនិកនៃក្រុមសិល្បៈល្ខោនឆ្លុះផងដែរ។ ជាមួយនឹងបទពិសោធន៍ជាង ១០ ឆ្នាំ លោកស្រីធ្វើការលើទម្រង់ល្ខោនសហគមន៍ និងចូលរួមក្នុងសកម្មភាពសង្គម ដែលផ្ដោតលើសមភាពយេនឌ័រ ការផ្ដល់អំណាចដល់ស្ត្រី និងសិទ្ធិមនុស្ស។ លោកស្រីធ្លាប់បានសហការជាមួយសមាគមហ្សារពន្លឺសិល្បៈ Theatre du Soleil និង Global Art Corp ដោយចូលរួមសម្ដែងទាំងក្នុងប្រទេស និងលើឆាកអន្តរជាតិ។ ក្នុងនាមជាអ្នកប្រឹក្សាឯករាជ្យ លោកស្រីបានអភិវឌ្ឍគម្រោងល្ខោនរឿង សម្របសម្រួលសិក្ខាសាលា និងធ្វើជាអ្នកណែនាំសម្រាប់សហគមន៍ងាយរងគ្រោះ។ ការងាររបស់លោកស្រីផ្ដោតលើវិធីសាស្ត្របែបចូលរួម និងប្រកបដោយបរិយាបន្ន ដែលប្រើប្រាស់ល្ខោនជាឧបករណ៍សម្រាប់ការពិភាក្សា និងការផ្លាស់ប្ដូរសង្គម។

ម្ចាស់សហគ្រាស សីហាម៉ាលី (សហគ្រាសផលិតណែម និងប្រហុក/ផ្អក បាត់ដំបង)



## លោកស្រី ប៉ែន ពិន

*ជំនួយការរដ្ឋបាលឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង*

កញ្ញារស់នៅភូមិកំរៀង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង។ បច្ចុប្បន្ន កញ្ញាបម្រើការនៅសាលាឃុំកំរៀង ក្នុងតួនាទីជាជំនួយការរដ្ឋបាលឃុំ។ នៅខែមករា ឆ្នាំ២០២៤ កញ្ញាបានចូលរួមជាមួយមណ្ឌលទទួលពលករកំរៀង ក្នុងការចុះផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ នៅខែកញ្ញា ឆ្នាំ២០២៤ កញ្ញាបានសហការជាមួយ មជ្ឈមណ្ឌលសំរាប់ការវិភាគបញ្ហាអភិវឌ្ឍន៍ សម្ភាសពលករចំណាកស្រុក ដែលបានវិលត្រឡប់ពីប្រទេសថៃ។ ក្នុងតួនាទីបច្ចុប្បន្នជាជំនួយការរដ្ឋបាលឃុំ កញ្ញាបានធ្វើការយ៉ាងសកម្មជាមួយរដ្ឋបាលឃុំកំរៀង ដើម្បីចែកស្បៀងអាហារជូនដល់គ្រួសារក្រីក្រ  មនុស្សចាស់ កុមារកំព្រា និងពលករចំណាកស្រុកដែលវិលត្រឡប់ពីប្រទេសថៃ។



## លោកស្រី ប៉ែន សោភា

*មេឃុំ ស្វាយដុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

ក្នុងឆ្នាំ២០១២ ដោយមានការជឿទុកចិត្ត និងការគាំទ្រពីថ្នាក់ដឹកនាំ លោកស្រីបានឈរឈ្មោះជាមេឃុំ និងបានបម្រើការក្នុងមុខតំណែងនេះរហូតមកដល់បច្ចុប្បន្ន។ សមិទ្ធផលលេចធ្លោរបស់លោកស្រី រួមមានការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ ការចុះសួរសុខទុក្ខ និងជួយគាំទ្រដល់សមាជិកសហគមន៍ ការរួមចំណែកដល់ការអប់រំកុមារតូច ការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពទឹកស្អាត និងអនាម័យ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការផ្សះផ្សារវិវាទក្រៅប្រព័ន្ធតុលាការ។ លោកស្រី ប៉ែន សោភា ក៏ធ្លាប់ធ្វើជាភ្នាក់ងារសុខភាពសត្វភូមិផងដែរ ហើយការងាររបស់លោកស្រីត្រូវបានទទួលស្គាល់ និងគាំទ្រដោយថ្នាក់ដឹកនាំមូលដ្ឋាន។ ក្នុងឆ្នាំ២០០៩ លោកស្រីត្រូវបានជ្រើសតាំងឱ្យបម្រើការជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ។



## លោកស្រី ផេង ផារ៉ូហ្សុីន

*អ្នកគ្រប់គ្រងកម្មវិធីយេនឌ័រ នៃអង្គការនារីដើម្បីសន្តិភាព*

លោកស្រី ផេង ផារ៉ូហ្សុីន ជាអ្នកជំនាញអភិវឌ្ឍន៍ដ៏មានការប្តេជ្ញាចិត្តមួយរូប ដែលមានបទពិសោធន៍ជិតពីរទសវត្សរ៍ក្នុងការងារលើកកម្ពស់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមនៅកម្ពុជា។ បច្ចុប្បន្ន លោកស្រីបម្រើការជាអ្នកគ្រប់គ្រងកម្មវិធីយេនឌ័រ នៅអង្គការនារីដើម្បីសន្តិភាព ជាទីដែលលោកស្រីដឹកនាំយុទ្ធសាស្រ្ត និងគំនិតផ្តួចផ្តើមប្រកបដោយបរិយាបន្ន ដែលផ្តោតលើសមភាពយេនឌ័រ  ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ  ការទទួលបានយុត្តិធម៌ក្នុងមូលដ្ឋាន ការកសាងបណ្តាញ និងអន្តរាគមន៍ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការជះឥទ្ធិពលលើគោលនយោបាយ និងការចូលរួមជាសាធារណៈ។ បទពិសោធន៍របស់លោកស្រី រួមមានការធ្វើការនៅអង្គការ Abt Global/Harvest III ដែលនៅទីនោះ លោកស្រីបានដឹកនាំភាពជាដៃគូយុទ្ធសាស្រ្ត ដើម្បីបង្កើនលទ្ធភាពទទួលបានទីផ្សារសម្រាប់ស្រ្តី យុវជន និងសមាជិកផ្សេងទៀតនៃក្រុមងាយរងគ្រោះនៅក្នុងវិស័យកសិ-ពាណិជ្ជកម្ម។ លោកស្រីធ្លាប់បម្រើការជាអ្នកគ្រប់គ្រងកម្មវិធីសមធម៌ និងបរិយាបន្ន នៅអង្គការ WaterAid កម្ពុជា ដែលនៅទីនោះ  លោកស្រីបានអភិវឌ្ឍក្របខ័ណ្ឌថ្នាក់ជាតិ  និងដឹកនាំការតស៊ូមតិគោលនយោបាយសម្រាប់សេវាទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន។ តួនាទីជាអ្នកដឹកនាំពីមុនរបស់លោកស្រី  រួមមានអ្នកគ្រប់គ្រងកម្មវិធីនៅអង្គការជនពិការកម្ពុជា  អ្នកគ្រប់គ្រងកម្មវិធីនៅបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ក្នុងព្រះរាជាណាចក្រកម្ពុជា និងជាអ្នកសម្របសម្រួលថ្នាក់ជាតិនៅអង្គការសម្ព័ន្ធប្រជាជនកម្ពុជាប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍។ លោកស្រីក៏ធ្លាប់បម្រើការជាអ្នកឯកទេសកម្រិតថ្នាក់ជាតិជាមួយកម្មវិធីអ្នកស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ ដោយធ្វើការតស៊ូមតិសម្រាប់ស្ត្រីដែលរស់នៅជាមួយការផ្ទុកមេរោគអេដស៍។



## លោកបណ្ឌិត ប៉ុញ ឧត្តម

*អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

លោកបណ្ឌិត ប៉ុញ ឧត្តម គឺជាអនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការអភិវឌ្ឍកសិកម្ម ការធ្វើកសិកម្មដែលធន់នឹងអាកាសធាតុ និងការសម្របសម្រួលកម្មវិធីកសិកម្មខេត្ត។ លោកបណ្ឌិត ឧត្តម ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការគ្រប់គ្រងដំណាំដែលបន្សុាំនឹងអាកាសធាតុ ការពង្រឹងខ្សែចង្វាក់តម្លៃកសិកម្ម   និងការគាំទ្រអង្គការកសិករ តាមរយៈកិច្ចសហការជាមួយស្ថាប័នថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍។ ការងាររបស់លោករួមមានការដឹកនាំដំណើរការផ្សៀងផ្ទាត់បច្ចេកទេសសម្រាប់កសិកម្មវៃឆ្លាតខាងអាកាសធាតុការគាំទ្រផលិតកម្មបែបសរីរាង្គ និងផ្តោតលើទីផ្សារ និងការរួមចំណែកដល់ការអនុវត្តគោលនយោបាយកសិកម្មថ្នាក់ជាតិ នៅកម្រិតខេត្ត។



## កញ្ញា រឹមផាត បុប្ផាភួង

*ប្រធានកម្មវិធីតស៊ូមតិ និងបណ្តាញ នៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា*

កញ្ញា រឹមផាត បុប្ផាភួង ជាប្រធានកម្មវិធីតស៊ូមតិ និងបណ្តាញ នៅអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា ដែលជាអង្គការស្ត្រីនិយមឈានមុខគេមួយលើការងារលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិស្ត្រីនៅទូទាំងប្រទេសកម្ពុជា។ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ និងមិនប្រកាន់និន្នាការនយោបាយ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០០ ដើម្បីលើកកម្ពស់សមភាពយេនឌ័រជាសិទ្ធិមនុស្ស។ តាមរយៈការអប់រំស្ត្រីនិយម ការចុះផ្សព្វផ្សាយតាមសហគមន៍ និងការតស៊ូមតិ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា បានបង្កើនភាពអង់អាចដល់ស្ត្រី និងបុរសឱ្យផ្លាស់ប្តូរបទដ្ឋានយេនឌ័រ បញ្ឈប់នូវអំពើហិង្សា និងចូលរួមដោយស្មើភាពគ្នាក្នុងសង្គម សេដ្ឋកិច្ច និងនយោបាយ។ ជាមួយនឹងបទពិសោធន៍ជាង ៦ឆ្នាំនៅ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា កញ្ញា បុប្ផាភួង ជួយគាំទ្រដល់ស្ត្រី និងយុវជនគ្រប់លក្ខណៈចម្រុះ ដើម្បីក្លាយខ្លួនជាភ្នាក់ងារផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ពួកគេ ដោយតស៊ូមតិឱ្យមានកំណែទម្រង់គោលនយោបាយ និងយុត្តិធម៌យេនឌ័រ បណ្តុះបណ្តាលបណ្តាញអង្គការសង្គមស៊ីវិលស្តីពីការតស៊ូមតិបែបស្ត្រីនិយម និងរួមគ្នាបង្កើតគោលការណ៍ណែនាំប្រកបដោយបរិយាបន្ន និងគោលការណ៍ណែនាំស្តីពីការប្រាស្រ័យទាក់ទង ដែលបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកស្រាវជ្រាវ និងអ្នកអនុវត្តន៍ក្នុងការប្រើប្រាស់។



## លោក រិទ្ធិ សុធីរ៉ា

*អនុប្រធានភូមិលំផាត់ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង*

លោក រិទ្ធ សុធារ៉ា រស់នៅភូមិលំផាត់ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង។ បច្ចុប្បន្ន លោកបម្រើការជាអនុប្រធានភូមិលំផាត់។ នៅពេលលោកផ្លាស់មករស់នៅស្រុកកំរៀងជាលើកដំបូងក្នុងឆ្នាំ២០០៥ លោក និងភរិយាបានធ្វើការជាកម្មករស៊ីឈ្នួលប្រចាំថ្ងៃ ដោយទទួលបានប្រាក់ឈ្នួល ៥.០០០ រៀល ក្នុងមួយថ្ងៃ។ នៅក្នុងឆ្នាំ២០០៧ លោកត្រូវបានមេភូមិតែងតាំងជាប្រធានក្រុមយុវជនភូមិ។ ក្រោយមក ក្នុងឆ្នាំ២០១២ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រជាការពារភូមិ។ ក្នុងឆ្នាំ២០២២ ដោយសារការជឿទុកចិត្ត និងការគាំទ្រពីអ្នកភូមិ និងអាជ្ញាធរឃុំ លោកត្រូវបានតែងតាំងជាអនុប្រធានភូមិលំផាត់ និងបានកាន់តំណែងនេះរហូតមកដល់សព្វថ្ងៃ។



### លោកបណ្ឌិត សំ ចាន់ធី

*ប្រធានក្រុមស្រាវជ្រាវ*

លោកបណ្ឌិត សំ ចាន់ធី បច្ចុប្បន្នជាប្រធានក្រុមស្រាវជ្រាវ និងជាសាស្ត្រាចារ្យជាន់ខ្ពស់។ លោកមានបទពិសោធន៍ការងារវិជ្ជាជីវៈជាង ១៨ ឆ្នាំ ក្នុងផ្នែកគាំពារសង្គម សង្គមកិច្ច ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការផ្គត់ផ្គង់ទឹក និងអនាម័យ ការគ្រប់គ្រងធនធានទឹកថាមពល សេវាប្រព័ន្ធអេកូឡូស៊ី ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ការគ្រប់គ្រងបរិស្ថានទីក្រុង ការគ្រប់គ្រងសំណល់រឹង ការគ្រប់គ្រងគម្រោង និងការពិនិត្យតាមដាន និងវាយតម្លៃ  ព្រមទាំងគណនេយ្យភាពសង្គម  និងហិរញ្ញវត្ថុ។ បន្ថែមលើនេះ លោកធ្លាប់ធ្វើការងារពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ បញ្ហាបរិស្ថាន សង្គម និងអភិបាលកិច្ច ការគ្រប់គ្រងគម្រោង ការតាំងទីលំនៅថ្មីយេនឌ័រ ការិយាល័យប្រជាពលរដ្ឋ និងសេវាច្រកចេញចូលតែមួយ គោលនយោបាយសាធារណៈ អភិបាលកិច្ចល្អកំណែទម្រង់រដ្ឋបាល និងការរេចរឹលដី។ លោកមានបទពិសោធន៍ ៥ ឆ្នាំ ក្នុងការងារតស៊ូមតិគោលនយោបាយថ្នាក់ជាតិ ទាក់ទងនឹងការការពារបរិស្ថាន ការអភិវឌ្ឍវារីអគ្គិសនី ការចូលរួមពីសាធារណជន ការរុករករ៉ែ បណ្ដាញសង្គម និងទំនាក់ទំនង និងការគ្រប់គ្រងធនធានធម្មជាតិផ្សេងទៀត។



### លោកស្រី សំម ឱណា

*ប្រធានសាខាមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ) ខេត្តព្រះសីហនុ*

លោកស្រីបានប្រឡងជាប់ជាមន្ត្រីរាជការ និងចូលបម្រើការងារនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ២០០៤។ លោកស្រីបានបម្រើរយៈពេល ៧ ឆ្នាំ នៅមណ្ឌលអប់រំកែប្រែទី ២ ក្នុងវិស័យសុខាភិបាល។ លោកស្រីបានបន្តបេសកកម្មនៅមន្ទីរឃុំឃាំងបណ្ដោះអាសន្ន នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) អស់រយៈពេល ១១ ឆ្នាំ ក្នុងវិស័យរដ្ឋបាល។ នៅដើមឆ្នាំ២០២១ លោកស្រីបានផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នៅពេលចាប់ផ្ដើមអាជីពដំបូងក្នុងវិស័យសង្គមកិច្ច លោកស្រីបានបម្រើការរយៈពេល ២ ឆ្នាំ នៅមជ្ឈមណ្ឌលជាតិព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដោយផ្ដោតលើការបន្សាប និងការព្យាបាល។ នៅដើមឆ្នាំ២០២៣ លោកស្រីបានចាប់ផ្ដើមបម្រើការនៅមន្ទីរសង្គមកិច្ចខេត្តព្រះសីហនុ ជាមន្ត្រីរួម ទទួលបន្ទុកការិយាល័យសេវាសង្គម។ នៅដើមឆ្នាំ២០២៤ លោកស្រីត្រូវបានជ្រើសតាំងជាប្រធានសាខាមូលនិធិជាតិជំនួយសង្គម។



## ឯកឧត្តម សរ បូរីរក្ស

*នាយកវិទ្យាស្ថានជាតិសង្គមកិច្ច*

ឯកឧត្តម សរ បូរីរក្ស បច្ចុប្បន្នជានាយកវិទ្យាស្ថានជាតិសង្គមកិច្ច។ ឯកឧត្តមទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ជំនាញពាណិជ្ជកម្មអន្តរជាតិ និងទីផ្សារ ពីសាកលវិទ្យាល័យ Hawaii Pacific សហរដ្ឋអាមេរិក រួមជាមួយនឹងវិញ្ញាបនបត្រទាក់ទងនឹងពាណិជ្ជកម្ម និងសាធារណៈជាច្រើនទៀតនៅកម្ពុជា។ ឯកឧត្តមបានចូលបម្រើកងទ័ពក្នុងឋានន្តរស័ក្តិជាមេបញ្ជាការនៅក្រសួងការពារជាតិ ហើយក្រោយមក បានផ្លាស់ប្តូរទៅកាន់តួនាទីជាមន្ត្រីរាជការ ដោយបម្រើការជាអភិបាលរងខេត្តព្រៃវែង ចំនួនពីរអាណត្តិ (៨ ឆ្នាំ)។ ក្នុងឆ្នាំ២០២៣ ឯកឧត្តមបានក្លាយជានាយកខុទ្ទកាល័យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។



## លោកស្រី សាយ ចន្ថា

*សមាជិកសហគមន៍ និងជាគ្រួសារក្រីក្រកម្រិត ២*

លោកស្រីមានទីលំនៅនៅភូមិកំពង់បាយខាងជើង សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត។

---



## លោកស្រី យូ ចាន់បុប្ផា

*មន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង*

លោកស្រី យូ ចាន់បុប្ផា គឺជាសមាជិកក្រុមប្រឹក្សាឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។ លោកស្រីធ្វើការជាមន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ដោយសម្របសម្រួលដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងការចុះបញ្ជីអត្រានុកូលដ្ឋាន។





## លោក ទេព នារ៉ា

*សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិបាត់ដំបង*

## លោកបណ្ឌិត ថាច់ ប៊ុនរឿន

*ព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យជាតិបាត់ដំបង*

លោក ទេព នារ៉ា គឺជាសាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិបាត់ដំបង និងជាឥស្សរជនជាន់ខ្ពស់ម្នាក់នៅក្នុងវិស័យអប់រំឧត្តមសិក្សា និងការធានាគុណភាពនៅកម្ពុជា។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយខាងភាពជាអ្នកដឹកនាំផ្នែកសិក្សាធិការ ការអភិវឌ្ឍការស្រាវជ្រាវ និងការធានាគុណភាពអប់រំឧត្តមសិក្សា ហើយលោកបានធ្វើជាតំណាងសាកលវិទ្យាល័យនៅកម្ពុជា ក្នុងវេទិកាថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ បន្ថែមលើតួនាទីជាអ្នកដឹកនាំផ្នែកសិក្សាធិការ លោក ទេព នារ៉ា ក៏បានចូលរួមយ៉ាងសកម្មនៅក្នុងគំនិតផ្តួចផ្តើមទទួលស្គាល់គុណភាពអប់រំ និងការធានាគុណភាពផងដែរ រួមទាំងការងារជាមួយបណ្តាញគុណភាពអប់រំឧត្តមសិក្សាកម្រិតអាស៊ាន។ លោកបានរួមចំណែកដល់ការពង្រឹងស្តង់ដារស្ថាប័ន សមត្ថភាពស្រាវជ្រាវ និងវិធីសាស្ត្រផ្អែកលើទិន្នន័យនៅក្នុងអភិបាលកិច្ចវិស័យអប់រំ។

លោកបណ្ឌិត ថាច់ ប៊ុនរឿន គឺជាសេដ្ឋវិទូ និងជាអ្នកដឹកនាំជាន់ខ្ពស់ផ្នែកសិក្សាធិការ ដែលមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យអប់រំឧត្តមសិក្សា ការគ្រប់គ្រងការស្រាវជ្រាវ និងការអភិវឌ្ឍស្ថាប័ននៅកម្ពុជា។ បច្ចុប្បន្នលោកបម្រើការជាព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យសង្គមវិទ្យា និងអភិវឌ្ឍន៍សហគមន៍ នៅសាកលវិទ្យាល័យជាតិបាត់ដំបង ជាទីដែលលោកគ្រប់គ្រងលើការស្រាវជ្រាវ កិច្ចការសិក្សាធិការ និងគម្រោងអភិវឌ្ឍន៍។ កន្លងមកលោកធ្លាប់កាន់តំណែងជាអ្នកដឹកនាំរយៈពេលវែង ជាព្រឹទ្ធបុរសរង នៃមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ និងជានាយកសាលាក្រោយបរិញ្ញាបត្រ ដោយសម្របសម្រួលកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត និងគ្រប់គ្រងភាពជាដៃគូជាមួយអង្គការថ្នាក់ជាតិ និងអន្តរជាតិ។ លោកបណ្ឌិត ប៊ុនរឿន ទទួលបានសញ្ញាបត្របណ្ឌិតសេដ្ឋកិច្ចពីសាកលវិទ្យាល័យ L'Aquila ប្រទេសអ៊ីតាលី ហើយស្រាវជ្រាវរបស់លោកផ្តោតលើសេដ្ឋកិច្ចនវានុវត្តន៍ ប្រព័ន្ធនវានុវត្តន៍ថ្នាក់ជាតិ និងតំបន់ និងការគ្រប់គ្រងជាយុទ្ធសាស្ត្រ។ លោកក៏ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច និងគ្រប់គ្រងពាណិជ្ជកម្ម និងបរិញ្ញាបត្រសេដ្ឋកិច្ចផងដែរ។

# ឧបសម្ព័ន្ធ ២៖ របៀបវារៈ

វេទិកាគោលនយោបាយថ្នាក់ខេត្តរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៦

*"ការផ្សារភ្ជាប់សហគមន៍ ទិន្នន័យ និងគោលនយោបាយ៖ ការពង្រឹងការសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ ដើម្បីអនាគតកម្ពុជា"*

ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦
សណ្ឋាគារ សុខាអង្គរ ខេត្តសៀមរាប
ភាសាខ្មែរ ដោយមានការបកប្រែជាភាសាអង់គ្លេស

## ពេលព្រឹក

| | |
|---|---|
| ៧:៣០ – ៨:១៥ | **ការចុះឈ្មោះចូលរួម**<br>ក្រុមការងារកម្មវិធីពន្លកចំណេះនៃអង្គការមូលនិធិអាស៊ី |
| ៨:៣០ – ៨:៤០ | **គោរពភ្លេងជាតិ**<br>ពិធីករ/ពិធីការិនី |
| ៨:៤០ – ៨:៥០ | **សុន្ទរកថាស្វាគមន៍**<br>លោកស្រី Meloney Lindberg<br>តំណាងអង្គការមូលនិធិអាស៊ីប្រចាំប្រទេសកម្ពុជា |
| ៨:៥០ – ៩:០០ | **ចំណាប់អារម្មណ៍**<br>លោកស្រី Kirsty Harris ប្រធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា |
| ៩:០០ – ៩:៣០ | **សុន្ទរកថាគន្លឹះ និងសុន្ទរកថាបើក  កម្មវិធី៖ សារៈសំខាន់នៃទិន្នន័យនៅមូលដ្ឋាននៅក្នុងការរៀបចំគោលនយោបាយថ្នាក់ក្រោមជាតិ**<br>លោក អ៊ឹង គឹមលាង អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប |
| ៩:៣០ – ១០:០០ | **ថតរូបអនុស្សាវរីយ៍ និងសម្រាកពិសាតែ-កាហ្វេ**<br>អ្នកចូលរួមទាំងអស់ |

## ពេលព្រឹក

១០:០០ – ១១:៣០

**កិច្ចពិភាក្សាពេញអង្គ៖ "ដំណោះស្រាយនៅមូលដ្ឋានដែលមានប្រសិទ្ធភាព៖ តើសហគមន៍ប្រែក្លាយទិន្នន័យ និងការចូលរួមទៅជាសកម្មភាពដោយរបៀបណា?"**

- **ប្រធានបទទី ១៖** "ការប្រើប្រាស់ទិន្នន័យដោះស្រាយបញ្ហាសហគមន៍ប្រកបដោយបរិយាបន្ន"
  **វាគ្មិន៖** លោកស្រី ប៉ែន សោភា មេឃុំស្វាយជុក ខេត្តកំពង់ឆ្នាំង
- **ប្រធានបទទី ២៖** "ការចូលរួមដ៏មានអត្ថន័យក្នុងដំណើរការស្រាវជ្រាវ"
  **វាគ្មិន៖** កញ្ញា គុំ សុម៉ាលី អ្នកសម្របសម្រួលគម្រោងនៃអង្គការយុវសន្តិភាព និងជាសមាជិកបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ SheThinks នៅរាជធានីភ្នំពេញ
- **ប្រធានបទទី ៣៖** "ការចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធភាពជាមួយសហគមន៍"
  **វាគ្មិន៖** កញ្ញា ជាតិ សុខា អង្គការតំណាងជនមានពិការភាព នាយិកាប្រតិបត្តិនៃសមាគមជនពិការខួរឆ្អឹងខ្នងកម្ពុជា ប្រចាំខេត្តបាត់ដំបង
- **ប្រធានបទទី ៤៖** "ការធ្វើកិច្ចពិភាក្សាប្រកបដោយបរិយាបន្នក្នុងសហគមន៍"
  **វាគ្មិន៖** លោកស្រី នូវ ស្រីលាប ប្រធានក្រុមសិល្បៈល្ខោនផ្លុះ ខេត្តសៀមរាប

**ការពិភាក្សាជាក្រុម និង ការរាយការណ៍ត្រឡប់**

**អ្នកសម្របសម្រួល៖**

- លោកស្រី ផេង ផារ៉ូហ្ស៊ីន អ្នកគ្រប់គ្រង កម្មវិធីយេនឌ័រនៃអង្គការនារីដើម្បីសន្តិភាព

១១:៣០ – ១២:០០

**កិច្ចពិភាក្សាពេញអង្គ៖ "ការពិភាក្សាប្រកបដោយបរិយាបន្ន នៅក្នុងការអនុវត្តជាក់ស្តែង"**

ការបង្ហាញត្រួសៗអំពីឧបករណ៍សម្របសម្រួលប្រកបដោយបរិយាបន្ន ដែលជួយបន្លឺសំឡេងរបស់ក្រុមងាយរងគ្រោះ ដោយវាគ្មិនបីរូប

**វាគ្មិន៖**

- លោក មាន វិបុលរតនៈ អ្នកសម្របសម្រួលគម្រោងនៃអង្គការជនពិការកម្ពុជា
- កញ្ញា ឆាំង ម៉ារ៉ុង សមាជិកបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ
- កញ្ញា ជ័យ ម៉ារ៉ាមី មន្ត្រីជាន់ខ្ពស់កម្មវិធី នៃអង្គការមូលនិធិអាស៊ី

**អ្នកសម្របសម្រួល៖**

- លោកស្រី អេង ចាន់ឌី នាយិកាប្រតិបត្តិនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា

## ពេលថ្ងៃត្រង់

១២:០០ – ១:០០

**ពិសាអាហារថ្ងៃត្រង់**

អ្នកចូលរួមទាំងអស់

១:១០ – ២:៤០

**ការពិភាក្សាស្របពេលគ្នា ១កៈ**

"ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ តាមរយៈកម្មវិធីផ្ទេរសាច់ប្រាក់នៅកម្ពុជា"

**អ្នកធ្វើបទបង្ហាញៈ**

- ឯកឧត្តម សរ បូរីរក្ស នាយកវិទ្យាស្ថានជាតិសង្គមកិច្ច
- លោក គង់ សុមុន្នី សាខាមូលនិធិជាតិជំនួយសង្គមខេត្តកោះកុង

**វាគ្មិនៈ**

- លោក គង់ សុមុន្នី សាខាមូលនិធិជាតិជំនួយសង្គមខេត្តកោះកុង
- លោកស្រី សំម ឱណា សាខាមូលនិធិជាតិជំនួយសង្គមខេត្តព្រះសីហនុ
- លោកស្រី ឌឹម សុខជីតា សមាជិកក្រុមប្រឹក្សាឃុំប៉ាក់ខ្លង ខេត្តកោះកុង
- លោកស្រី សាយ ចន្ថា តំណាងគ្រួសារក្រីក្រកម្រិតទី ២ មកពីខេត្តកំពត

**អ្នកសម្របសម្រួលៈ**

- បណ្ឌិត សំ ចាន់ធី វិទ្យាស្ថានជាតិសង្គមកិច្ច

---

**ការពិភាក្សាស្របពេលគ្នា ១ខៈ**

"ការបែងចែកថវិកាឃុំសម្រាប់ការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់លើសហគមន៍ងាយរងគ្រោះ"

**វាគ្មិនៈ**

- លោកស្រី ឡា ចិន្តា អភិបាលរងស្រុកសៀមបូក
- លោកស្រី ហ៊ិន សុវណ្ណារ៉ា ក្រុមប្រឹក្សាឃុំអូរម្រះ
- លោកស្រី យូ ចាន់បុប្ផា អ្នកដឹកនាំ សហគមន៍ស្ត្រីជនជាតិដើមភាគតិច
- លោក ឆែង ពឿន តំណាងសហគមន៍ ដែលមានពិការភាព

**អ្នកសម្របសម្រួលៈ**

- លោក ជួន វីរៈ អង្គការភូមិខ្ញុំ

២:៤០ – ២:៥០

**សម្រាកពិសាតែ-កាហ្វេ**

អ្នកចូលរួមទាំងអស់

## ពេលថ្ងៃត្រង់

២:៥០ – ៤:១០

**ការពិភាក្សាស្របពេលគ្នា ២ក៖**
"ប្រព័ន្ធនវានុវត្តន៍ថ្នាក់តំបន់តាមរយៈកិច្ចសហការរវាងសាកលវិទ្យាល័យ អាជ្ញាធរខេត្ត មន្ទីរជំនាញពាក់ព័ន្ធ និងវិស័យឧស្សាហកម្មនៅភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា"

**វាគ្មិន៖**

- ឯកឧត្តម មូល ធន អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង
- លោកបណ្ឌិត ប៉ុញ ឧត្តម អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង
- លោកស្រី ហួរ ដានី អនុប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តបាត់ដំបង
- លោកស្រី អ៊ូច សុម៉ាលី ម្ចាស់សហគ្រាសសីហាម៉ាលី ណែមត្រីបាត់ដំបង

**អ្នកសម្របសម្រួល៖**

- លោកបណ្ឌិត ថាច់ ប៊ុនរឿន  សាកលវិទ្យាល័យជាតិបាត់ដំបង

---

**ការពិភាក្សាស្របពេលគ្នា ២ខ៖**
"ការពង្រឹងកិច្ចគាំពារសង្គមសម្រាប់ពលករចំណាកស្រុកកម្ពុជា  នៅក្នុងប្រទេស"

**វាគ្មិន៖**

- លោក ឡុង ចំរើន នាយករងវិទ្យាល័យ កំរៀង
- លោក រិទ្ធិ សុធីរ៉ា អនុប្រធានភូមិ
- កញ្ញា លន ម៉ាឡា គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ
- កញ្ញា ប៉ែន ពិន ជំនួយការរដ្ឋបាលឃុំ
- លោក ហែម ប៊ុនហ៊ាន នាយកប្រតិបត្តិនៃមណ្ឌលទទួលពលករកំរៀង

**អ្នកសម្របសម្រួល៖**

- លោក អ៊ីល អឿ នាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលសំរាប់ការវិភាគបញ្ហាអភិវឌ្ឍន៍

៤:៤០ – ៥:០០

**សុន្ទរកថាបិទកម្មវិធី**

ឯកឧត្តម ថោង សុគន្ធ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធនៃទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកគណៈកម្មាធិការប្រឹក្សាផ្នែកបច្ចេកទេសនៃកម្មវិធីពន្លកចំណេះ

# ឧបសម្ព័ន្ធ ៣៖ ការផ្សាយព័ត៌មានក្នុងប្រព័ន្ធផ្សព្វផ្សាយ

១. វិស័យដឹកជញ្ជូន ត្រូវបានចាត់ទុកជាសក្តានុពលខ្លាំងក្លាមួយរបស់ខេត្តសៀមរាប ក្រៅពីវិស័យទេសចរណ៍ និងកសិកម្ម - CNC News

២. អង្គការមូលនិធិអាស៊ី រៀបចំវេទិកាគោលនយោបាយថ្នាក់ខេត្ត ផ្តោតពង្រឹងការសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ - Khmer Times

៣. Australia and The Asia Foundation Support Inclusive Policymaking in Cambodia's Provinces - The Asia Foundation

៤. Cambodia pushes evidence-based policymaking to provincial level | The Phnom Penh Post

ផ្អែកលើសមិទ្ធផលនៃកម្មវិធីពន្លកចំណេះ ដំណាក់កាលទី១ (២០១៩-២០២៣) ដែលមានគោលបំណងពង្រឹងសមត្ថភាពស្ថាប័នវិស័យស្រាវជ្រាវនៅកម្ពុជា ដើម្បីការស្រាវជ្រាវប្រកបដោយគុណភាព អង្គការមូលនិធិអាស៊ី កំពុងអនុវត្តកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា (២០២៣-២០២៧)។ ក្រោមការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី កម្មវិធីនេះ មានគោលដៅរួមចំណែកដល់ការសម្រេចចិត្តផ្អែកគោលនយោបាយសាធារណៈ ដែលផ្អែកលើទិន្នន័យ និងមានការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន ត្រូវបានអនុវត្ត និងក្លាយជាបទដ្ឋាននៅកម្ពុជា។

ទំនាក់ទំនងយើងខ្ញុំ


**អង្គការមូលនិធិអាស៊ី | ការិយាល័យប្រចាំកម្ពុជា**

ផ្ទះលេខ ៥៩ ផ្លូវឧកញ៉ាពេជ្រ (ផ្លូវ ២៤២) រាជធានីភ្នំពេញ កម្ពុជា

ponlok.chomnes@asiafoundation.org

+855 (0)23 210 431

https://policypulse.org/



Australian Aid

PONLOK CHOMNES

The Asia Foundation